សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# រដ្ឋបាលឌីជីថលនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **អ៊ូច វិចិត្រ**

ណែនាំដោយ
លោក **ហៀង សាន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# រដ្ឋបាលឌីជីថលនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អ៊ូច វិចិត្រ**

ណែនាំដោយ

លោក **ហៀង សាន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ **អ៊ូច ទិចិត្រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២៣-២០២៤។

**សូមថ្លែងអំណរគុណដ៏យ៉ាងជ្រាលជ្រៅជូនៈ**

លោកឪពុកអ្នកម្តាយ លោកទាំងទ្វេបានបង្កើតរូបរាងកាយកូន និងបានការចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានឱ្យកូនរៀនសូត្រ និងជានិច្ចកាលលោកទាំងទ្វេបានលើកទឹកចិត្តកូនគ្រប់វិនាទី។ គុណូបការៈគុណយ៉ាងអនេកប្បការ និងវិសេសថ្លៃថ្លាបំផុតនេះធ្វើឱ្យកូនចងចាំ និងមិនអាចកាត់ថ្លៃបានឡើយ។

ទន្ទឹមនឹងនេះ មានការចូលរួមជំរុញលើកទឹកចិត្តពីសំណាក់ប្រពន្ធសម្លាញ់ កូនសំណព្វចិត្ត បងប្អូនជាទីគោរពស្រឡាញ់ និងមិត្តភ័ក្តិជាទីរាប់អានផងដែរ។

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ជាពិសេសអនុបណ្ឌិត **ហៀង សាន** សាស្ត្រាចារ្យនីតិសាធារណៈ និងជាប្រធានដេប៉ាតឺម៉ង់នីតិឯកជននៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាសាស្ត្រាចារ្យណែនាំ។ លោកមានទេពកោសល្យ និងបទពិសោធន៍ច្រើនហើយបានចំណាយពេលវេលាដ៏មានតម្លៃ និងផ្តល់ការណែនាំជាទ្រឹស្តីក៏ដូចជាការអនុវត្តនៅក្នុងការសិក្សាស្រាវជ្រាវនេះ។ អ្វីដែលលោកបានចែកជូន គឺសុទ្ធតែជាគំនិតល្អៗជាធាតុចូលយ៉ាងសំខាន់ដែលនៅក្នុងការអភិវឌ្ឍធនធានមនុស្សលើវិស័យឌីជីថលនៅព្រះរាជាណាចក្រកម្ពុជា។

សូមប្រសិទ្ធពរជូនលោកអ្នកបានប្រកបតែសុភមង្គល និងសេចក្តីចម្រុងចម្រើនជានិច្ច!!!

## អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា មានការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចប្រកបដោយវឌ្ឍនភាព និងនិរន្តរភាពជាងពីរទសវត្សរ៍ ដោយសារតែរាជរដ្ឋាភិបាលមានឆន្ទៈដ៏មោះមុត នៅក្នុងការលើកកម្ពស់គុណភាពសេវាសាធារណៈ នៅក្នុងគោលបំណងទទួលយកការផ្លាស់ប្តូរនៃបរិបទរដ្ឋបាល និងការផ្តល់សេវាសាធារណៈថ្មីតាមបែបបច្ចេកវិទ្យា ដើម្បីបំពេញតម្រូវការប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។ ប៉ុន្តែមុននឹងឈានដល់ការរីកចម្រើននេះក៏បានជួបនូវការរាំងស្ទះក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាល ទៅកាន់ប្រជាពលរដ្ឋដោយសារកំណើនប្រជាជនចេះតែកើនឡើង ហើយតម្រូវការនៃការផ្តល់សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋក៏កាន់តែកើនឡើងជាលំដាប់ ដែលជាហេតុធ្វើឱ្យមានការកកស្ទះ និងភាពយឺតយ៉ាវដោយសារការតម្រូវឱ្យមកដល់ទីកន្លែងផ្ទាល់ខ្លួនដើម្បីទទួលសេវាសាធារណៈនៅតាមស្ថាប័នចំណុះរបស់រាជរដ្ឋាភិបាល។ ដោយយោងតាមការមើលឃើញពីបញ្ហានេះ ទើបខ្ញុំបាទជ្រើសរើសយកប្រធានបទមួយនេះមកបង្ហាញអំពីរដ្ឋបាលឌីជីថលនៅកម្ពុជាបច្ចុប្បន្នមកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវសរសេរសារណាបញ្ចប់ការសិក្សានេះ។

ប្រធានបទ **រដ្ឋបាលឌីជីថលនៅកម្ពុជាបច្ចុប្បន្ន** ជាប្រធានបទថ្មីមួយដែលពិពណ៌នាអំពីរបៀបក្នុងការគ្រប់គ្រងរដ្ឋបាល និងរបៀបនៃការផ្តល់សេវាសាធារណៈតាមបែបបច្ចេកវិទ្យាទំនើបដែលហៅម្យ៉ាងទៀតថារដ្ឋាភិបាលឌីជីថលដែលបង្កឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្លាទាំងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចពេលបច្ចុប្បន្ន និងអនាគត។ នៅក្នុងការផ្តល់សេវាសាធារណៈតាមបែបឌីជីថលនេះ បាននាំមកនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវការកែតម្រូវ និងអភិវឌ្ឍន៍បន្ថែមទៀតក្នុងពេលតែមួយនេះដែរ វាក៏បាននាំមកនូវលទ្ធផលល្អ និងថាមពលដល់មនុស្សគ្រប់ៗរូបតាមរយៈការផ្តល់ឱ្យមានការទទួលសេវាសាធារណៈតាមការប្រើប្រាស់នូវបណ្តាញឌីជីថលផ្សេងៗ។

ដោយសារចំណេះដឹងនៅមានកម្រិត ខ្ញុំបាទសង្ឃឹមថាកំហុសខុសឆ្គងទៅលើផ្នែកអត្ថន័យ ខ្លឹមសារពាក្យពេចន៍ ឃ្លាឃ្លោង អក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការសរសេរសារណាអាចកើតមាន។ ដូច្នេះ ខ្ញុំបាទសូមធ្វើការខន្តីអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយនោះ ដែលកើតមានឡើងដោយប្រការណាមួយពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យ មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវក៏ដូចមហាជនទាំងអស់។ ព្រមជាមួយនោះ ខ្ញុំបាទសូមទទួលយកនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាដើម្បីធ្វើជាទុនធ្វើការកែលម្អ និងជាបទពិសោធន៍ដើម្បីជំរុញឱ្យការស្រាវជ្រាវលើសារណាមួយនេះកាន់តែល្អប្រសើរ និងប្រកបដោយគុណភាព។

# មាតិកា

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣

៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ........ ៤

៧. រចនាសម្ពន្ធនៃការសិក្សាស្រាវជ្រាវ ........ ៤


## ជំពូកទី១

## រំពូកទ្រឹស្ដីនានាទាក់ទងនឹងទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាល


**១.១. និយមន័យ** ........ ៦

១.១.១. រដ្ឋបាល ........ ៦

១.១.២. ការចូលប្រើប្រាស់ (Access) ........ ៧

១.១.៣. អ្នកទទួល (Addressee) ........ ៧

១.១.៤. ប្រព័ន្ធស្វ័យប្រវត្តិ (Automate System) ........ ៧

១.១.៥. ប័ណ្ណ ឬកាតទូទាត់ (Card) ........ ៧

១.១.៦. កម្មវិធីចម្លងមេរោគ (Contaminant) ........ ៧

១.១.៧. ទិន្នន័យ (Data) ........ ៧

១.១.៨. អេឡិចត្រូនិក (Electronic) ........ ៧

១.១.៩. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Commerce) ........ ៨

១.១.១០. ទម្រង់អេឡិចត្រូនិក (Electronic Form) ........ ៨

១.១.១១. ការគ្រប់គ្រងរដ្ឋបាលតាមបែបបច្ចេកវិទ្យា ........ ៨

**១.២. បទដ្ឋានគតិយុត្ត** ........ ១០

១.២.១. ច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ........ ១០

១.២.២. ច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១១

១.២.៣. ច្បាប់ ស្តីពីការប្រកួតប្រជែង ........ ១១

១.២.៤. ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ........ ១២

១.២.៥. ច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ ........ ១២

១.២.៦. គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ........ ១២

**ជំពូកទី២**

**សញ្ញាណទូទៅនៃការផ្តល់សេវាសាធារណៈតាមបែបឌីជីថល**

**២.១. សញ្ញាណទូទៅ** ........ ១៧

២.១.១. សារតារ ........ ១៧

២.១.១.១. ចក្ខុវិស័យ ........ ១៨

២.១.១.២. បេសកកម្ម ........ ១៨

២.១.១.៣. គោលបំណង ........ ១៨

២.១.២. មុខងាររបស់រដ្ឋាភិបាលកម្ពុជាតាមបែបឌីជីថល ........ ១៩

**២.២. បំណែងចែកនៃការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថល** ........ ២០

២.២.១. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G២C) ........ ២០

២.២.២. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន (G២B) ........ ២១

២.២.៣. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល (G២G) ........ ២១

២.២.៤. ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G២E) ........ ២២

**២.៣. ដំណាក់កាលនៃការអនុវត្តរបស់រដ្ឋាភិបាលឌីជីថលកម្ពុជា ....................................២២**

២.៣.១. គោលនយោបាយសេដ្ឋកិច្ចឌីជីថល ........................................................................២៣

២.៣.២. គោលនយោបាយសង្គមឌីជីថល..........................................................................២៤

## ជំពូកទី៣

## រដ្ឋបាលសាធារណៈនៅកម្ពុជាបច្ចុប្បន្ន

**៣.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅកម្ពុជា.....................................................................២៦**

៣.១.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈ........................................................................២៦

៣.១.២. ការគ្រប់គ្រងសេវារដ្ឋបាលសាធារណៈ ..................................................................២៧

៣.១.៣. ការកែលម្អគុណភាពសេវាសាធារណៈ ...................................................................២៧

៣.១.៤. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ...............................................................២៨

៣.១.៥. ការកែទម្រង់ប្រព័ន្ធបៀវត្ស ..............................................................................២៨

**៣.២. ការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាលឌីជីថលកម្ពុជាបច្ចុប្បន្ន.......................................២៩**

៣.២.១. របៀបរបបនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង ស្ថាប័ន.................................៣១

៣.២.១.១. ក្រសួងពាណិជ្ជកម្ម ....................................................................................៣១

៣.២.១.២. អគ្គនាយកដ្ឋានពន្ធដារ.................................................................................៣៣

៣.២.១.៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ...........................................................៣៥

៣.២.១.៤. ក្រសួងមហាផ្ទៃ ........................................................................................៣៥

៣.២.២. ការចាត់វិធានការទប់ស្កាត់នូវជំងឺកូវីដ-១៩តាមរយៈប្រព័ន្ធបច្ចេកវិទ្យា .................................៣៥

៣.២.២.១. ក្រសួង ស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជន ...............................................................៣៦

៣.២.២.២. ក្រសួងសុខាភិបាល ....................................................................................៣៦

៣.២.២.៣. ក្រសួងអប់រំ យុវជន និងកីឡា .........................................................................៣៧

**៣.៣. លទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល.................. ៣៧**

៣.៣.១. ការកែលម្អគុណភាពសេវាសាធារណៈ ............................................................ ៣៨
៣.៣.២. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ............................................................ ៣៨

## ជំពូកទី៤

## បញ្ហាប្រឈម និងដំណោះស្រាយ

**៤.១. បញ្ហាប្រឈម និងទិសដៅការងារបន្ទាប់** ............................................................ ៤០
៤.១.១. បញ្ហាប្រឈម ............................................................ ៤២
៤.១.១.១. សេដ្ឋកិច្ច ............................................................ ៤៣
៤.១.១.២. ផលិតភាព ............................................................ ៤៤
៤.១.១.៣. ផលប៉ះពាល់ទៅលើជំនាញ ............................................................ ៤៤
៤.១.១.៤. សង្គម ............................................................ ៤៥
៤.១.២. ទិសដៅការងារបន្ទាប់ ............................................................ ៤៥
**៤.២. ដំណោះស្រាយ និងការប្រកួតប្រជែង** ............................................................ ៤៧
**សេចក្តីសន្និដ្ឋាន** ............................................................ ៥១
**អនុសាសន៍** ............................................................ ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

កម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចតម្រូវឱ្យនិស្សិតធ្វើការសរសេរនូវរបាយការណ៍ស្រាវជ្រាវ ឬសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្លួន។ ឆ្លៀតពេលនេះ ខ្ញុំបានសម្រេចចិត្តសរសេរសារណាបញ្ចប់ការសិក្សា ដោយលើកយកប្រធានបទស្តីពីរដ្ឋបាលឌីជីថលនៅកម្ពុជាបច្ចុប្បន្ន។

ប្រទេសកម្ពុជាស្ថិតនៅក្នុងការកសាង និងអភិវឌ្ឍន៍ទៅលើកម្មវិធីឌីជីថលសម្រាប់ធ្វើការគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលប្រើប្រាស់ដោយកុំព្យូទ័រ និងតម្រូវឱ្យមានធនធានមនុស្ស ដែលមានជំនាញពិតប្រាកដដល់ផ្នែកព័ត៌មានវិទ្យានេះ។ នៅក្នុងឆ្នាំ២០២១ ការអនុវត្តបន្ថែមទៅលើការបញ្ជាប្រព័ន្ធឌីជីថលមានភាពលឿនរហ័សជាងមុនជាមួយនឹងការផ្តល់ព័ត៌មានរួមសហការប្រតិបត្តិនៅក្នុងការចូលជាជំនួយលើការផ្សព្វផ្សាយ និងការបង្ហាញជាដើម។ ការចែករំលែកដោយប្រព័ន្ធបច្ចេកវិទ្យាបានចាប់ផ្តើមមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងស្របពេលវិបត្តិស្ថានការណ៍កូវីដ១៩កំពុងផ្ទុះបន្តពីឆ្នាំ២០១៩មក។ ការរីកដាលនៃជំងឺនេះ ជាឱកាសដែលត្រូវការគ្រប់គ្រងតាមប្រព័ន្ធឌីជីថលសម្រាប់ការចែករំលែក ឬផ្តល់ព័ត៌មានទៅក្នុងសង្គមបានលឿនឆាប់រហ័សក៏ព្រោះតែមានការលំបាកនៅក្នុងការជួបជុំគ្នាផ្ទាល់។ ចាប់ពីពេលនោះមក ប្រព័ន្ធបច្ចេកវិទ្យាដែលដាក់ឱ្យដំណើរការផ្ទាល់ពីរាជរដ្ឋាភិបាលធ្វើឱ្យមានការផ្លាស់ប្តូរ និងការកើនឡើងនូវធនធានមនុស្សជាមួយនឹងដំណើរការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ប្រព័ន្ធទូរគមនាគមន៍ និងប្រៃសណីយ៍។

ស្របពេលជាមួយគ្នានេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានបន្តជំរុញលើកកម្ពស់ឱ្យស្របស្តង់ដារអន្តរជាតិមានតម្លៃសមរម្យ និងសេវាកម្មទំនើបគ្របដណ្តប់ទូទាំងប្រទេសតាមរយៈការអនុវត្តរបស់រាជរដ្ឋាភិបាល នៅក្នុងការបើកទូលាយឱ្យមានការចូលរួមពីវិស័យឯកជនដោយគ្មានការរើសអើងឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្ត និងកាតព្វកិច្ចនៅក្នុងក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក។ ការរៀបចំក្នុងការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធឌីជីថលដោយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះដែលបានចូលរួម។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

នៅក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលតាមរយៈប្រព័ន្ធឌីជីថលនេះស្របពេលនៃវិបត្តិកូវីដ១៩កើតមានឡើងគឺមានលក្ខណៈល្អប្រសើរណាស់។ ក៏ប៉ុន្តែ វិបត្តិកូវីដ១៩នេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចប្រទេសកម្ពុជាយើង ដែលធ្វើឱ្យរាជរដ្ឋាភិបាលប្រឈមនឹងការលុបចោលផ្នែកខ្លះនៅក្នុងបរិបទមួយចំនួន។ ការបន្តឆ្លងនូវជំងឺកូវីដ១៩នេះ នាំឱ្យមានការធ្លាក់ចុះយ៉ាងខ្លាំងស្ទើរគ្រប់ផ្នែកនៃក្បាលម៉ាស៊ីនដឹកនាំរបស់រដ្ឋ។ បច្ចុប្បន្ននេះ ការរៀបចំផែនការផ្សេងៗលើការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលទៅកាន់គ្រប់ផ្នែកបានរហ័សក្នុងការសហការគ្នាតែក៏នៅមានបញ្ហាចោទមួយចំនួនកើតមានឡើងជារឿយៗ។ ចំពោទបញ្ហាទាំងនោះមានដូចជា៖

- តើការគ្រប់គ្រងរដ្ឋបាលសាធារណៈតាមប្រព័ន្ធឌីជីថលនេះមានលក្ខណៈល្អប្រសើរដូចម្ដេច?
- តើការគ្រប់គ្រងតាមប្រព័ន្ធឌីជីថលនេះមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ឬទេ?
- តើមានការវិវត្តអ្វីខ្លះជាមួយប្រព័ន្ធបច្ចេកវិទ្យាទំនើបនេះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងការជ្រើសរើសប្រធានបទនេះមកធ្វើសារណា ខ្ញុំបាទបានឆ្លងកាត់ការពិភាក្សាគិតគូរមុនមកហើយ និងមានគោលបំណងដូចជាដើម្បីបង្កើនការយល់ដឹងនូវល្បឿននៃបដិវត្តន៍ឌីជីថល និងផលប៉ះពាល់ជាច្រើនរបស់វា។ ការយល់ដឹងអំពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកតាមរយៈការរៀបចំមូលដ្ឋានគ្រឹះដែលជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថល។ នៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ ពលរដ្ឋ និងធុរជន ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពសង្គម។ ឈ្វេងយល់ពីស្ថានភាពក្នុងការគ្រប់គ្រង និងវិធានការនាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាលឌីជីថលផ្ដោតលើសមាសធាតុចំនួនប្រាំដែលចែកចេញជាគ្រឹះចំនួនពីររួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថលក្នុងការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល គោលនយោបាយ បន្ទាប់គឺការកសាងពលរដ្ឋឌីជីថលកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល។ សមិទ្ធផលដែលសម្រេចបានពីការគ្រប់គ្រងទៅលើប្រព័ន្ធបច្ចេកវិទ្យាទំនើបនេះ គឺអាចទាញយកផលប្រយោជន៍ពីសេដ្ឋកិច្ចជាមួយ និងសង្គមឌីជីថលឱ្យបានជាអតិបរមាព្រមទាំងទទួលបានការកាត់បន្ថយពីផលប៉ះពាល់ ឬផលអវិជ្ជមានឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

មានទំហំ និងដែនកំណត់ ដោយខ្ញុំស្រាវជ្រាវពីការគ្រប់គ្រង ការអនុវត្តការងាររដ្ឋបាល និងការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលកម្ពុជា តាមបែបបច្ចេកវិទ្យាដែលមានការធ្វើបដិវត្តន៍ជាច្រើនដំណាក់កាល ដែលបានរំលេចឡើងអំពីកំណែទម្រង់រដ្ឋាភិបាលឌីជីថលតាំងពីសម័យបុព្វកាល រហូតមកដល់បច្ចុប្បន្ន ដោយបច្ចុប្បន្ន រាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្តន៍នូវគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាពីឆ្នាំ២០២១-២០៥០ក្នុងចក្ខុវិស័យ ដើម្បីសម្រេចបាននូវវិសាលភាពនៃការអនុវត្តដែលឆាប់ស្រូបយកបច្ចេកវិទ្យា និងនវានុវត្តន៍ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទនេះ គឺពិតជាបានផ្តល់នូវសារៈសំខាន់ជាច្រើនសម្រាប់សិស្ស និស្សិត និងមន្ត្រីរាជការមានដូចជាចំពោះសង្គម បានបង្ហាញអំពីចក្ខុវិស័យក្នុងការអភិវឌ្ឍប្រទេសពីមួយដំណាក់កាលទៅមួយដំណាក់កាលនៃការធ្វើកំណែទម្រង់។ បង្ហាញពីក្នុងការផ្លាស់ប្តូរនៃការផ្តល់សេវាសាធារណៈ ហើយនឹងការពន្លឿនល្បឿននៃនវានុវត្តន៍ឌីជីថលជាពិសេសក្នុងបរិបទការអភិវឌ្ឍនេះ។ សាយភាយនូវចំណេះដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ទៅកាន់ប្រជាពលរដ្ឋឱ្យមានលក្ខណៈយល់ដឹង និងងាយស្រួលក្នុងការអនុវត្តព្រមទាំងឆាប់ចាប់យក និងរហ័សក្នុងការសម្របខ្លួនជាមួយការងារបែបទំនើបទាន់សម័យ។ សម្រួលនូវការទទួលបានសេវានៃការចុះបញ្ជីអាជីវកម្ម ឬការស្នើសុំសេវាសាធារណៈអ្វីមួយទៅកាន់រដ្ឋាភិបាលដោយធ្វើឡើងតាមរយៈប្រព័ន្ធឌីជីថល។ បង្ហាញពីបច្ចេកវិទ្យាឌីជីថលអាចមានអន្តរកម្មជាមួយនឹងពិភពជីវសាស្ត្រផងដែរ។

ចំពោះអង្គភាព ឬក្រុមហ៊ុនទទួលបានការយល់ដឹងអំពពីរបៀបក្នុងការចុះបញ្ជីអាជីវកម្មតាមរយៈប្រព័ន្ធអ៊ីនធឺណេត។ មានការយល់ដឹងបន្ថែមពីការប្រើប្រាស់សេវាសាធារណៈឱ្យចំទិសដៅ មានទំនុកចិត្តក្នុងការធ្វើអាជីវកម្មដោយកាត់បន្ថយភាពស្មុគស្មាញក្នុងការធ្វើអាជីវកម្ម ឬការចុះបញ្ជីអ្វីមួយ។

ចំពោះខ្ញុំផ្ទាល់ បានពង្រឹងនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនតាមររយៈការស្រាវជ្រាវ ការប្រមូលផ្តុំនិងការរៀបរៀងនូវរបាយការណ៍ស្រាវជ្រាវ។ ទទួលបាននូវពុទ្ធិបន្ថែមតាមរយៈការស្វះស្វែងរកប្រភពព័ត៌មានឯកសារថ្មីៗជាច្រើន និងបានដកស្រង់នូវខ្លឹមសារល្អៗដែលទាក់ទងទៅនឹងការអនុវត្តការងាររដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា។ យល់ដឹងកាន់តែច្បាស់ អំពីរបៀបរបបនៃការប្រើប្រាស់ប្រព័ន្ធឌីជីថលនៅក្នុងការអនុវត្តការងាររដ្ឋបាល និងការចាត់វិធានការទប់ស្កាត់ស្ថានភាពប្រទេសជាតិពីជំងឺដ៏កាចសាហាវ (កូវីដ-១៩)។ យល់ដឹងពីការប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមបែបថ្មី។ បន្ថែមនូវបទពិសោធន៍ថ្មីតាមរយៈការសិក្សាពីចម្ងាយ (E-Learning) ដែលជាការផ្លាស់ប្តូរសម្របខ្លួនទៅតាមបរិបទថ្មីសម័យកូវីដ-១៩ ផងដែរ។

ចំពោះអ្នកអាន ឬអ្នកស្រាវជ្រាវជំនាន់ក្រោយ មានការយល់ដឹងពីរបៀបរបបក្នុងការដឹកនាំតាមរយៈវិធីសាស្ត្រថ្មីដែលមានលក្ខណៈទំនើប និងជឿនលឿនរបស់រាជរដ្ឋាភិបាល។ យល់ដឹងបន្ថែមពីការចុះបញ្ជីធ្វើអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដែលប្រកបដោយភាពងាយស្រួល ហើយចំណេញពេលវេលាព្រមទាំងមានសុវត្ថិភាព។ ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយអាចយកទៅសិក្សាស្រាវជ្រាវបន្ត និងធ្វើបច្ចុប្បន្នភាពបន្ថែមផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ គឺបានធ្វើការសិក្សាស្រាវជ្រាវបែបគុណភាព និងស៊ីជម្រៅទៅលើការផ្ដល់សេវាសាធារណៈតាមបែបឌីជីថលរបស់រាជរដ្ឋាភិបាល ការដាក់ចេញនូវគោលនយោបាយ ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក និងការគ្រប់គ្រងស្ថានភាពជាក់ស្ដែងដែលយើងពឹងផ្អែកទៅលើទិន្នន័យចម្បង ដូចជាច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឆ្នាំ២០១៩ និងច្បាប់ស្តីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០១៩ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ព្រមទាំងទិន្នន័យបន្ទាប់បន្សំដែលរួមមានលិខិតបទដ្ឋានគតិយុត្តនានាដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ។

## ៧. រចនាសម្ពន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីសរសេរសារណានេះ ឱ្យទៅជាកិច្ចការស្រាវជ្រាវមានសោភណភាព របៀបរៀបរយ និងគុណភាពដែលផ្តល់នូវភាពងាយស្រួលដល់អ្នកអាន ឬអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបន្តបន្ទាប់ ខ្ញុំបានរៀបចំនូវការស្រាវជ្រាវដែលមានរចនាសម្ពន្ធនៃការស្រាវជ្រាវត្រឹមត្រូវតាមក្បួនខ្នាត និងមានលក្ខណៈពេញលេញដែលក្នុងនោះខ្ញុំបានបែងចែកខ្លឹមសារចេញជាបួនជំពូក គឺជំពូកទីមួយបង្ហាញពីការរំឭកទ្រឹស្តីនានាពាក់ព័ន្ធនឹងទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាល។ ចំណែកជំពូកទីពីរវិញ បង្ហាញពីសញ្ញាណទូទៅនៃទំនើបកម្មរដ្ឋបាលសាធារណៈតាមបែបបច្ចេកវិទ្យានៅក្នុងជំពូកនេះបែងចែកជាបីចំណុចបន្ថែម ដោយចំណុចទី១និយាយអំពីសញ្ញាណទូទៅនៃការផ្តល់នៅសេវារដ្ឋបាលសាធារណៈ ចំណុចទី២បង្ហាញអំពីបំណែងចែកនៃការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថល និងចំណុចទី៣បរិយាយអំពីដំណាក់កាលនៃការអនុវត្តរដ្ឋាភិបាលឌីជីថលកម្ពុជា។ ចំពោះជំពូកទីបីវិញ បង្ហាញពីស្ថានភាពរដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្នដោយលើកក្នុងជំពូកនេះ បែងចែកជាពីរចំណុចទី១និយាយអំពីស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលឌីជីថលកម្ពុជានាពេលបច្ចុប្បន្នចំណុចទី២បានលើក

ពីលទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល និងជំពូកចុងក្រោយលើកយកមកបង្ហាញបញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅការងារបន្ទាប់។

# ជំពូកទី១

# រំពូកទ្រឹស្តីនានាទាក់ទងនឹង

# ទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាល

# ជំពូកទី១

# រំឭកទ្រឹស្តីនានាទាក់ទងនឹងទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាល

## ១.១. និយមន័យ

### ១.១.១. រដ្ឋបាល

**រដ្ឋបាល** មានអត្ថន័យទូលំទូលាយណាស់ហើយក៏អាចឱ្យអត្ថន័យជាច្រើនបែបច្រើនយ៉ាងផងដែរ។ ជាអត្ថន័យនៃពាក្យរដ្ឋបាលតាមលក្ខណៈខុសគ្នាដូចតទៅ៖

**ក. ន័យអក្សរសាស្ត្រ**

រដ្ឋបាល បានមកពីពាក្យរដ្ឋ+អភិបាល ដោយរដ្ឋមានន័យថាដែន ឬប្រទេស ចំណែកឯអភិបាលសំដៅលើអ្នកគ្រប់គ្រង អ្នកបីបាច់ថែរក្សា អ្នកថែរក្សា។ ដូច្នេះ រដ្ឋបាល មានន័យថាអ្នករក្សាដែន ឬប្រទេស។[១]

**ខ. ន័យអង្គការ**

**រដ្ឋបាល** គឺសំដៅលើរដ្ឋបាលសាធារណៈ មានន័យថាជារដ្ឋការ ឬរាជការ ពោល គឺក្រសួងសាធារណៈទាំងអស់ចំណុះរដ្ឋាភិបាល។ រដ្ឋការ ឬរាជការ ឬក្រសួងរាជការក៏សំដៅលើស្ថាប័នគ្រប់គ្រង អង្គការគ្រប់គ្រង ឬអំណាចគ្រប់គ្រង។ ដូច្នេះ រដ្ឋការគឺអង្គភាព មន្ទីរ ក្រសួង ស្ថាប័នដែលមានរចនាសម្ពន្ធ និងតួនាទីបំពេញគោលដៅប្រយោជន៍សាធារណៈ ទោះអង្គភាពនេះមានលក្ខន្តិកៈប្រភេទណាក៏ដោយ។[២]

**គ. ន័យទូលាយបែបបច្ចេកទេស**

**រដ្ឋបាល** ត្រូវបានគេយល់គ្រប់គ្នាថាជាសកម្មភាព ឬជាការគ្រប់គ្រងរដ្ឋ ពីព្រោះជួនកាលគេប្រើជាសកម្មភាព ជួនកាលជាលក្ខណៈអង្គការហើយថែមទាំងប្រើបានទៅលើវិស័យឯកជន និងវិស័យសាធារណៈទៀតផង។

**ឃ. ន័យចង្អៀតបែបបច្ចេកទេស**

**រដ្ឋបាល** សំដៅទៅលើរដ្ឋបាលសាធារណៈ។ អាចប្រើពាក្យថារដ្ឋការ ឬរាជការដែលមិននាំឱ្យមានការភ័ន្តច្រឡំជាមួយពាក្យរដ្ឋបាលក្នុងវិស័យឯកជននោះទេ។[៣]

---

[១] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[២] សៀវភៅ សិក្ខាប័ននីតិរដ្ឋបាល, រៀបរៀងដោយលោក អ ចំរើន, បោះពុម្ពឆ្នាំ២០១១, ទំព័រvii

[៣] សៀវភៅនីតិរដ្ឋបាល, រៀបរៀងដោយលោកសាស្ត្រាចារ្យហៀង សាង, បោះពុម្ពលើកទី៦ ឆ្នាំ២០២១, ទំព័រ២

**១.១.២. ការចូលប្រើប្រាស់** ( Access )

សំដៅដល់ការចូលប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិកដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យព័ត៌មាន ឬឯកសារផ្សេងៗទៀតនៅក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

**១.១.៣. អ្នកទទួល** ( Addressee )

សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

**១.១.៤. ប្រព័ន្ធស្វ័យប្រវត្តិ** ( Automate System )

សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្តាញ អេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹង ឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

**១.១.៥. ប័ណ្ណ ឬកាតទូទាត់** ( Card )

សំដៅដល់ប័ណ្ណ ឬកាតធនាគារ ប័ណ្ណឥណទាន / ប័ណ្ណឥណពន្ធ ស្មាតកាត ឬប័ណ្ណ/កាតទូទាត់ទោះក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃហើយមានមុខងារសម្រាប់ទូទាត់។

**១.១.៦. កម្មវិធីចម្លងមេរោគ** ( Contaminant )

សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បីកែប្រែ បំផ្លាញ កត់ត្រាទិន្នន័យ ឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក និងជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក។

**១.១.៧. ទិន្នន័យ** ( Data )

សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិកដែលត្រូវបានរៀបចំក្នុងទម្រង់សម្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក។

**១.១.៨. អេឡិចត្រូនិក** ( Electronic )

សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនីឌីជីថល ម៉ាញ៉េទិច អុបទិក ជីវមាត្រអេឡិចត្រូគីមី វ៉ាយអឺឡេស អេឡិចត្រូម៉ាញ៉េទិច ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

**១.១.៩. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ( Electronic Commerce )

សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវាដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក។

**១.១.១០. ទម្រង់អេឡិចត្រូនិក** ( Electronic Form )

សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

**១.១.១១. ការគ្រប់គ្រងរដ្ឋបាលតាមបែបបច្ចេកវិទ្យា**

ការគ្រប់គ្រងតាមបែបបច្ចេកវិទ្យា គឺផ្តោតទៅលើការផ្តល់សេវា និងការគ្រប់គ្រងរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលអាចធ្វើការកំណត់អត្ថន័យពីរផ្សេងទៀត គឺរដ្ឋាភិបាលអេឡិចត្រូនិក និងរដ្ឋាភិបាលឌីជីថល។

**ក. រដ្ឋាភិបាលអេឡិចត្រូនិក**

រដ្ឋាភិបាលអេឡិចត្រូនិក ឬហៅថា E-government[៤] គឺសំដៅទៅលើរដ្ឋាភិបាលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) [៥] ជាពិសេសអ៊ីនធឺណេតជាឧបករណ៍ដើម្បីសម្រេចបានរដ្ឋាភិបាលកាន់តែប្រសើរ។ ពោលគឺរដ្ឋាភិបាលអេឡិចត្រូនិក គឺជាការប្រើប្រាស់ឧបករណ៍ទំនាក់ទំនងបច្ចេកវិទ្យាដូចជាកុំព្យូទ័រ និងអ៊ីនធឺណេតដើម្បីផ្តល់សេវាកម្មសាធារណៈបម្រើដល់ប្រជាពលរដ្ឋ និងមនុស្សដទៃទៀតនៅក្នុងប្រទេស ឬតំបន់។

រដ្ឋាភិបាលអេឡិចត្រូនិក ផ្តល់នូវឱកាសថ្មីៗសម្រាប់ប្រជាពលរដ្ឋឱ្យចូលទៅកាន់រដ្ឋាភិបាលដោយផ្ទាល់ និងងាយស្រួលជាងមុនថែមទាំងសម្រាប់ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលដោយផ្ទាល់ដល់ប្រជាពលរដ្ឋ។

និយាយដល់ពាក្យថារដ្ឋាភិបាលអេឡិចត្រូនិក គឺផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលដែលទាក់ទងនឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ឬICT ដោយប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណេត (Internet) និងគេហទំព័រផ្អែកលើប្រព័ន្ធបច្ចេកវិទ្យា ( Web-based Technologies) ដែលនាំនូវព័ត៌មាន និងសេវាកម្មឱ្យក្លាយទៅជាពិភពលោកតែមួយចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៩០មក។ រដ្ឋាភិបាលជាច្រើននៅជុំវិញពិភពលោកកំពុងអនុវត្តន៍រដ្ឋាភិបាលឌីជីថលរួមជាមួយនឹងភាពជឿជាក់នៅក្នុងដំណើរការរបស់រដ្ឋ។[៦]

---

[៤] E-government = Electronic-government.

[៥] ICT= Information and Communication Technologies.

[៦] OECD, the E-government Imperative, Paris: OECD Publications, ២០០៣.

## ខ. រដ្ឋាភិបាលឌីជីថល

រដ្ឋាភិបាលឌីជីថល (Digital Government) សំដៅលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។[៧] រួមបញ្ចូលគ្នាជាមួយយុទ្ធសាស្ត្រធ្វើទំនើបកម្មរបស់រដ្ឋាភិបាលដើម្បីបង្កើតតម្លៃសាធារណៈ។ តួអង្គសំខាន់ៗរបស់ប្រព័ន្ធអេកូឡូស៊ីនៃរដ្ឋាភិបាលឌីជីថលដែលរួមមានរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អាជីវកម្ម សហគមន៍ ប្រជាពលរដ្ឋ និងបុគ្គលដែលគាំទ្រដល់ការបង្កើត ការទទួលទិន្នផល សេវាកម្ម និងមាតិកាតាមរយៈអន្តរកម្មជាមួយរដ្ឋាភិបាល។[៨]

ដោយសារតែវិស័យសាធារណៈ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋ ការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ និងការធ្វើបរិវត្តកម្មប្រព័ន្ធសេវាសាធារណៈដែលត្រូវឈរលើមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលប្រកបដោយភាពជឿនលឿន និងទាន់សម័យសម្រាប់កម្ពុជា រាជរដ្ឋាភិបាលបានអនុវត្តន៍នូវកម្មវិធី និងគំនិតផ្តួចផ្តើមមួយចំនួនក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវប្រព័ន្ធរដ្ឋបាលសាធារណៈ និងសេវាសាធារណៈជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តីការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសាធារណៈគឺស្ថិតក្នុងល្បឿនមួយដែលយឺតធៀបនឹងកម្រិតមធ្យមនៅក្នុងអនុតំបន់ តំបន់ និងសាកលលោក។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ដែលត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើម និងកិច្ចការកែទម្រង់ពាក់ព័ន្ធដើម្បីសម្របខ្លួនទៅជារដ្ឋាភិបាលឌីជីថល។[៩]

រដ្ឋាភិបាលឌីជីថល នេះមានអន្តរកម្មឌីជីថលរវាង៖

- ពលរដ្ឋ និងរដ្ឋាភិបាលរបស់ពួកគេ (C2G)
- រដ្ឋាភិបាល និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត (G2G)
- រដ្ឋាភិបាល និងពលរដ្ឋ (G2C)
- រដ្ឋាភិបាល និងនិយោជិត (G2E)
- រដ្ឋាភិបាល និងធុរកិច្ច / មិត្តភក្តិ (G2B)។

---

[៧] បច្ចេកវិទ្យាឌីជីថល សំដៅដល់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) រួមមាន អ៊ីនធឺណេត បច្ចេកវិទ្យា និងឧបករណ៍ចល័តក៏ដូចជាបច្ចេកវិទ្យាវិភាគទិន្នន័យដែលត្រូវបានប្រើដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាន់ ការប្រមូល ការផ្លាស់ប្តូរ ការរួមបញ្ចូលគ្នា ការវិភាគ ការលទ្ធភាពស្វែងរក និងការបង្ហាញនៃមាតិកាឌីជីថលរួមទាំងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍសេវាកម្ម និងសូហ្វវែរកម្មវិធីផ្សេងៗទៀត។

[៨] គេហទំព័រ https://secudemy.com/egov-digital/ ដកស្រង់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤។

[៩] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥, ទំព័រទី១៧។

បច្ចេកវិទ្យាទាំងនេះអាចផ្តល់ជូននូវភាពខុសគ្នាជាច្រើនដូចជា៖

- ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលឱ្យកាន់តែប្រសើរដល់ប្រជាពលរដ្ឋ
- ផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋតាមរយៈការទទួលបានព័ត៌មាន ឬការគ្រប់គ្រងរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព
- អត្ថប្រយោជន៍ដែលទទួលបានអាចជាការកាត់បន្ថយអំពើពុករលួយ បង្កើននូវតម្លាភាព បង្កើនភាពងាយស្រួលដែលអាចឱ្យប្រជាជនមានអំណាចក្នុងការចូលទៅប្រើប្រាស់ព័ត៌មានកាន់តែឆាប់រហ័ស
- បង្កលក្ខណៈងាយស្រួលដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងរដ្ឋបាល
- ជួយឱ្យប្រទេសជាតិមានការកំណើនប្រាក់ចំណូល នៅតាមវិស័យតាមរយៈការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា។

ចំណែកឯក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានកំណត់និយមន័យរដ្ឋាភិបាលអេឡិចត្រូនិកថាជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដោយស្ថាប័នរដ្ឋាភិបាលដើម្បីធ្វើទំនាក់ទំនង ឬផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត។[១០]

## ១.២. បទដ្ឋានគតិយុត្ត

### ១.២.១. ច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ច្បាប់នេះ មានគោលបំណងការពារម៉ាក ពាណិជ្ជនាមដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម។ ចំពោះម៉ាក គឺជាសញ្ញាដែលមើលឃើញហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវាកម្មសហគ្រាសនីមួយៗ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញ ហៅថាពាណិជ្ជសញ្ញាហើយម៉ាកដែលប្រើប្រាស់សម្រាប់សេវាហៅថាសេវាសញ្ញា។ ចំពោះម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជីហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសម្គាល់នូវចរិតលក្ខណៈរួមដទៃទៀតគិតទាំងគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី។ ដោយឡែកពាណិជ្ជនាមវិញ គឺជាឈ្មោះ ឬសញ្ញាសម្គាល់ ឬជាឈ្មោះ និងសញ្ញាសម្គាល់សម្រាប់បញ្ជាក់ និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ។

[១០] គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ "ឆ្ពោះទៅសន្តិភាព និងសកម្មភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន" នៃឧបសម្ពន្ធទី១ វាក្យសព្ទទំព័រទី១។

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

### ១.២.២. ច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ។ បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក។ ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក។ ចំពោះគោលដៅនៃច្បាប់នេះវិញ គឺកំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។ ជំរុញការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងធុរកិច្ចដើម្បីអនុវត្តន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។ បង្ការ និងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យ និងប្រព័ន្ធព័ត៌មាន។ លុបបំបាត់ឧបសគ្គទាំងឡាយ ដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតលាយលក្ខណ៍អក្សរ និងហត្ថលេខា។ សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈតាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។ បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដារដែលទាក់ទងនឹងយថាភូតភាព និងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។ ច្បាបនេះ អនុវត្តន៍លើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹងការបង្កើតឬអនុវត្តន៍លិខិតប្រគល់សិទ្ធិ ការបង្កើត ឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។ រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យ ឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។ ការផ្ទេរអចលនវត្ថុ ឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។ ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

### ១.២.៣. ច្បាប់ ស្តីពីការប្រកួតប្រជែង

ច្បាប់នេះ កំណត់អំពីសកម្មភាពដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងព្រមទាំងបង្កើត និងកំណត់សមត្ថកិច្ចរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជាក្នុងគោលបំណង ដើម្បីលើកទឹកចិត្តឱ្យមានទំនាក់ទំនងធុរកិច្ចដោយស្មើភាព និងស្មោះត្រង់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីៗ និងជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញ និងសេវាមានគុណភាពខ្ពស់ ថ្លៃទាប សម្បូរបែប និងមានជម្រើសច្រើន។

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលធ្វើសកម្មភាពធុរកិច្ច ឬធ្វើសកម្មភាពគាំទ្រដល់ធុរកិច្ច ពាក់ព័ន្ធនឹងការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ទោះបីសកម្មភាពនោះមានប្រភពនៅក្នុង ឬក្រៅប្រទេសក៏ដោយ។

### ១.២.៤. ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

ច្បាប់នេះ មានវិសាលភាពអនុវត្តន៍ចំពោះរាល់សហគ្រាសពាណិជ្ជកម្ម រាល់ផលិតករក្នុងគោលដៅពាណិជ្ជកម្ម អ្នកនាំចូល អ្នកនាំចេញទំនិញ អ្នកលក់ដូរទំនិញ សេវាករនៃសេវាកម្មដែលពាក់ព័ន្ធនឹងផលិតផល ទំនិញ អ្នកឃោសនាពាណិជ្ជកម្មអំពីផលិតផល ទំនិញ និងសេវា អង្គការសង្គម និងអង្គការក្រៅរដ្ឋាភិបាល ដែលចូលរួមក្នុងសកម្មភាពផលិតកម្មពាណិជ្ជកម្ម ឬជំនួយមនុស្សធម៌។ ផលិតកម្ម ក្នុងន័យនៃច្បាប់នេះសំដៅលើរាល់ប្រតិបត្តិការរួមមានការចិញ្ចឹមសត្វ ការយកទឹកដោះសត្វ ការប្រមូលផលដំណាំ ការបេះផ្លែឈើ ការនេសាទ សត្តឃាត ការផលិត ការកែច្នៃ និងការវេចខ្ចប់ផលិតផលទំនិញរួមទាំងការស្តុកទុកក្នុងរយៈពេលផលិតផល និងការបំពេញសេវាមុនដំណើរការពាណិជ្ជកម្មលើកដំបូង។ ពាណិជ្ជកម្មក្នុងន័យនៃច្បាប់នេះ សំដៅលើរាល់ប្រតិបត្តការស្តីពីការស្តុក ការដឹកជញ្ជូន ការកាន់កាប់ក្នុងគោលបំណងលក់ដូរ ការដាក់តាំងលក់ ការលក់នូវរាល់មុខទំនិញ។ ការប្រគល់ឱ្យដោយឥតគិតថ្លៃនូវគ្រប់ផលិតផលអាហារណែកម្ម នីហរណែកម្មព្រមទាំងការដាក់លក់ ការលក់សេវាកម្ម ឬការផ្តល់សេវាដោយឥតគិតថ្លៃ។

### ១.២.៥. ច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ

ច្បាប់នេះ កំណត់អំពីក្របខណ្ឌ និងយន្តការសម្រាប់គ្រប់គ្រង និងធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់នៃម្ហូបអាហារក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហា ដើម្បីផ្តល់ការការពារសុខភាព និងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។ ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាព និងសុវត្ថិភាពម្ហូបអាហារដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ និងលើអាជីវកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២.៦. គោលនយោបាយយុទ្ធសាស្ត្រចតុកោណ

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងរួមគ្នាបំពេញតួនាទីជាឯកសារក្របខណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ដែលនឹងមានកំណត់សូចនាករលទ្ធផល និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងដែលត្រូវមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយតាមវិស័យដទៃទៀតរបស់រាជ

រដ្ឋាភិបាល។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងក្លាយជាមគ្គុទេសដ៏ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ឱ្យស្ថិតនៅក្នុងជីវភាពនៃប្រព័ន្ធតួអង្គតែមួយ។ លទ្ធផលធំៗចំនួន៨ដែលរាជរដ្ឋាភិបាលបានសម្រេចកន្លងមក ហើយតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ក្នុងរយៈពេលខាងមុខបន្តទៀត កម្ពុជានឹងប្រឈមជាមួយនិន្នាការវិវត្តធំៗមួយចំនួនទាំងក្នុង និងក្រៅប្រទេសដែលជាកត្តាសត្យានុម័តកំណត់នូវបរិការណ៍ និងទិសដៅនៃដំណើរការអភិវឌ្ឍប្រទេសដែលអាចនឹងស្តែងឡើងជាបញ្ហាប្រឈមផង និងកាលានុវត្តភាពផង។ តាមបទពិសោធន៍ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង៣ដំណាក់កាលកន្លងមក រាជរដ្ឋាភិបាលអាចធ្វើការវាយតម្លៃបានត្រឹមត្រូវពីភាពខ្លាំង និងភាពខ្សោយក៏ដូចជាបញ្ហាប្រឈម និងកាលានុវត្តភាព។ **យុទ្ធសាស្ត្រចតុកោណ** នៅតែមានភាពចាំបាច់សម្រាប់បន្តការអនុវត្តនៅក្នុងដំណាក់កាលទី៤បច្ចុប្បន្ននេះ និងតទៅមុខទៀតដែលនឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពសំខាន់ៗដូចខាងក្រោម៖

ទី១- ភាពចាំបាច់ក្នុងការបន្តពង្រឹង និងពង្រីកសមិទ្ធផលនានាដែលរាជរដ្ឋាភិបាលសម្រេចបាន ក្នុងនីតិកាលទី៥កន្លងមក ដូចជាក្នុងបញ្ចប់ការងារសេសសល់ទាំងឡាយនៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណទាំង៣ដំណាក់កាលមុន តាមរយៈការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការលើកស្ទួយនីតិរដ្ឋ សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកកម្ពស់កម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាជនពិសេសការដោះស្រាយបញ្ហា**ប្រសិទ្ធភាព**នៃអភិបាលកិច្ច និងបញ្ហាយុត្តិធម៌សង្គមព្រមទាំងការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ។

ទី២- ភាពចាំបាច់ក្នុងស្វែងរកប្រភពថ្មី ដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ដោយទាញយកប្រយោជន៍ពីកាលានុវត្តភាពនៅក្នុងតំបន់ បង្កើតតម្លៃបន្ថែមក្នុងវិស័យចន្ទល់សេដ្ឋកិច្ចដែលមានស្រាប់ និងអនុវិស័យពាក់ព័ន្ធជំរុញការវិនិយោគក្នុងវិស័យកសិកម្ម រៀបចំខ្លួនសម្រាប់ការឈោងចាប់យកបច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល និងឈោងចាប់យកឱកាសក៏ដូចជាជម្នះផលវិបាកពីបដិវត្តន៍ឧស្សាហកម្មទី៤.០ ព្រមទាំលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងគោលដៅឆ្លើយតប និងដោះស្រាយនូវរាល់កង្វល់ និងសំណូមពរថ្មីៗរបស់ប្រជាជនកម្ពុជានៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ និងក្នុងគោលដៅបម្រើឱ្យបេសកកម្មនៃការដឹកនាំកម្ពុជា ឈានទៅសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានកំណត់យក**គោលដៅយុទ្ធសាស្ត្រ៤** និង**វិស័យអាទិភាព៤** ជាការប្តេជ្ញាចិត្តក្នុងការបន្តអនុវត្ត**យុទ្ធសាស្ត្រចតុកោណ**ទៀត។ ក្នុងបរិការណ៍បច្ចុប្បន្នផ្អែកលើភាពចាំបាច់កម្ពុជាបានត្រៀមលក្ខណសម្បត្តិយ៉ាងឬត់ចត់ និងគ្រប់ជ្រុងជ្រោយដើម្បីប្រើប្រាស់ឱ្យអស់

នូវកាលានុវត្តភាព និងសក្តានុពលរបស់ខ្លួនសំដៅបន្តដោះស្រាយបញ្ហាប្រឈមនានាក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍជាតិ។ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** នៅរក្សាជារួមនូវរចនាសម្ព័ន្ធដើមរបស់ខ្លួន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានកែសម្រួលលំដាប់អាទិភាពតាមការដ្ឋានរួម និងមុំមួយចំនួននៃយុទ្ធសាស្ត្រនេះព្រមទាំងបញ្ចូលអាទិភាពថ្មីមួយចំនួនហើយបានសម្រិតសម្រាំង និងសម្រួចសកម្មភាពមួយចំនួនបន្ថែមទៀតដើម្បីៈ

- ទី១. ឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង និងបរិការណ៍ថ្មីៗរបស់កម្ពុជា និង
- ទី២. លើកកម្ពស់កិច្ចអភិវឌ្ឍតាមរយៈការពង្រឹងទំនាក់ទំនង ឬអន្តរសកម្មរវាងបណ្តាទិសដៅទាំង៤នៃយុទ្ធសាស្ត្រ គឺ**កំណើនការងារ សមធម៌ និងប្រសិទ្ធភាព** ដែលជាកញ្ចប់នៃសមីការតែមួយដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ អំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលនៅក្នុងការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។ រចនាសម្ព័ន្ធចំនួន៤ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះរួមមានៈ

១- ស្នូលនៃយុទ្ធសាស្ត្រ គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច

២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

៣- ចតុកោណយុទ្ធសាស្ត្រទាំង៤

៤- មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ

ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណសម្រាប់នីតិកាលទី៦នៃរដ្ឋសភានឹងអនុវត្តនូវៈ

១- ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

២- ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ

៣- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង

៤- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន។

ទិសដៅសំខាន់បំផុតនៃការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចនេះ ដើម្បីធានាធម្មានុរូបភាព និងភាពជឿជាក់ពីសាធារណជនតាមរយៈការកសាងស្ថាប័នរដ្ឋឱ្យមាននូវប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតបគណនេយ្យភាព និងតម្លាភាព។

ការរៀបចំរបាយការណ៍បញ្ចប់ការសិក្សានេះ សូមលើកយកមកតែចំណុចដែលទាក់ទងទៅនឹងប្រធានបទការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនៅកម្ពុជា ដែលជាផ្នែកមួយនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

**ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនៅកម្ពុជា** គឺជាផ្នែកមួយនៃការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចដែលសមាសធាតុស្នូល និងបរិស្ថានគ្របដណ្តប់នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ក្នុងន័យនេះកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាប្រកបដោយ **ចក្ខុវិស័យយុទ្ធសាស្ត្រ និងគោលបំណង**ច្បាស់លាស់ក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសធារណៈ និងធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ។

**ក. ចក្ខុវិស័យ**

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្ពោះទៅសម្រេចបានចក្ខុវិស័យរបស់ខ្លួន គឺប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលជឿទុកចិត្តបានសំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។

**ខ. គោលបំណង**

ផ្អែកលើចក្ខុវិស័យខាងលើគោលបំណងសំខាន់ៗត្រូវបានកំណត់ និងសម្រេចឱ្យបានក្នុងនោះរួមមាន៖

១- សេវាសាធារណៈប្រកបដោយគុណភាព សាមញ្ញ ប្រសិទ្ធភាព ភាពជឿទុកចិត្តបាន និងឆាប់រហ័សដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការ។

២- ការគ្រប់គ្រង និងអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ស្វាហាប់ ប្រសិទ្ធភាព មនសិការវិជ្ជាជីវៈ និងភាពជឿជាក់ទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ។

**គ. គោលដៅ**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្មវិធីជាតិនេះបានកំណត់គោលដៅជាក់លាក់ដូចជាសេវាសាធារណៈត្រូវធ្វើកែលម្អតាមបែបទំនើបកម្មតាមសម័យកាល និងធានាភាពងាយស្រួលនៅក្នុងការទទួលយកសេវាទៅប្រើប្រាស់ ផ្តល់សេវាដែលផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់ក៏ដូចជាផ្តល់សេវាឱ្យចំទីកន្លែងដែលមានសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក៏តម្រូវឱ្យកែលម្អដែលត្រូវរៀបចំតួនាទី របៀបគ្រប់គ្រង និងចាត់ចែងឱ្យមានភាពច្បាស់លាស់។ ជំនាញរបស់មន្ត្រីផ្តល់សេវាត្រូវតែឆ្លើយតបនឹងតម្រូវការ និងលើកកម្ពស់គុណភាពជាមួយនឹងការទទួលខុសត្រូវខ្ពស់។

រាល់កម្មវិធីកំណែទម្រង់ចាំបាច់ ទាមទាឱ្យមានយន្តការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដែលក្នុងនោះគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងសហការជាមួយគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍដើម្បីដាក់ឱ្យអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

ការអនុវត្តកម្មវិធីជាតិនេះ គឺដើម្បីធ្វើវិចារណកម្មរដ្ឋបាលសាធារណៈតាមរយៈការកែលម្អគុណភាពនៃសេវាសាធារណៈ ការកែលម្អការគ្រប់គ្រង ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ និងកែលម្អប្រព័ន្ធបៀវត្សបន្ថែមទៀតតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា។

**ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនៅកម្ពុជា** គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការសម្រេចបានចក្ខុវិស័យវែងឆ្ងាយរបស់ប្រទេសកម្ពុជាដែលមាន សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខរាជរដ្ឋាភិបាល។

# ជំពូកទី២

# សញ្ញាណទូទៅនៃការផ្តល់សេវាសាធារណៈតាមបែបឌីជីថល

# ជំពូកទី២

# សញ្ញាណទូទៅនៃការផ្ដល់សេវាសាធារណៈតាមបែបឌីជីថល

## ២.១. សញ្ញាណទូទៅ

សម័យបច្ចេកវិទ្យាទំនើបឌីជីថលនេះ បានទំលាយនូវឧបសគ្គជាច្រើនដែលកាលពីមុនធ្លាប់តែមានការប្រើប្រាស់ឯកសារដែលសរសេរដោយដៃ និងប្រើប្រាស់អាជ្ញាធរសាធារណៈដើម្បីការពារ។ ក៏ប៉ុន្តែ បច្ចុប្បន្នវាបង្ហាញឱ្យឃើញនូវសមត្ថភាព ឬប្រសិទ្ធភាពក៏ស្ដួចស្ដើងរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហា ដូចជាអភិបាលកិច្ច ឬរាជការផ្សេងៗតាមរយៈការប្រើប្រាស់អេឡិចត្រូនិក។ ការផ្ដល់សេវាសាធារណៈ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះគឺជាការផ្ដល់នូវព័ត៌មាន និងការផ្ដល់សេវាកម្មដ៏ប្រសើរដែលត្រូវនឹងតម្រូវការរបស់សង្គមជាតិយើងសព្វថ្ងៃ។ ប៉ុន្តែមុននឹងឈានជើងដល់ចំណុចល្អប្រសើរជាងមុននេះ គឺប្រទេសកម្ពុជាបានឆ្លងកាត់នូវការធ្វើបដិវត្តន៍ក្នុងការផ្ដល់សេវាសាធារណៈ។ ដូចគ្នានេះដែរ រាជរដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងឡាយកំពុងចូលរួមក្នុងការកែប្រែប្រព័ន្ធគ្រប់គ្រងក៏ដូចជាប្រព័ន្ធអប់រំ ប្រព័ន្ធថែទាំសុខភាព ប្រព័ន្ធគមនាគមន៍ និងប្រព័ន្ធផ្សេងៗជាច្រើនទៀត។ វិធីថ្មីនៃការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីផ្លាស់ប្ដូរឥរិយាបថក្នុងការផ្ដល់សេវា ប្រព័ន្ធផលិតកម្ម និងការប្រើប្រាស់របស់យើងក៏បានផ្ដល់សក្ដានុពលសម្រាប់ការគាំទ្រដល់ការបង្កើត និងល្បឿនវិសាលភាពនៃការផ្លាស់ប្ដូរ។

### ២.១.១. សារៈសំខាន់

ការរីកចម្រើនបច្ចេកវិទ្យាទំនើបយ៉ាងឆាប់រហ័សនៅក្នុងសម័យកាលនេះ ដែលត្រូវបានអនុញ្ញាតឱ្យមានការសំយោគបញ្ចូលគ្នានូវមាតិកាព័ត៌មាន ការប្រើប្រាស់ ការអភិវឌ្ឍបច្ចេកវិទ្យាកុំព្យូទ័រ ការផ្សព្វផ្សាយ ការទំនាក់ទំនង និងការចែកចាយ។ មិនតែប៉ុណ្ណោះឥទ្ធិពលនៃសមត្ថភាពធនធានមនុស្សបានជំរុញឱ្យមានការបង្កើតនូវគុណប្រយោជន៍ដ៏ពេញនិយមនាពេលបច្ចុប្បន្ននេះ គឺបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ការរួមបញ្ចូលគ្នានៃបច្ចេកវិទ្យាបាននាំមកនូវការផ្លាស់ប្ដូរ និងការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងវិស័យមួយចំនួនដូចជាការគ្រប់គ្រងចំណេះដឹងរួមមានទាំងការបង្កើតការចម្រាញ់ ការរក្សាទុក ការចែករំលែក ការផ្សព្វផ្សាយចំណេះដឹង ការធ្វើសហប្រតិបត្តិការ និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងកម្រិតអប់រំ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាបង្កើតនូវគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលនឹងតម្រូវឱ្យរាជរដ្ឋាភិបាលផ្ដួចផ្ដើមគំនិត និងគាំទ្រដើម្បីសម្រេចឱ្យបានជោគជ័យក្នុងចក្ខុវិស័យឆ្នាំ២០១៥។[១១] ហេតុនេះហើយទើបមានព្រះរាជក្រឹត្យស្ដីពីការរៀបចំ

---

[១១] គោលនយោបាយជាតិស្ដីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០០៩ "សំណើគោលនយោបាយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា"។

និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលហត្ថលេខា និងព្រះរាជលញ្ឆករដោយប្រមុខរដ្ឋស្តីទីសម្តេចអគ្គមហាធម្មពោធិសាលជា ស៊ីម ចុះនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅកម្ពុជាឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសជឿនលឿនក្នុងតំបន់ និងក្នុងសាកលលោក។[១២] ជាក់ស្តែងប្រទេសកម្ពុជាសម្រេចបាននូវការរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច និងសង្គមដ៏គួរឱ្យចាប់អារម្មណ៍នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែទាក់ទងទៅនឹងការអភិវឌ្ឍទៅលើចំណេះដឹងជាមូលដ្ឋាន កម្ពុជាមិនសូវមានការវិវឌ្ឍខ្លាំងទេបើប្រៀបធៀបទៅនឹងប្រទេសជិតខាង។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរកំពុងកើតមានឡើងទាំងក្នុងកម្រិតរដ្ឋាភិបាលចំពោះការដាក់ចេញនូវឯកសារផែនការសំខាន់ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងកម្រិតសហគមន៍។

### ២.១.១.១. ចក្ខុវិស័យ

ដោយមានប្រវត្តិជាប្រទេសអច្ឆរិយ និងមានទីតាំងភូមិសាស្ត្រពិសេស ព្រះរាជាណាចក្រកម្ពុជានឹងក្លាយជាដៃគូប្រកួតប្រជែងពិតប្រាកដ និងជាសង្គមមានគ្រឹះចំណេះដឹង និងព័ត៌មានក្នុងពិភពលោក និងប្រកាន់នូវដំណោះស្រាយផ្អែកលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចប្រកបដោយចីរភាព។

### ២.១.១.២. បេសកកម្ម

ធ្វើសមាហរណកម្មនូវសកម្មភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅក្នុងវិស័យសាធារណៈ ព្រមទាំងឯកជន និងធានាជូននូវការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកស្ទួយសង្គមព្រមទាំងការសម្រេចនូវកិច្ចព្រមព្រៀងបទដ្ឋានសហគមន៍រួមមាន លើកកម្ពស់សម្បជញ្ញៈប្រឆាំងទៅនឹងកំណើនសីតុណ្ហភាពពិភពលោក ផ្តល់បទដ្ឋានច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ពន្ធសាធារណៈ និងឯកជនក្នុងការកសាងនូវសមត្ថភាពពាណិជ្ជកម្មអេឡិចត្រូនិកដោយជំរុញឱ្យមានកំណើនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានតំបន់។

### ២.១.១.៣. គោលបំណង

ដោយយោងទៅតាមចក្ខុវិស័យក្នុងការសម្លឹងមើលការរៀបចំប្រទេសឱ្យទទួលបានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងគុណភាពទើបរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលបំណងដើម្បីសម្រេចការងារក្នុងការជំរុញការអភិវឌ្ឍប្រទេសឱ្យមានភាពកាន់តែឆាប់រហ័ស និងទទួលបានផលិតផលល្អប្រសើរតាមរយៈគោលបំណងដូចតទៅបង្កើត និងផ្តល់នូវបទដ្ឋាន និងគោលនយោបាយជាតិដែលនឹងអនុញ្ញាតឱ្យបច្ចេកវិទ្យា

[១២] ព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, លេខ នស/រកត/០៩១៤/១១៣៦, ០៨ កញ្ញា ២០១៤, មាត្រា១។

គមនាគមន៍ និងព័ត៌មានរួមចំណែកក្នុងការធ្វើឱ្យសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍ជាតិ។ ផ្តល់សេវាសាកល និងលទ្ធភាពអាចប្រើប្រាស់បាននូវព័ត៌មានរួមទាំងបរិក្ខារទំនាក់ទំនងនៅក្នុងប្រទេស ដែលនឹងនាំឆ្ពោះទៅរកការប្រកួតប្រជែងទិន្នផល និងផលិតផលលើឆាកអន្តរជាតិ។ ប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ឱ្យទៅជាសង្គមមួយដែលពោរពេញទៅដោយចំណេះដឹងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសមស្រប។ ផែនការមេរបស់កម្ពុជាក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគឺបានផ្តោតទៅលើធនធានមនុស្ស ការបណ្តុះបណ្តាល និងការលើកកម្ពស់អក្ខរកម្មឌីជីថល ( រាប់បញ្ចូលទាំងអ្នករស់នៅតាមជនបទ ) លទ្ធភាពនៅក្នុងការប្រើប្រាស់កុំព្យូទ័ររបស់មន្ត្រីរដ្ឋាភិបាល ដើម្បីពង្រីកហេដ្ឋារចនាសម្ពន្ធខាងវិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មាន និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត។ល។

### ២.១.២. មុខងាររបស់រដ្ឋាភិបាលកម្ពុជាតាមបែបឌីជីថល

រដ្ឋាភិបាលជាច្រើនបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ជាពិសេសប្រព័ន្ធអ៊ីនធឺណេត គេហទំព័រផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាផ្តល់នូវសេវាកាន់តែល្អព្រមទាំងជាសេនាធិការចំណុះឱ្យរដ្ឋាភិបាលសម្រាប់ប្រជាពលរដ្ឋ អាជីវកម្ម និងបុគ្គលិក។ លើសពីនេះទៅទៀតមុខងាររបស់រដ្ឋាភិបាលត្រូវបានពិពណ៌នាដូចខាងជា ប្រជាពលរដ្ឋអាចចូលទៅប្រើប្រាស់ព័ត៌មានរបស់រដ្ឋាភិបាលដែលផ្តល់មកនូវការចូលទៅប្រើប្រាស់ព័ត៌មានទាំងអស់របស់រដ្ឋាភិបាល គឺជាការផ្តួចផ្តើមដ៏សំខាន់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិកប្រភេទនៃការផ្តួចផ្តើមនេះផ្តល់ឱ្យនូវការដាក់ដំណើរការជាប្រព័ន្ធ។ សម្របសម្រួលអនុលោមភាពជាទូទៅ រដ្ឋាភិបាលអេឡិចត្រូនិកក៏បានណែនាំប្រព័ន្ធអេឡិចត្រូនិកភ្ជាប់ទៅកាន់សេវាប្រើប្រាស់ ដែលជួយសម្រួលអនុលោមភាពជាមួយនឹងបណ្តុំនៃច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗ។ ការចូលរួមរបស់ប្រជាពលរដ្ឋដោយប្រជាពលរដ្ឋអាចចូលរួមនៅក្នុងដំណើរការនៃការបង្កើតសេចក្តីសម្រេច តាមរយៈការប្រជុំពិភាក្សាតាមអនឡាញជាមួយនឹងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក (E-Voting[១៣])។

[១៣] E-Voting (Electronic Voting)៖ ការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកសំដៅទៅដល់ការបោះឆ្នោតតាមអេឡិចត្រូនិកគឺជាដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោត កត់ត្រាសន្លឹក និងដាក់តាមតារាងអេឡិចត្រូនិក។

## ២.២. បំណែងចែកនៃការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថល

ការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថលកម្ពុជាមានបំណែងចែក ឬអន្តរកម្មរវាងរដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G២C[១៤]) រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន (G២B[១៥]) រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល (G២G[១៦]) រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G២E[១៧])។

ការធ្វើបំណែងចែកនេះ សម្រាប់ផ្តល់នូវភាពសម្របសម្រួលក្នុងកិច្ចការងារសង្គម និងសេដ្ឋកិច្ចជាតិ ដើម្បីឱ្យគ្រប់វិស័យទាំងអស់ទទួលបានការរីកចម្រើន និងតម្លាភាពក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត។

### ២.២.១. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G2C)

ប្រភេទនៃសេវានេះរក្សានូវក្រសែភ្នែកនៃសកម្មភាពរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋសម្រាប់ការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកនៅក្នុងសមត្ថភាពនៃចំណេះដឹងខាងប្រព័ន្ធអេឡិចត្រូនិក។ ចំពោះអត្ថប្រយោជន៍ចម្បងនៃសេវាកម្មរបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ (G2C) គឺជាទម្រង់បំពេញបែបបទធម្មតា និងពាក្យស្នើសុំអនឡាញ។ ប្រជាពលរដ្ឋ អាចចូលទៅប្រើប្រាស់ព័ត៌មានរបស់រដ្ឋាភិបាលភ្លាមៗដោយពុំចាំបាច់ទៅកាន់ទីតាំងផ្ទាល់ទេ។ អត្ថប្រយោជន៍ផ្សេងៗទៀត គឺបានបម្រើសេវាកម្មនោះទៅកាន់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ចំណេះដឹងខាងព័ត៌មានវិទ្យានីតិវិធីសុវត្ថិភាព (Security procedure) និងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ ម៉្យាងវិញទៀត សេវាកម្មនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈសម្រាប់រូបវន្តបុគ្គលទូទៅ។

សេវាកម្មទាំងនេះ រួមមានការបន្តសុពលភាពនៃប័ណ្ណបើកបរ ការបង់ពន្ធ ការផាកពិន័យ ការបង់ប្រាក់ជូនរដ្ឋ វិក័យបត្រដែលចេញដោយអង្គភាពរបស់រដ្ឋ ឬស្ថាប័ន និងការបង់ថ្លៃសេវាប្រភេទផ្សេងៗ។

ជាក់ស្តែងសម្រាប់បច្ចុប្បន្ន ប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកមានកំណើនកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃដោយពួកគេប្រើប្រាស់សម្រាប់ធ្វើជំនួញ និងការបង្រៀនរៀនអនឡាញ (Online class) ការទំនាក់ទំនង ការផ្តល់សេវាកម្មសាធារណៈទូទៅរបស់រដ្ឋាភិបាល ការទទួលសេវាកម្ម ការទូទាត់ប្រាក់ផ្សេងៗជាដើម។ល។

[១៤] G2C= Government to Citizens

[១៥] G2B= Government-to-business

[១៦] G2G= Government to Government

[១៧] G2E= Government-to-employees

សកម្មភាពទាំងអស់នេះ គឺសុទ្ធសឹងតែឆ្លងកាត់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិករហូតឈានដល់ដំណាក់កាលអាចនឹងគាំងស្ទះដំណើរការទាំងអស់នៅគ្រប់ផ្នែក គ្រប់វិស័យប្រសិនបើមិនមានការប្រើប្រាស់ ឬការសម្រាលការងារពីប្រព័ន្ធបច្ចេកវិទ្យា។

### **២.២.២. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន** (G2B)

ប្រភេទនៃសេវានេះផ្តោតសំខាន់ទៅលើសមត្ថភាពនៃការកាត់បន្ថយថ្លៃចំណាយ ការប្រមូលព័ត៌មាន និងបង្កើនការគ្រប់គ្រងកាន់តែប្រសើរឡើង។ នៅក្នុងសេវាកម្មនេះ រដ្ឋាភិបាលអាចទទួលបានជាវត្ថុ ការបង់ថ្លៃវិក័យបត្រ និងបានឃើញពីសកម្មភាពអាជីវកម្មផ្សេងៗទៀតនៅក្នុងន័យបានទទួលផលប្រយោជន៍ពីអាជីវកម្មនោះ។ ការរក្សាបាននូវទិន្នន័យដើម្បីពិនិត្យបច្ច័យ និងជួយឱ្យការបង្កើតសេចក្តីសម្រេចអាចត្រូវធ្វើឡើងបានព្រមទាំងជួយគាំទ្ររដ្ឋាភិបាលតាមរយៈសេវាកម្មរដ្ឋាភិបាលទៅកាន់ធុរជន។ អត្ថប្រយោជន៍មួយចំនួនទៀតសម្រាប់ប្រភេទនៃសេវាកម្មនេះ មានដូចជា បទប្បញ្ញត្តិតាមប្រព័ន្ធអនឡាញដែលបានបង្ហាញសម្រាប់ស្ថាប័នឯកជន និងសម្របសម្រួលដល់ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់សហគ្រាស ក្រុមហ៊ុន ឬអាជីវកម្ម។

គោលបំណងនេះ ការផ្តល់សេវារបស់រដ្ឋាភិបាលទៅកាន់ធុរជនគឺដើម្បីកាត់បន្ថយការលំបាកសម្រាប់អាជីវកម្មផ្តល់ព័ត៌មានជាបន្ទាន់ និងបើកទំនាក់ទំនងតាមឌីជីថលតាមរយៈអាជីវកម្មអេឡិចត្រូនិក។

### **២.២.៣. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល** (G2G)

ចំពោះសេវានេះវិញ រួមមានការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការ និងមុខងារអាជីវកម្មដោយខ្លួនឯង ឬជាមួយនឹងរដ្ឋាភិបាល។ ដើម្បីឱ្យសេវានេះទទួលបាននូវការប្រើប្រាស់ដ៏ទូលំទូលាយលុះត្រាតែជាប្រភេទសេវាជាកញ្ចប់ដែលមានសមាគម និងដៃគូសហប្រតិបត្តិការធ្វើការរួមគ្នាយ៉ាងស្អិតរមួតជាមួយនឹងអគ្គនាយកដ្ឋាន ស្ថាប័ននានាដែលចំណុះឱ្យរាជរដ្ឋាភិបាល។ វាអនុញ្ញាតឱ្យរដ្ឋាភិបាលកាត់បន្ថយនូវអត្រាគ្មានការងារធ្វើ បទល្មើសអសុវត្ថិភាពតាមផ្ទះ (Homeless Security)។ សម្រាប់សកម្មភាពរដ្ឋាភិបាល បានណែនាំឱ្យមានការសហការគ្នាជាអន្តរក្រសួង បង្កើនការឆ្លើយតបឱ្យបានទាន់ពេលវេលា និងតភ្ជាប់ការប្រកាសរបស់អន្តរក្រសួង។ លើសពីនេះទៅទៀត សេវានេះផ្តល់ឱ្យនូវកិច្ចសហប្រតិបត្តិការទាំងអស់ទាំងក្នុង ក្រៅស្ថាប័ន និងពង្រឹងសេវាទាំងក្នុង និងក្រៅរដ្ឋាភិបាល។ វាក៏មានការផ្លាស់ប្តូរព័ត៌មានជាមួយរដ្ឋាភិបាល។ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការតាមប្រព័ន្ធអនឡាញដើរតួនាទីយ៉ាងសំខាន់រវាងស្ថាប័នរបស់រដ្ឋាភិបាល និងអគ្គនាយកដ្ឋាននានាដើម្បីចែករំលែកទិន្នន័យ ធនធាន ជំនាញ និងសមត្ថភាពលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិរបស់រដ្ឋាភិបាល។

### ២.២.៤. ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G2E)

យោងតាមប្រភេទនៃសេវា មានទំនាក់ទំនងរវាងរដ្ឋាភិបាល និងបុគ្គលិក។ ការផ្តល់សេវារដ្ឋាភិបាលទៅកាន់បុគ្គលិកលើកទឹកចិត្តឱ្យបុគ្គលិកចូលរួមដើម្បីបង្កើនប្រសិទ្ធភាព និងផ្តល់ឱ្យរបៀបនៃការសិក្សាពីចម្ងាយ (E-Learning)[18] ប្រមូលផ្តុំបុគ្គលិកទាំងអស់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងការធ្វើការងាររបស់ពួកគេ។ សេវានេះ ត្រូវបានពិពណ៌នាដោយផ្តល់ឱ្យបុគ្គលិកអាចចូលទៅប្រើប្រាស់គោលនយោបាយ ដែលទាក់ទងទៅនឹងការទូទាត់ប្រាក់សំណង និងអត្ថប្រយោជន៍ផ្សេងទៀតជាដើម។

## ២.៣. ដំណាក់កាលនៃការអនុវត្តរបស់រដ្ឋាភិបាលឌីជីថលកម្ពុជា

សេវាកម្មសាធារណៈតាមរយៈអ៊ីនធឺណេត ដែលដំណើរការក្រោមប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា គឺអាចជួយឱ្យប្រជាជនខ្មែរទទួលបានភាពងាយស្រួលនៅក្នុងការស្នើសុំការធ្វើលិខិតស្នាមរដ្ឋបាលតាមប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា។

ដោយប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យានេះមាន Application សម្រាប់រដ្ឋាភិបាលឌីជីថល ទំនាក់ទំនងទៅនឹងការអនុវត្តទៅលើទម្រង់បួនប្រភេទសំខាន់ៗដូចជា៖

**ក. ប្រព័ន្ធសច្ចានុម័តអេឡិចត្រូនិក EAS**[១៩]

មានគោលបំណងអនុញ្ញាតឱ្យក្រសួងទាំងអស់ផ្លាស់ប្តូរឯកសារគ្នាទាំងក្នុង និងក្រៅស្ថាប័នដោយរួមបញ្ចូលមុខងារការសរសេរដោយដៃអនុញ្ញាតឱ្យមានការប្រើប្រាស់ប្រព័ន្ធមានភាពងាយស្រួល។ ទម្រង់នេះបានកាត់បន្ថយការពន្យារពេលមិនចាំបាច់មួយចំនួន និងលទ្ធផលកាន់តែប្រសើរឡើងក្នុងសេវាសាធារណៈ។

**ខ. ប្រព័ន្ធចុះបញ្ជីយានយន្ត**

សម្រាប់យានយន្ត និងទោចក្រយានយន្ត និងអនុវត្តន៍ទៅលើការចុះបញ្ជីយានយន្ត ផ្តល់អាជ្ញាបណ្ណស្នើសុំបណ្ណបើកបរ និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ការផ្លាស់ប្តូររចនាសម្ពន្ធ ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ការត្រួតពិនិត្យ ការធ្វើប័ណ្ណសម្គាល់ (លេខអត្តសញ្ញាណកម្ម) ការធ្វើស្លាកលេខ ការបង់ពន្ធប្រថាប់ត្រាវិញ្ញាបនបត្រយានយន្ត ស្ថិតិ និងការគ្រប់គ្រងកម្មសិទ្ធិយានយន្ត ឬទោចក្រយានយន្ត។

---

[១៨] E-learning (Electronic learning)៖ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសំដៅទៅលើការរៀបតាមរយៈអេឡិចត្រូនិកដែលហៅម៉្យាងទៀតការសិក្សារៀនសូត្រតាមអ៊ីនធឺណេត ឬជាការសិក្សាតាមអេឡិចត្រូនិក គឺជាការទទួលបានចំណេះដឹងតាមរយៈបច្ចេកវិទ្យាអេឡិចត្រូនិក និងប្រព័ន្ធផ្សព្វផ្សាយ។

[១៩] EAS = Electronic Approval System.

**គ. ប្រព័ន្ធចុះបញ្ជីស្នាក់នៅ**

សម្រាប់អនុវត្តន៍ទៅលើការគ្រប់គ្រងទិន្នន័យនៃការចុះសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព ការផ្លាស់ប្តូរទីលំនៅ ការគ្រប់គ្រងសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារក៏ដូចជាព័ត៌មានសម្រាប់ការផ្តល់ឱ្យអត្តសញ្ញាណកម្ម ការចុះឈ្មោះបោះឆ្នោតព្រមទាំងការស្នាក់នៅរបស់ជនបរទេស។

**ឃ. ប្រព័ន្ធចុះបញ្ជីអចលនទ្រព្យ**

សម្រាប់គ្រប់គ្រងទៅលើអចលនទ្រព្យ ដូចជាការចុះបញ្ជី ឬការលុបចេញពីបញ្ជី ការបំបែក ការរួមបញ្ចូលទ្រព្យ ការគ្រប់គ្រងកម្មសិទ្ធិអចលនទ្រព្យ ការផ្លាស់ប្តូរកម្មសិទ្ធិ ដីរួម ពន្ធអចលនទ្រព្យ វិញ្ញាបនបត្រអចលនទ្រព្យព្រមទាំងស្ថិតិជាដើម។

### ២.៣.១. គោលនយោបាយសេដ្ឋកិច្ចឌីជីថល

ចំពោះក្នុងទិដ្ឋភាពសេដ្ឋកិច្ចការរីកចម្រើនបែបឌីជីថល បាននឹងកំពុងតែបង្កើតគំរូធុរកិច្ចថ្មីៗ ផ្លាស់ប្តូរដំណើរការផលិតកម្ម ប្រើប្រាស់ និងចែកចាយទំនិញ និងសេវាព្រមទាំងផ្លាស់ប្តូរនូវរបៀបធ្វើការជាបណ្តើរៗ សំដៅពង្រីកមូលដ្ឋានផលិតផល និងសេវាឌីជីថលគួបផ្សំនឹងការធ្វើទំនើបកម្មផលិតកម្ម និងការបង្កើនផលិតភាពប្រសិទ្ធភាពសេដ្ឋកិច្ចដែលឆ្លើយតបទៅនឹងការអភិវឌ្ឍនៃបច្ចេកវិទ្យាដែលយើងហៅថា**សេដ្ឋកិច្ចឌីជីថល**។

- **ក្នុងន័យចង្អៀតសេដ្ឋកិច្ចឌីជីថល** សំដៅលើទីផ្សារដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលដល់ការដោះដូរទំនិញ និងការផ្តល់សេវាតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬម្យ៉ាងទៀតគឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្អែកលើអ៊ីនធឺណេតនៅក្នុងដំណើរការផលិតកម្ម នៃការដោះដូរទំនិញ និងសេវា
- **ក្នុងន័យទូលំទូលាយសេដ្ឋកិច្ចឌីជីថល** សំដៅទៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធ ICT និងឌីជីថល។[20]

នៅក្នុងនោះដែរ ដើម្បីសម្រេចបាននូវគោលនយោបាយនេះប្រទេសកម្ពុជាមានសក្តានុពលទៅលើវិស័យសេដ្ឋកិច្ចឌីជីថលនេះឱ្យប្រកបដោយប្រសិទ្ធភាព និងគុណភាពក្នុងការអភិវឌ្ឍផងដែរដែលសក្តានុពលសំខាន់ៗទាំងនោះរួមមាន៖ **ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃតំបន់ និងសាកល** ដែលផ្តោតទៅលើផលិតកម្មនៅក្នុងស្រុក និងស្ថិតក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និងសម្របបានតាមនិន្នាការសាកលភាវូបនីយកម្មតាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និងសាកល។

[20] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥, ទំព័រទី៩។

**ការជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច** សេដ្ឋកិច្ចឌីជីថលបានធ្វើឱ្យមានគូប្រកួតប្រជែងយ៉ាងធំទូលាយ ហេតុនេះហើយទើបជាកត្តាដែលជំរុញឱ្យមានសកម្មភាពណិជ្ជកម្មកាន់តែមានភាពរីកដុះដាលពីមួយថ្ងៃទៅមួយថ្ងៃ។ ការផ្តោតលើប្រសិទ្ធភាពនៃប្រតិបត្តិការនៃការទិញលក់ទំនិញ និងសេវាជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈការទូទាត់កាន់តែងាយស្រួលរហ័សគួបផ្សំនឹងការដឹកជញ្ជូនលឿន និងមានតម្លៃសមរម្យនឹងត្រូវបានលើកកម្ពស់។ **ការបង្កើតការងារ ជំនាញ និងការវិនិយោគ** សព្វថ្ងៃនេះសេដ្ឋកិច្ចគឺអាស្រ័យទៅតាមតម្រូវការពោលគឺសេដ្ឋកិច្ចកំពុងតែផ្លាស់ប្តូរមូលដ្ឋានទំនាក់ទំនងរបស់យើងជាមួយ និងការងារព្រមទាំងរបៀបនៃការរៀបចំសង្គមបែបថ្មីផងដែរ ជាមួយគ្នានេះការលើកកម្ពស់សហគ្រិនភាព និងនវានុវត្តន៍នឹងបានរួមចំណែកក្នុងការបង្កើតធុរកិច្ចថ្មី និងការទាក់ទាញការវិនិយោគនៅក្នុងស្រុក និងក្រៅស្រុកនៅក្នុងវិស័យ ICT។ **ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ** ចំពោះវិស័យសាធារណៈការផ្តល់សេវាសាធារណៈត្រូវបានប្រព្រឹត្តទៅយ៉ាងរលូនមានភាពងាយស្រួលព្រមទាំងមានប្រសិទ្ធភាព និងតម្លាភាពកាន់តែខ្ពស់តាមរយៈការទទួលយកផ្នត់គំនិតឌីជីថល និងការលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ការដោះស្រាយបញ្ហាជារចនាសម្ពន្ធនៅក្នុងវិស័យប្រពៃណីរួមទាំងវិស័យសេដ្ឋកិច្ច សង្គម និងសន្តិសុខ។[២១]

### ២.៣.២. គោលនយោបាយសង្គមឌីជីថល

ទន្ទឹមនឹងការគាំទ្រដល់ការអភិវឌ្ឍ និងការជំរុញកំណើនសេដ្ឋកិច្ចវឌ្ឍនភាពសង្គមកម្ពុជាអាចសម្រេចបានតាមរយៈការរៀបចំនូវសង្គមឌីជីថលមួយដែលមានការចូលរួមពីកោសិការសង្គមទាំងអស់ ពោល គឺបុគ្គលគ្រប់រូបអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គល ក្រុមគ្រួសារ និងសហគមន៍ ការចូលរួមចំណែកបម្រើឱ្យសកម្មភាពសង្គម និងការទទួលបានសេវាសាធារណៈដោយគ្មានការរើសអើង។ ក្នុងនោះដែរ ដើម្បីសម្រេចបាននូវគោលនយោបាយនេះប្រទេសកម្ពុជាមានសក្តានុពលទៅលើវិស័យសង្គមឌីជីថលនេះឱ្យប្រកបដោយប្រសិទ្ធភាព និងគុណភាពក្នុងការអភិវឌ្ឍផងដែរ។

ក្នុងគោលនយោបាយខាងលើនេះ ក៏មានបង្កប់នូវសក្តានុពលសំខាន់ៗទាំងនោះរួមមាន**ការទទួលបានសេវាសង្គមកាន់តែងាយស្រួល និងភាពទូលំទូលាយតាមរយៈថ្នាលបច្ចេកវិទ្យាឌីជីថល** កោសិការសង្គមបាននឹងកំពុងប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថលដើម្បីទទួលបានសេវាសាធារណៈទាញយកព័ត៌មាន និងទិន្នន័យសិក្សារៀនសូត្រ និងបង្រៀនសរសេរអត្ថបទចែករំលែកចំណេះដឹង ស្វែងរកការងារ និងដៃគូជីវិតបង្ហាញពីទេពកោសល្យផ្ទាល់ខ្លួន និងកសាងបណ្តាញសម្រាប់ទំនាក់ទំនងទាំងនៅក្នុងប្រទេស និងឆ្លងប្រទេស។ **ការពង្រឹង**

[២១] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥, ទំព័រទី៦។

**ទំនាក់ទំនង និងការចែករំលែកក្នុងសង្គមកាន់តែស៊ីជម្រៅ** បុគ្គលម្នាក់ៗចាប់ផ្តើមមានទំនាក់ទំនង ការផ្សារភ្ជាប់គ្នាទៅវិញទៅមក និងអន្តរសកម្មកាន់តែស្និទ្ធិស្នាលបើកចំហ ដោយពុំខ្វល់ខ្វាយពីភាពខុសគ្នានៃឋានៈសង្គម ភូមិសាស្ត្រ ភេទ សាសនា និងជាតិសាសន៍ឡើយ។ សម្រាប់ប្រទេសកម្ពុជា ចំនួននៃការតភ្ជាប់នូវអ៊ីនធឺណេតតាមឧបករណ៍ចល័ត ជាពិសេសទូរស័ព្ទចល័តមានរហូតដល់១២៨%នៃចំនួនប្រជាជនសរុបដែលភាគច្រើនជាអ្នកប្រើប្រាស់ថ្នាល ឬប្រព័ន្ធសង្គម តួលេខនេះបានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋខ្មែរកាន់តែសកម្ម និងទូលំទូលាយក្នុងសង្គមឌីជីថលដោយបានប្រែក្លាយជាសកម្មភាពនៃជីវភាពប្រចាំថ្ងៃ។ **ការទទួលបានការកម្សាន្ត និងព័ត៌មានពីសង្គមតាមតម្រូវការ** សេវាឌីជីថលផ្សេងៗដូចជានិន្នាការនៃការភ្ជាប់ទូរ ទស្សន៍ឌីជីថល ការលេងហ្គេម វីដេអូ និងការបំពេញតម្រូវការមូលដ្ឋានដទៃទៀតតាមមធ្យោបាយឌីជីថលត្រូវបានសង្កេតឃើញថាបាន នឹងកំពុងចាប់ផ្តើមជ្រៀតចូលសង្គមបន្តិចម្តងៗ ជាពិសេសក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩។ នៅក្នុងពេលបច្ចុប្បន្ន យុវជនខ្មែរមានទំនោរខ្ពស់ទៅរកការប្រើប្រាស់បច្ចេកវិទ្យា ទូរស័ព្ទចល័ត និងសេវាអ៊ីនធឺណេត ដើម្បីសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃប៉ុន្តែផ្តោតលើគោលដៅបំពេញតម្រូវការកម្សាន្ត។

# ជំពូកទី៣

# រដ្ឋបាលសាធារណៈ

# នៅកម្ពុជាបច្ចុប្បន្ន

# ជំពូកទី៣

# រដ្ឋបាលសាធារណៈនៅកម្ពុជាបច្ចុប្បន្ន

## ៣.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅកម្ពុជា

រដ្ឋបាលសាធារណៈ ត្រូវប្រែក្លាយពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវាគួរជាទីគោរព និងមានភាពត្រឹមត្រូវក្នុងការបម្រើ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ តាមរយៈការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈកន្លងមក សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុវត្តដោយផ្អែកលើមូលដ្ឋានដែលមានស្រាប់ និងយុទ្ធសាស្ត្រកែទម្រង់រដ្ឋបាលសាធារណៈ ដែលត្រូវបានចង្អុលបង្ហាញដោយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤កន្លងមក។ ស្ថានភាពបច្ចុប្បន្នរបស់រដ្ឋបាលសាធារណៈកម្ពុជាដែលបានប្រសូត្រចេញពីកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤។

### ៣.១.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈ

បច្ចុប្បន្ន រចនាសម្ពន្ធរដ្ឋបាលសាធារណៈកម្ពុជាមានពីរកម្រិតគឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ចំណែកឯរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ក្រុង ខណ្ឌ និងរដ្ឋបាលឃុំ និងសង្កាត់។

រដ្ឋបាលរាជធានី ត្រូវបានបែងចែកជាខណ្ឌហើយរដ្ឋបាលខណ្ឌត្រូវបានបែងចែកជាសង្កាត់។

រដ្ឋបាលខេត្ត ត្រូវបានបែងចែកជាក្រុង និងស្រុក ហើយរដ្ឋបាលក្រុងត្រូវបានបែងចែកជាសង្កាត់ និងរដ្ឋបាលស្រុកត្រូវបានបែងចែកជាឃុំ និងសង្កាត់។

រដ្ឋបាលឃុំ សង្កាត់ត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។

រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សា និងគណៈអភិបាលនៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ចំណែកឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់ដែលតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោត

អសាកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតសាកលស្របតាមនីតិវិធី ដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

### ៣.១.២. ការគ្រប់គ្រងសេវារដ្ឋបាលសាធារណៈ

ពេលបច្ចុប្បន្ន សេវាសាធារណៈដែលមានលក្ខណៈជាសេវារដ្ឋបាលមួយចំនួនធំត្រូវបានប្រមូលផ្តុំផ្តល់ ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងសេវា សាធារណៈមួយចំនួនមិនទាន់ត្រូវបានផ្តល់ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅឡើយ។

អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយ ដែលជាយន្តការសម្រាប់ការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវារដ្ឋបាលចាំបាច់នានាដែលបាន ផ្ទេរពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជា ពលរដ្ឋ។ ហេតុនេះ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយជាទីកន្លែងដែលប្រជាពលរដ្ឋមកស្នើសុំ និង ទទួលឯកសារសំណុំបែបបទ និងព័ត៌មានពេញលេញពាក់ព័ន្ធនឹងប្រភេទសេវារដ្ឋបាលកម្រៃ និងពេលវេលានៃ ការផ្តល់សេវារដ្ឋបាល។ ស្របពេលជាមួយគ្នានេះ ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតឡើងដើម្បីទទួល ពាក្យបណ្តឹង និងផ្តល់ព័ត៌មានភាពមិនប្រក្រតី និងភាពខ្វះខាតប្រព្រឹត្តដោយបុគ្គលិកនៃរដ្ឋបាលពាក់ព័ន្ធចំពោះ អ្នកទទួលសេវាសាធារណៈ។ ក្រៅពីនេះ នៅមានសេវាសាធារណៈមួយចំនួនបាន និងកំពុងរៀបចំផ្ទេរតាមរយៈ យន្តការផ្ទេរមុខងារ និងធនធានពីបណ្តាក្រសួង ស្ថាប័ន ទៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋបាល ថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.១.៣. ការកែលម្អគុណភាពសេវាសាធារណៈ

ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិនឱ្យទទួលបានបៀវត្សគ្រប់ចំនួន មិនមានការកាត់កងទូទាត់ដោយហេតុផលណាមួយ និងបានទៀងទាត់ពេលវេលានៅសប្តាហ៍ទី២ និងទី៤នៃ ខែនីមួយៗ។ មន្ត្រីរាជការទទួលបានការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។ ការកាត់ពន្ធបៀវត្សប្រចាំខែរបស់ មន្ត្រីរាជការដែលអនុវត្តដោយដៃនៅតាមក្រសួងត្រូវបានជំនួសដោយការកាត់ពន្ធជាស្វ័យប្រវត្តិតាមរយៈប្រព័ន្ធ ទិន្នន័យ បៀវត្សរបស់ក្រសួងមុខងារសាធារណៈ។ នីតិវិធីនៃការពិនិត្យ និងផ្តល់ប្រាក់វិភាជន៍គ្រួសារត្រូវបានកែ

សម្រួលឱ្យសាមញ្ញ និងឆាប់រហ័ស ដោយអនុញ្ញាតផ្តល់ជូនប្រាក់វិភាជន៍គ្រួសារសម្រាប់កូនមន្ត្រីរាជការដល់អាយុ២១ឆ្នាំជាស្វ័យប្រវត្តិ (ពីមុនកូនលើសអាយុ១៥ឆ្នាំត្រូវមានលិខិតបញ្ជាក់ការសិក្សា១ឆ្នាំម្តង)។

### ៣.១.៤. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ចំពោះនិយ័តកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិព្រមទាំងប្តូរប្រភេទក្របខណ្ឌមន្ត្រីរាជការបានចំនួន ១០១០៦៣នាក់ត្រូវជា៩៩,១៤%នៃចំនួនមន្ត្រីរាជការដែលត្រូវធ្វើនិយ័តកម្មរបស់ក្រសួង ស្ថាប័នចំនួន៣២ (គិតត្រឹមថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤) និងដំឡើងថ្នាក់ និងឋានន្តរស័ក្តិជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៤មក។ រៀបចំកែសម្រួលលក្ខន្តិកៈ និងរចនាសម្ពន្ធសាលាភូមិន្ទរដ្ឋបាល ដើម្បីគាំទ្រដល់ការកសាងសមត្ថភាពមន្ត្រីរាជការឱ្យកាន់តែប្រសើរឡើងឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការងារ។ ធ្វើការសិក្សា និងវិភាគមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាលដើម្បីគាំទ្រដល់ការលើកកម្ពស់គុណភាពសេវាអប់រំ និងសុខាភិបាល។ ធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការ ដើម្បីគាំទ្រការបំពេញមុខងាររបស់ក្រសួង និងការបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីជាន់ខ្ពស់ មន្ត្រីគ្រប់គ្រងកម្រិតមធ្យម ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។ គោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ។ អនុក្រឹត្យ និងសេក្តីណែនាំស្តីពីនីតិវិធីនៃការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ អនុក្រឹត្យស្តីពីការគ្រប់គ្រង និងចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

### ៣.១.៥. ការកែទម្រង់ប្រព័ន្ធបៀវត្ស

សហការជាមួយក្រសួង ស្ថាប័ន ដើម្បីរៀបចំក្របខណ្ឌមន្ត្រីរាជការ ដំឡើងប្រាក់បំណាច់មុខងារ ដំឡើងប្រាក់បៀវត្សមូលដ្ឋាន និងផ្តល់ប្រាក់វិភាជន៍គ្រួសារក្នុងទិសដៅពង្រឹងប្រសិទ្ធភាពការងារ បង្កើនផលិតភាព និងបង្កើនបៀវត្សមន្ត្រីរាជការ។ បៀវត្សប្រចាំខែអប្បបរិមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធត្រូវបានរៀបចំដំឡើងបន្តបន្ទាប់ដល់ជាង១លានរៀលចាបពីឆ្នាំ២០១៨មក។ ប្រាក់បំណាច់មុខងាររបស់មន្ត្រីនគរបាលជាតិ យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីពន្ធនាគារត្រូវបានដំឡើងឱ្យមានសង្គតិភាពជាមួយនឹងមន្ត្រីរាជការស៊ីវិល។ ប្រាក់បំណាច់មុខងារប្រចាំខែសម្រាប់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី សមាជិករាជរដ្ឋាភិបាលត្រូវបានដំឡើង និងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីនៅតាមស្ថានតំណាងកម្ពុជានៅបរទេស បច្ច័យនិច្ចភត្តប្រចាំខែប្រគេនមន្ត្រីសង្ឃកំពុងបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ទីប្រឹក្សា ជំនួយការ ខុទ្ទកាល័យ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្មៀនឃុំ មេភូមិ អនុភូមិ និងសមាជិកភូមិ។ ការ

បើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិនឱ្យទទួលបានបៀវត្សគ្រប់ចំនួនមិនមានការកាត់កងដោយហេតុផលណាមួយ និងបានទៀងទាត់ពេលវេលានៅសប្តាហ៍ទី២ និងទី៤នៃខែនីមួយៗ។

ព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនខាងនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម ខាងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ទោះបីជាត្រូវប្រឈមនឹងសភាពការណ៍ប្រែប្រួលផ្នែកនយោបាយ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសាកល ការគំរាមចំពោះអធិបតេយ្យជាតិ និងបូរណភាពទឹកដី គ្រោះធម្មជាតិផ្ទួនៗ ការរីករាលដាលនៃជំងឺកូវីដ-១៩ និងតម្រូវការដោះស្រាយសំណូមពរថ្មីៗរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈយ៉ាងណាក៏ដោយ។ ក្នុងចំណោមសមិទ្ធផលធំៗចំនួន៤របស់រាជរដ្ឋាភិបាលកន្លងមក បានកត់សម្គាល់ឃើញថាការកែទម្រង់អភិបាលកិច្ចរួមមាន៖ ការអនុវត្តការការកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កែទម្រង់តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងកែទម្រង់ផ្សេងទៀតបានធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពដំឡើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធដល់កម្រិតជាង១លានរៀលក្នុងមួយខែនៅឆ្នាំ២០១៨បានទៀតទាត់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែ និងបើករៀងរាល់២សប្តាហ៍ម្តងចាប់ពីឆ្នាំ២០១៩មកព្រមទាំងបានលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ថ្នាក់ក្រោមជាតិ។ ក្នុងរយៈពេលខាងមុខ កម្ពុជានឹងប្រឈមជាមួយនិន្នាការវិវត្តធំៗមួយចំនួនទាំងក្នុង និងក្រៅប្រទេសដែលជាកត្តាសក្យានុម័តកំណត់បរិការណ៍ និងទិសដៅនៃដំណើរការអភិវឌ្ឍប្រទេសដែលអាចនឹងស្តែងឡើងជាបញ្ហាប្រឈមផង និងជាកាលានុវត្តផង។

## ៣.២. ការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាលឌីជីថលកម្ពុជាបច្ចុប្បន្ន

រដ្ឋាភិបាលកម្ពុជា កំពុងអភិវឌ្ឍន៍ខ្លួនឱ្យក្លាយទៅជារដ្ឋាភិបាលឌីជីថលមួយដើម្បីធ្វើការគ្រប់គ្រងសង្គមតាមប្រព័ន្ធបច្ចេកវិទ្យាកុំព្យូទ័រទំនើបៗធ្វើឱ្យមានតម្រូវការធនធានមនុស្សដែលមានជំនាញច្បាស់លាស់ ខណៈពេលដែលបច្ចុប្បន្នប្រទេសកម្ពុជាសម្បូរទៅដោយសាលារៀនគ្រប់កម្រិត និងផ្តល់ភាពងាយស្រួលនៅក្នុងការទទួលយកចំណេះដឹងដើម្បីទៅថ្ងៃមុខជាធនធានបន្តទៅលើវិស័យការងារជាច្រើនទៀត។[២២] មួយវិញទៀតប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលនៅកម្ពុជាកំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើម និងចូលរួមបានតិចតួចក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសាកលនៅឡើយ។ ទន្ទឹមនេះ រដ្ឋាភិបាលឌីជីថលដែលមានតួនាទីស្នូល និងដឹកមុខក្នុងដំណើរការបរិវត្តកម្មឌីជីថលក៏ហាក់មិនទាន់រៀបចំខ្លួនឱ្យបានពេញលេញ និងស៊ីជម្រៅ។

[២២] គេហទំព័រ https://opendevelopmentcambodia.net/km/topics/science-and-technology/ ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៤។

តាមស្ថានភាពនាបច្ចុប្បន្ន នៅអំឡុងពេលការកកើតឡើងនៃជំងឺរីករាលដាលអំពីកូវីដ-១៩ បានធ្វើឱ្យប្រទេសកម្ពុជាមិនអាចចេញចូល ឬធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ ឬជួបទល់មុខបានឡើយ។ មិនថាត្រឹមតែប្រទេសយើងប៉ុណ្ណោះទេប្រទេសជិតខាង និងប្រទេសឆ្ងាយទាំងឡាយបានជួបនៅឧបសគ្គដូចៗគ្នាក្នុងការរៀបចំផែនការសម្រាប់ការធ្វើដំណើរមិនថាតែការណាត់ជួប ការធ្វើដំណើរផ្លាស់ប្តូរពីកន្លែងមួយទៅទីកន្លែងមួយទៀតដោយងាយស្រួលដូចពីមុនការផ្ទុះនៃវីរុស។ ដើម្បីជាជំនួយដល់ការពិភាក្សាគម្រោងការនានាបន្តគេអាចជួបតាមរយៈប្រព័ន្ធអេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិទ្យាដោយជួបតាមរយៈឧបករណ៍កម្មវិធីផ្សេងៗដូចជា Google Meet, Zoom, Hangouts, ដែលអាចប្រើប្រាស់ជាមួយការជួប ឬនិយាយពិភាក្សាតាមរយៈ Email, Telegram និង Video Call ជាដើម។ ប្រសិនបើ យោងតាមផែនការមេគ្រប់គ្រងលើវិស័យបច្ចេកវិទ្យាគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមប្រទេសជាតិយើង។ អាស្រ័យហេតុនេះ ទើបមានការផ្តោតសំខាន់ទៅលើធនធានមនុស្សក្នុងការជួយបណ្តុះបណ្តាល និងលើកកម្ពស់អក្ខរកម្មឌីជីថល (រួមទាំងការរាប់បញ្ចូលទៅតាមអ្នករស់នៅជនបទ)។ បន្ទាប់មក លទ្ធភាពក្នុងការប្រើប្រាស់កុំព្យូទ័ររបស់មន្ត្រីរាជរដ្ឋាភិបាលបានពង្រឹងបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធខាងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត។ តាមរយៈប្រព័ន្ធសន្និសីទក្រសួងមហាផ្ទៃបើកកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីពិភាក្សានិងប្រមូលធាតុចូលលើសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០ ដែលដឹកនាំដោយសហប្រធានពីររូប គឺរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងក្រុមការងារពាក់ព័ន្ធ ក្រសួងមហាផ្ទៃព្រមទាំងមន្ត្រីជំនាញមួយចំនួនទៀតផងដែរ។ ចំពោះសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០ ក្នុងគោលបំណងលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈកាន់តែប្រសើរ ដោយបានដាក់ចេញនូវវិធានការគោលនយោបាយអាទិភាពក្រោមក្របខណ្ឌយុទ្ធសាស្ត្រចំនួន៥រួមមាន៖ ទី១. បទដ្ឋានគតិយុត្តរដ្ឋាភិបាលឌីជីថល ទី២. ហេដ្ឋារចនាសម្ពន្ធឌីជីថល ទី៣. សេវារដ្ឋាភិបាលឌីជីថល ទី៤. ការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល និងទី៥.ភាពជាដៃគូរវាងរដ្ឋ និងឯកជន។

គួរបញ្ជាក់ថា បច្ចុប្បន្នការវិវត្តនៃរដ្ឋាភិបាលឌីជីថលកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយដោយហេតុថាឌីជីថលលូបនីយកម្មតាមក្រសួង ស្ថាប័ន មិនមានការប្រមូលផ្តុំភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្របសម្រួលដល់ការងារដោយគ្មានយុទ្ធសាស្ត្រ សម្រាប់ការផ្លាស់ប្តូរទៅឌីជីថលរយៈពេលវែង ការគិតគូរជាសំខាន់ពីប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដែលអាចកើតចេញពីទិន្នន័យប្រមូលផ្តុំបាន។[២៣]

[២៣] គេហទំព័រ https://www.interior.gov.kh/news/detail/២៣៤៧ ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៤។

### ៣.២.១. របៀបរបបនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង ស្ថាប័ន

ដំណើរការប្រព្រឹត្តនៃក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធបច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងតែអនុវត្ត និងបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ក្នុងនីតិកាលទី៦នៃរដ្ឋសភាដោយឈរលើក្របខណ្ឌគោលនយោបាយ និងបានផ្តល់ការឆ្លើយតបដល់ការធ្វើបដិវត្តន៍ឧស្សាហកម្ម៤.០ដើម្បីទទួលបានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងនោះដែរមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងបានអនុវត្តន៍ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ទើបនាំឱ្យមានការផ្តល់សេវាសាធារណៈតាមបែបឌីជីថលនេះឡើង ដូចជាការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានការចូលរួមសហការជាមួយនឹងក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនតែប៉ុណ្ណោះនៅមានការចូលរួមសហការដោយក្រសួងមួយចំនួនទៀតនៅថ្ងៃអនាគត។

ខាងក្រោមនេះ គឺជារបៀបនៃការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង ស្ថាប័នដែលពាក់ព័ន្ធនីមួយៗដូចតទៅ៖

#### ៣.២.១.១. ក្រសួងពាណិជ្ជកម្ម

#### ក. ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលធ្វើតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបអនឡាញទាំងស្រុងគឺជានីតិវិធីថ្មីក្នុងការបង្កើតអាជីវកម្មរបស់សហគ្រាសតូច ធំ រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានលក្ខណៈបង្រួបបង្រួមនៅក្នុងការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់អាជីវកម្ម ជៀសវាងការបង្កើតអាជីវកម្មខុសច្បាប់ដែលត្រូវទទួលការផាកពិន័យរហូតឈានទៅដល់ការផ្អាកដំណើរការ ឬបិទទ្វារអាជីវកម្មផ្ទុយនឹងនេះការចុះបញ្ជីអាជីវកម្មស្របតាមនីតិវិធីរបស់រដ្ឋាភិបាលគឺទទួលបានការគាំពារតាមផ្លូវច្បាប់ មិនតែប៉ុណ្ណោះអ្នកដែលបានចុះបញ្ជីអាជីវកម្ម គឺទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀតពីបេឡាសន្តិសុខសង្គម។ ចំពោះការចុះបញ្ជីអាជីវកម្មតាមថ្នាលឌីជីថលដែលជាបរិបទថ្មីនេះអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅលើថ្នាលបច្ចេកវិទ្យាព័ត៌មានតែមួយដោយឡែកក្នុងដំណាក់កាលដំបូងនេះការចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង ស្ថាប័នដទៃក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលតម្រូវឱ្យអ្នកធ្វើតាមនីតិវិធីដដែលរបស់ក្រសួងស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំយ៉ាងយូរ៨ថ្ងៃនៃថ្ងៃធ្វើការលុបបំបាត់ការបំពេញឯកសារដដែលៗ ចំណាយថវិកាតិចជាងមុនច្រើន ទូទាត់

ថ្លៃសេវាទាំងអស់ក្នុងការចុះបញ្ជីអាជីវកម្មក្នុងពេលតែមួយតាមអនឡាញទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធខណៈពេលដែលតម្លៃសេវាថោកជាងមុន។

បច្ចុប្បន្ននេះ ធុរជនត្រូវប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើមដើម្បីអាចបង្កើតគណនីនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។[២៤] ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការចុះបញ្ជីអាជីវកម្មយន្តការថ្មីត្រូវធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយ ដែលត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២០ហើយវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ផ្សេងៗត្រូវចេញជាទម្រង់ឌីជីថលដែលធុរជនអាចបោះពុម្ព (Print) ដោយខ្លួនឯង និងយកទៅប្រើប្រាស់ជាផ្លូវការបានដោយមិនបាច់តម្រូវឱ្យយកឯកសារដែលមានត្រាច្បាប់ដើមដូចមុនទៀតទេ។ វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ផ្សេងៗក្នុងទម្រង់ឌីជីថលអាចបញ្ជាក់ពីភាពត្រឹមត្រូវបានតាមរយៈលេខសម្គាល់សហគ្រាសដែលអាចផ្ទៀងផ្ទាត់បានលើគេហទំព័រចុះបញ្ជីពាណិជ្ជកម្ម។

**ខ. សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក**

❖ **ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួង ឬស្ថាប័នរដ្ឋអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាព និងប្រតិបត្តិការដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវសម្រាប់បង្កើត ឬរក្សាទុកឯកសារ

ខ. ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត

គ. ការកំណត់មធ្យោបាយ និងរបៀបក្នុងការទូទាត់ប្រាក់ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែលក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើក្រសួង ឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀប និងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី ការបង្កើតរក្សាទុក ឬការបោះផ្សាយ

[24] សេចក្តីជូនដំណឹងរបស់ធនាគារជាតិ លេខ ធ៧.០២០.៥៦៩ ស.ជ.ណ ចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ខ. ប្រភេទនៃហត្ថលេខា ដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ

គ. របៀប និងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក

ឃ. ដំណើរការគ្រប់គ្រង និងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់

ង. លក្ខខណ្ឌកំណត់ផ្សេងៗទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិកជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។[25]

### ៣.២.១.២. អគ្គនាយកដ្ឋានពន្ធដារ

### ក. សេវាកម្មអេឡិចត្រូនិកពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ បានបែងចែកជាបីកម្មវិធីដើម្បីបម្រើដល់ការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនោះ គឺកម្មវិធីលើគេហទំព័រ (Web App) មានដូចជា៖

- ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income-ToI E-Filing) [២៦]
- ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing For Web Application)
- ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ (Tax Certificate Management System)
- ប្រព័ន្ធគ្រប់គ្រងពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិយានជំនិះតាមអនឡាញ (Online Tax on Vehicle Transfering System)
- បង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)[២៧]
- ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ (Tax learning Management System)
- ស្នើរសុំជៀសវាងការយកពន្ធត្រួតគ្នា DTA (DTA System)[២៨]
- ការស្នើសុំការលើកទឹកចិត្ត (Tax Incentive)

[២៥] ច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩, មាត្រា៣៤។

[២៦] ToI E-Filing = Tax on Income Electronic Filing.

[២៧] E-Payment = Electronic Payment.

[២៨] DTA System = Double Tax Agreement System.

- កម្មវិធី បញ្ជូនឯកសារអេឡិចត្រូនិក (e-Document Submission System)[២៩]
- ស្នើសុំបង្វិលសងតប (E-Vat)[៣០]។

### ខ. កម្មវិធីទូរស័ព្ទ

កម្មវិធីទូរស័ព្ទមានដូចជា៖

- កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT[៣១] Tax Prefilling App)
- កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)
- កម្មវិធីគណនាពន្ធមធ្យោបាយ (Cambodia Road Tax)
- កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track)
- កម្មវិធីប្រតិទិនពន្ធដារ (Cambodia Tax Calendar)
- កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat)
- កម្មវិធីព័ត៌មានស្តីពីពន្ធដារ (GDT News)
- កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax)។

### គ. កម្មវិធីលើកុំព្យូទ័រ (Desktop App)

- **របៀបនៃការបង់ពន្ធតាមអនឡាញ (E-Payment)**

ជាដំបូងចុចចូលទៅគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ហើយចុចលើសេវាអេឡិចត្រូនិកពន្ធដាររួចចុចលើ icon បង់ប្រាក់ពន្ធតាមអនឡាញ (ប្រសិនបើលោកអ្នកមិនទាន់មានគណនីទេអាចបង្កើតគណនីថ្មីមួយដើម្បីធ្វើការ Log in ដើម្បីចូលទៅកាន់កម្មវិធីនោះដោយគ្រាន់តែបំពេញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលឱ្យត្រឹមត្រូវ និងគ្រប់គ្រាន់ជាការស្រេច)។ ក្នុងកម្មវិធីនេះ បានផ្តល់នូវភាពងាយស្រួលដល់អ្នកប្រើប្រាស់ដោយអាចជ្រើសរើសប្រភេទនៃពន្ធដែលយើងចង់បង់ ព្រមទាំងមានធនាគារជាច្រើនដែលជាជម្រើសក្នុងការបង់ពន្ធរបស់អ្នកជាប់ពន្ធ។ នៅពេលដែលអ្នកបានបញ្ចូលលេខគណនីចូលរួចហើយនោះ ប្រព័ន្ធនឹងលោតបញ្ចូលលេខគណនីរបស់អ្នកក្នុងព័ត៌មានបង់ពន្ធ និងប្រកាសពន្ធដោយស្វ័យប្រវត្តិបើពិនិត្យឃើញថាត្រឹមត្រូវហើយនោះចុចត្រួតពិនិត្យប្រព័ន្ធនឹងបង្ហាញពាក្យស្នើសុំបង់ពន្ធ និងបង្ហាញធនាគារដែលអ្នកបានជ្រើសរើស

[២៩] E-Document Submission System = Electronic Document Submission System.

[៣០] E-vat = Expanded Value Added Tax.

[៣១] GDT = General Department of Taxation.

រួចបញ្ចូលនូវលេខគណនី និងព័ត៌មានគណនីរបស់អ្នកហើយប្រព័ន្ធនឹងបង្ហាញពាក្យ Verify ដើម្បីបញ្ជាក់ម្តងទៀតរួចប្រព័ន្ធនឹងបង្ហាញបង្កាន់ដៃអេឡិចត្រូនិកបញ្ជាក់ការបង់ប្រាក់ពន្ធជាការស្រេច។

**៣.២.១.៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមាននូវគេហទំព័ររបស់ក្រសួងផ្ទាល់សម្រាប់ការផ្តល់ព័ត៌មានក៏ដូចជាសេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងវិស័យការងារ និងការបណ្តុះបណ្តាល។ ដោយក្នុងនោះដែរមានការបែងចែកចំពោះការផ្តល់សេវាពាក់ព័ន្ធវិស័យការងារ សេវាពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈព្រមទាំងសេវាពាក់ព័ន្ធជនបរទេស។[32]

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ នៅក្នុងគោលបំណងដាក់ឱ្យដំណើរការការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពព្រមទាំងស្របតាមសំណើរបស់វិស័យឯកជននៅក្នុងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន។

**៣.២.១.៤. ក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យរដ្ឋបាលដឹកនាំគ្រប់គ្រងនគរបាលជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូនប្រជាពលរដ្ឋខ្មែរ។

ក្រសួងមហាផ្ទៃ បានចេញសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្រសួងមហាផ្ទៃដោយមានរដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃជាប្រធាន និងមានសមាសភាពជាអនុប្រធាន២រូបព្រមទាំងសមាជិក១២រូប។ សម្រាប់ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននេះផងដែរមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលត្រូវដឹកនាំដោយនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

### ៣.២.២. ការចាត់វិធានការទប់ស្កាត់នូវជំងឺកូវីដ-១៩តាមរយៈប្រព័ន្ធបច្ចេកវិទ្យា

រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានភ្លាមៗអំពីការទប់ស្កាត់នូវការបង្កឡើងពីជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលខ្លាំងរហូតមកដល់បច្ចុប្បន្ន។ ការចាត់វិធានការនេះ គឺសំដៅលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាលើការផ្សព្វផ្សាយ ការប្រកាសតាមបណ្តាញប្រព័ន្ធអ៊ីនធឺណេតអំពីការទប់ស្កាត់ក្នុងការកើនឡើងនៃជំងឺ គ្រប់កន្លែងធ្វើការក្រសួង ស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន សាកលវិទ្យាល័យ សាលារៀនរដ្ឋ សាលារៀនឯកជន កន្លែងទីប្រជុំ

[32] គេហទំព័រ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៤។

ជន (មានមនុស្សច្រើនធ្វើឱ្យមានហានិភ័យខ្ពស់) កន្លែងបោះដុំអីវ៉ាន់ធំៗ ផ្សារទំនើប (កន្លែងមានម៉ាស៊ីនត្រជាក់ច្រើនក៏អាចងាយនឹងឆ្លងរហ័ស) និងបណ្តាហាងនានា (ភោជនីយដ្ឋានជាដើម)។ ការជួយពីប្រជាពលរដ្ឋក្នុងការទប់ស្កាត់បន្ថែមជៀសវាងការជួបជុំផ្ទាល់ជាមួយមនុស្សច្រើននៅទីកន្លែងណាមួយ គឺត្រូវមកទាក់ទងគ្នាតាមបណ្តាញប្រព័ន្ធអេឡិចត្រូនិកដូចជាការប្រើប្រាស់ទូរស័ព្ទ (ចុច Call ឬVideo Call សម្រាប់ទំនាក់ទនង) ប្រព័ន្ធអ៊ីនធឺណេតប្រើប្រាស់ដោយកុំព្យូទ័រអាចប្រើបានជាមួយបណ្តាល Email, Message, Facebook, Telegram, Line, និងApps ជាច្រើនទៀតផងដែរ។ ការដឹកជញ្ជូន ឬមានការបញ្ជាទិញអីវ៉ាន់ពីអតិថិជន យើងអាចមកផ្លាស់ប្តូរឱ្យក្រុមហ៊ុនដឹកជញ្ជូនមកទទួល និងយកទៅឱ្យអ្នកទិញផ្ទាល់បានតាមរយៈបណ្តាញទាក់ទងអ៊ីនធឺណេត ឬប្រើ App ដែលយើងបានចុះឈ្មោះសម្រាប់ការដាក់កុម្ម៉ង់ ឬឱ្យដឹកជញ្ជូនដោយមិនចាំបាច់ចេញពីកន្លែងស្នាក់នៅ។

**៣.២.២.១. ក្រសួង ស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជន**

ការប្រកាសឱ្យបុគ្គលិកទាំងធ្វើការបម្រើរដ្ឋ និងបម្រើវិស័យឯកជនចាប់ផ្តើមអនុវត្តន៍វិធានការទប់ស្កាត់លើបរិបទជំងឺកូវីដ-១៩បន្តការផ្ទុះឡើង។ ការប្រកាសឱ្យមានការកាត់បន្ថយចំនួនបុគ្គលិកនៅក្នុងកន្លែងធ្វើការស្ថិតក្នុងការិយាល័យឱ្យមានចំនួនតិចជាងមុន (កាត់បន្ថយពាក់កណ្តាល ឬច្រើនជាងនឹង) មូលហេតុចង់ឱ្យមានការរក្សាគម្លាតពីគ្នា និងអាចថែរក្សាសុខភាពបានខ្ពស់។ កន្លែងធ្វើការក្រុមហ៊ុនឯកជនត្រូវមានការប្រុងប្រយ័ត្នប្រសិនជាអាចឱ្យបុគ្គលិកធ្វើការពីផ្ទះដោយអនឡាញបានត្រូវមានការអនុញ្ញាត និងប្រសិនបើក្រុមហ៊ុនមិនអាចខ្វះអ្នកប្រចាំការបាននៅកន្លែងធ្វើការត្រូវមានការផ្លាស់វេនរវាងបុគ្គលិកដូចជាខាងរដ្ឋបាលជាដើម។

**៣.២.២.២. ក្រសួងសុខាភិបាល**

ក្រសួងសុខាភិបាល បានប្រកាសដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យា QR Code "ទប់ស្កាត់កូវីដ-១៩ Stop Covid-19"។ សេចក្តីប្រកាសនេះផ្អែកលើការឆ្លងរីករាលដាលនៃជំងឺនេះត្រូវមានយុទ្ធសាស្ត្រក្នុងការទប់ស្កាត់បន្ថែមគណៈកម្មាធិការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានជម្រាបឱ្យបានដឹងថាការបង្កើនប្រសិទ្ធភាពការបង្ការ និងទប់ស្កាត់ជៀសវាងហានិភ័យនៃការរីករាលដាលពីស្ថានភាពជំងឺCovid-19 ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានដាក់ឱ្យប្រើប្រាស់ QR Code ពេលចេញចូលទៅតាមទីកន្លែងណាមួយ ដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន កន្លែងកម្សាន្ត អគារស្នាក់នៅរួម ខុនដូ ក្រុមហ៊ុន រោងចក្រ សហគ្រាសដែលជាទីតាំងមានមនុស្សចេញចូលច្រើន ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតាមដានការ Scan ព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យា QR Code បានលឿនហើយងាយគ្រប់គ្រងបានពីទីតាំងដែលប្រជាពលរដ្ឋបានទៅ។

ក្នុងករណីនេះ ប្រសិនជាមានករណីផ្ទុះកូវីដ-១៩ កើតឡើងនៅកន្លែងណាមួយផ្តល់ភាពងាយស្រួលអំពីទិន្នន័យព័ត៌មានដែលបានរក្សាក្នុងប្រព័ន្ធបច្ចេកវិទ្យា។

#### ៣.២.២.៣. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការសម្រាប់ការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាដើម្បីដោះស្រាយបញ្ហាក្នុងការសិក្សាស្របពេលនៃការផ្ទុះឡើងជំងឺកូវីដ-១៩ និងដើម្បីបង្កើនសមត្ថភាពសម្រាប់ការអប់រំនៅពេលអនាគត។ ជាលើកដំបូងបង្អស់ដែលកម្មវិធីសិក្សានៅទូទាំងកម្ពុជាត្រូវបានផ្លាស់ប្តូរពីការសិក្សានៅតាមសាលារៀនផ្ទាល់មកជាការសិក្សាតាមប្រព័ន្ធអនឡាញ (Online) ទាំងស្រុងដោយក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីសិក្សាពីចម្ងាយសម្រាប់ចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សាដើម្បីបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩។ លើសពីនេះទៅទៀត ក្រសួងក៏បានរៀបចំរួចជាស្រេចនូវទស្សនវិស័យសំខាន់ៗដើម្បីពង្រឹងប្រព័ន្ធអប់រំតាមបែបឌីជីថល (Digital) នៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើងសម្រាប់ពេលខាងមុខ។ ជាទូទៅ ក្រសួងអប់រំ យុវជន និងកីឡា សង្កេតឃើញថាមាតាបិតាសិស្សានុសិស្ស និងគ្រប់ភាគីពាក់ព័ន្ធបានស្វាគមន៍គាំទ្រសេវាសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡាជាពិសេសជាមួយនឹងការផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាអ៊ីនធឺណេត (Zoom, Loom, Microsoft Team, Google Classroom, Email, និងTelegram ជាដើម) តាមរយៈទូរទស្សន៍ដែលអាចបន្តឱ្យមានការរៀន និងបង្រៀននៅទីក្រុង និងជនបទទូទាំង២៥រាជធានី ខេត្តក្នុងឱកាសចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។

### ៣.៣. លទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល

ការបញ្ជ្រាបការយល់ដឹង និងជំនាញឌីជីថលទៅដល់អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋានក៏មានភាពប្រសើរឡើងជាលំដាប់។ នៅក្នុងវិស័យឯកជន ការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យ៉ាងណាមិញ ការផ្លាស់ប្តូរទៅរកភាពជាអ្នកដឹកនាំឌីជីថលដែលឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថល។ ការទាក់ទាញធនធានមនុស្សមានទេពកោសល្យឌីជីថល។ ធនធានប្រភេទនេះ គឺជាតួអង្គដ៏សំខាន់នៅក្នុងការដែលបរិការណ៍នៃបរិវត្តកម្មឌីជីថលដែលចូលរួមធានាបាននូវការបង្កើតថ្មី និងនវានុវត្តន៍រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធ ICT និងការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល។

បច្ចេកវិទ្យាឌីជីថលក្នុងការងារសាធារណៈរបស់ស្ថាប័នរដ្ឋ និងមន្ត្រីរាជការនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជាកម្រិតនៃការយល់ដឹងខុសគ្នា និងការព្រួយបារម្ភចំពោះកត្តាសន្តិសុខព័ត៌មាន និងសុវត្ថិភាពទិន្នន័យ។

នៅក្នុងន័យនេះការគិតគូរសម្រាប់ទិសដៅអនាគត ការអភិវឌ្ឍរដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល និងផ្តោតទៅលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុង រួមទាំងនីតិវិធីនៃការអនុវត្តការងារផ្តល់សេវា

តាមប្រព័ន្ធអេឡិចត្រូនិក និងការផ្តល់ព័ត៌មាននានា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ការលើកកម្ពស់ការយល់ដឹង និងជំនាញឌីជីថលដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់រួមទាំងនៅថ្នាក់មូលដ្ឋាន។

ការអនុវត្តឌីជីថល ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់មុខងារស្នូលរបស់ស្ថាប័នរដ្ឋ និងសេវាសាធារណៈពុំគ្រប់គ្រាន់សម្រាប់ប្រែក្លាយជារដ្ឋាភិបាលឌីជីថលពេញលេញឡើយ ព្រោះប្រព័ន្ធទាំងនេះត្រូវការថ្នាលបច្ចេកវិទ្យាមូលដ្ឋាន និងបទប្បញ្ញត្តិមួយចំនួនសម្រាប់គាំទ្រដែលខ្វះខាតនៅឡើយ។ ថ្នាលបច្ចេកវិទ្យាមូលដ្ឋានទាំងនោះមានដូចជាបច្ចេកវិទ្យាភ្លោះលើមជ្ឈមណ្ឌលទិន្នន័យរួមរបស់រាជរដ្ឋាភិបាល ថ្នាលផ្លាស់ប្តូរ ទិន្នន័យសម្រាប់អន្តរប្រតិបត្តិការ និងសន្ទានកម្ម អត្តសញ្ញាណឌីជីថល និងប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន។[៣៣]

### ៣.៣.១. ការកែលម្អគុណភាពសេវាសាធារណៈ

បណ្តាក្រសួង និងស្ថាប័នរដ្ឋមួយចំនួនបាននឹងកំពុងដំណើរការរដ្ឋបាល ICT និងគម្រោងឌីជីថលក្នុងនោះរួមមានការចុះបញ្ជីឌីជីថលសម្រាប់កម្មសិទ្ធិដីធ្លី ការចុះបញ្ជីយានយន្ត និងពន្ធដារជាដើម។ ជាមួយគ្នានេះការគ្រប់គ្រងចំណូលរបស់អង្គភាពប្រមូលចំណូលរដ្ឋក៏កំពុងតភ្ជាប់នឹងឌីជីថលជាជំហានៗ ជាពិសេសការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធប្រកាសពន្ធអនឡាញ (E-Filing) និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម និងឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញ (Online VAT Refund and Online VAT Credit) និងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) និងថ្មីៗនេះការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា (Online Business Registration) ជាដើម។

ការកើនឡើងនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងរដ្ឋាភិបាលឌីជីថលជាសញ្ញាមួយល្អ ក៏ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវគិតគូរដើម្បីអាចឈានទៅរករដ្ឋាភិបាលឌីជីថលពេញលេញមួយ។ បើទោះបីជាមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក៏ដោយក៏ស្ថាប័នរដ្ឋភាគច្រើននៅតម្រូវឱ្យផ្តល់ឯកសារ ឬព័ត៌មានដដែលៗដោយសារពុំមានការចែករំលែករវាងស្ថាប័នពាក់ព័ន្ធមួយចំនួន ស្របពេលដែលការដាក់ឯកសារនៅតម្រូវក្នុងទម្រង់ជាក្រដាសស្នាម និងការទទួលយកតាមប្រព័ន្ធអេឡិចត្រូនិកនៅមានតិចតួចនៅឡើយ។

### ៣.៣.២. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល គឺជានិន្នាការថ្មីមួយដែលទាមទារឱ្យអ្នកដឹកនាំបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យាដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មីផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការធ្វើអភិបាលកិច្ចការប្រាស្រ័យទាក់ទងការសម្រេចចិត្ត ឬការ

[៣៣] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥, ទំព័រទី១៣៥។

ដោះស្រាយបញ្ហានានា។ រាជរដ្ឋាភិបាលបានបង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួនតាមរយៈការគិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានាសំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលដែលរួមមានជាអាទិ៍ការធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ ការដាក់ចេញនូវផែនការមេ និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន។ ទន្ទឹមនេះការយល់ដឹង និងជំនាញឌីជីថលទៅដល់អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋានក៏មានភាពប្រសើរឡើងជាលំដាប់។ នៅក្នុងវិស័យឯកជនការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យ៉ាងណាមិញ ការផ្លាស់ប្តូរទៅរកភាពជាអ្នកដឹកនាំឌីជីថលដែលឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា គឺចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងនៅក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថល។

នាពេលបច្ចុប្បន្ននេះ ការទទួលយកឌីជីថលក្នុងចំណោមអ្នកដឹកនាំទាំងផ្នែកវិស័យសាធារណៈ និងវិស័យឯកជនមានវឌ្ឍនភាពជាវិជ្ជមាន។ រាជរដ្ឋាភិបាលបាន បង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួនតាមរយៈការគិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានាសំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលដែលរួមមានជាអាទិ៍ការធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ ការដាក់ចេញនូវផែនការមេ និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍។

# ជំពូកទី៤

# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៤

# បញ្ហាប្រឈម និងដំណោះស្រាយ

## ៤.១. បញ្ហាប្រឈម និងទិសដៅការងារបន្ទាប់

ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈបញ្ហាប្រឈមសំខាន់ៗមួយចំនួនក្នុងរដ្ឋបាលសាធារណៈដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងដោះស្រាយមាននីតិវិធីមួយចំនួនក្នុងការផ្តល់សេវាសាធារណៈនៅមានភាពស្មុគស្មាញ ប្រមូលផ្តុំ ការិយាធិបតេយ្យ។ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈនៅមានកម្រិតហើយការដាក់ឱ្យអនុវត្តមួយចំនួនមានលក្ខណៈដាច់ដោយដុំ មិនមានលក្ខណៈជាប្រព័ន្ធ។ លំហូរការងារ និងទំនាក់ទំនងផ្ទៃក្នុងក្រសួង ស្ថាប័ន និងរវាងក្រសួង ស្ថាប័ន និងក្រសួង ស្ថាប័ននៅមិនទាន់ដំណើរការជាបណ្តាញតភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានភាពរលូននៅឡើយ។ សេវាសាធារណៈមិនទាន់ទទួលបានទំនុកចិត្តពេញលេញពីសាធារណជន។ ក្របខណ្ឌបទដ្ឋានលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការផ្តល់សេវាសាធារណៈមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងប្រសិទ្ធភាព។ យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសាធារណៈមិនទាន់បានដាក់ឱ្យដំណើរការប្រកងដោយប្រសិទ្ធភាព។ ចំពោះការគ្រប់គ្រង និងការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការមិនទាន់ត្រូវបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងមិនទាន់មានការរៀបចំការពិពណ៌នាអំពីមុខតំណែងឱ្យបានច្បាស់លាស់នៅឡើយ។ សកម្មភាពអនុវត្តការងារជាប្រចាំមិនស្របជាមួយនឹងគោលដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ សមត្ថភាពធនធានមនុស្ស និងស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ បញ្ហាប្រឈមនៅក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.០។ ការជំរុញឱ្យមានការប្រកួតប្រជែងនៅកម្ពុជាដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតមានឡើង និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដំណាក់កាលនៃការអភិវឌ្ឍថ្មី។ ការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅពុំទាន់ឆ្លើយតប គណនេយ្យភាព និងតម្លាភាពស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបណ្តាលមកពីការដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅរក្សាទម្លាប់ចាស់ គឺពុំទាន់ឆ្លើយតបទៅនឹងបរិបទថ្មីព្រមទាំងការបម្រើសេវាសាធារណៈនៅមានកម្រិតពុំទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតនៅឡើយ។ រចនាសម្ព័ន្ធ របៀបរបបការងារនៅពុំទាន់មានប្រសិទ្ធភាព រចនាសម្ព័ន្ធ និងរបៀបរបបការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងតាមការណែនាំនៃលិខិតបទដ្ឋានពាក់ព័ន្ធក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានការឆក់ល្វែងមួយចំនួនដែលបណ្តាឱ្យដំណើរការការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌហាក់ពុំទាន់ភាពរលូនតាមការចង់បាន។ បញ្ហាកង្វះមន្ត្រី និងបុគ្គលិកនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការមកបំពេញ

ការងារពេញលេញជាប្រចាំ សមត្ថភាពរបស់មន្ត្រីក៏នៅមានកម្រិតដោយសារពុំទាន់ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញសមស្របនៅឡើយដោយមិនទាន់និយាយដល់កង្វះការតាំងចិត្ត និងឆន្ទៈរបស់មន្ត្រីមួយចំនួនដែលអាចបណ្តាលមកពីខ្វះការលើកទឹកចិត្តទាំងផ្នែកស្មារតី។ បញ្ហាប្រឈមពាក់ព័ន្ធថវិកាក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ចំណូលភាគច្រើនបំផុតរបស់រដ្ឋបាលក្រុង ស្រុក បានមកពីមូលនិធិក្រុង ស្រុកដែលជាថវិកាផ្ទេរពីថ្នាក់ជាតិសម្រាប់ប្រតិបត្តិការការងារ និងការអភិវឌ្ឍនៅមូលដ្ឋានក្រុង ស្រុកដែលនៅមានកម្រិតតិចតួច និងពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាននៅឡើយ ដោយឡែកចំណូលនៅមូលដ្ឋានដែលអាចរួមមានពន្ធមូលដ្ឋាន និង/ឬកម្រៃសេវាជាដើមនៅមានកម្រិតតិចតួចណាស់។

កាលានុវត្តភាពរបស់កម្ពុជាដើម្បីធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ និងកំណត់ទុកការងារកែទម្រង់ជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗឆ្ពោះទៅរកអភិវឌ្ឍនភាព និងវិបុលភាពក្នុងស្មារតីនេះរាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមរៀបចំនិងដាក់ឱ្យអនុវត្តការងារកែទម្រង់ជាច្រើនក្នុងវិស័យសាធារណៈ ជាពិសេសកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បរិការណ៍កែទម្រង់រដ្ឋបាលសាធារណៈរបស់យើងបានចង្អុលប្រាប់យ៉ាងជាក់ប្រាកដថាការងារកែទម្រង់នេះ គឺជាមាគ៌ាដ៏ត្រឹមត្រូវតែមួយគត់ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចជ្រើសរើសយកមកប្រតិបត្តិយ៉ាងគត់មត់ និងម៉ឺងម៉ាត់ក្លៀវក្លាតាមទស្សនវិស័យដ៏ប្រាកដនិយម **គឺកែទម្រង់ គឺរស់មិនកែទម្រង់គឺស្លាប់។** ហេតុនេះ យើងពិតជាគ្មានជម្រើសអ្វីផ្សេងក្រៅពីការខិតខំពុះពារជម្នះការលំបាក និងឧបសគ្គសព្វសារពើដើម្បីអភិវឌ្ឍសមត្ថភាពដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយបំពាក់ជាប់ជានិច្ចនូវស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ចំពោះគោលដៅកែទម្រង់ដែលបានកំណត់ប្រកបដោយសតិសម្បជញ្ញៈនៃលក្ខណៈបន្ទាន់ មហិច្ឆតា និងប្រាកដនិយមនៃការកែទម្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជាយើង ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋកម្ពុជាបច្ចុប្បន្នគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ប៉ុន្តែនៅក្នុងកម្រិតវិស័យ និងកម្រិតក្រសួង ស្ថាប័ន មានសេចក្តីត្រូវការកែលម្អ និងពង្រឹងបន្ថែមទៀតនូវការកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីធានាសង្គតិភាពទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមរបស់រាជរដ្ឋាភិបាលផងក៏ដូចជាដើម្បីធានាភាពត្រឹមត្រូវ ភាពច្បាស់លាស់ និងភាពអាចវាស់វែងបាននូវលទ្ធផលឬសមិទ្ធកម្មបានផង។ តាមរយៈបរិការណ៍សាកល និងក្នុងប្រទេសព្រមទាំងកម្មវិធីជាតិ និងគោលនយោបាយជាតិជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ បានផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពសំខាន់ៗដូចតទៅ ការ

រីកចម្រើនផ្នែកបច្ចេកវិទ្យាក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទី៤.០នេះ បានធ្វើឱ្យអនុវត្តការងារ ឬទំនាក់ទំនងគ្នាបានកាន់តែប្រសើរឡើងក្នុងខណៈដែលប្រទេសកម្ពុជាមានអត្រាអ្នកប្រើប្រាស់ទូរស័ព្ទ កំព្យូទ័រ និងអ៊ីនធឺណិតខ្ពស់។ ដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ បាននឹងកំពុងរីករាលដាលនៅលើសកលលោកផងនោះបានជំរុញឱ្យមានទម្លាប់ថ្មីមួយ គឺប្រព័ន្ធអនឡាញដែលជាកត្តានាំឱ្យមានការប្រើប្រាស់តាមរយៈចម្ងាយឆ្ងាយដូចជា ការសិក្សា ការប្រជុំ ការស្នើសុំ ឬបំពេញបែបបទអ្វីមួយពីអ្នកទទួលសេវា និងអ្នកផ្ដល់សេវា។ កម្មវិធីជាតិ ឬគោលនយោបាយរបស់រាជរដ្ឋាភិបាលបានជំរុញឱ្យតាមបណ្តាក្រសួងស្ថាប័នជំនាញដាក់ឱ្យប្រើប្រាស់នូវកម្មវិធី ឬគេហទំព័រផ្តល់សេវាតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាដើម។

ផែនការយុទ្ធសាស្ត្រដើម្បីធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ តាមរយៈយុទ្ធសាស្ត្រចតុកោណ៣ដំណាក់កាលកន្លងមក និងក្នុងដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០២៣ដែលបានរៀបចំឡើងក្នុងការអនុវត្ត បន្តទៀតនេះចាំបាច់ត្រូវមានផែនការយុទ្ធសាស្ត្រមួយចំនួនសម្រាប់ធ្វើទំនើបកម្មរដ្ឋបាលសាធារណៈក្នុងនោះរួមមាន ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈតាមរយៈការបន្តអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ។ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) នៅគ្រប់ក្រសួង ស្ថាប័ន អង្គភាព។ រៀបចំ និងបង្កើតលិខិតបទដ្ឋានសេវាសាធារណៈ។ កសាងសមត្ថភាពមន្ត្រីផ្តល់សេវា។

ការផ្លាស់ប្តូររបស់ប្រទេសនីមួយៗតែងតែមានជាបន្តបន្ទាប់ ក៏ដូចទៅនឹងការប្រឈមនូវបញ្ហានានាដែលកំពុងកើតឡើងក្នុងល្បឿនមួយដែលធ្វើឱ្យមានការស្មុគស្មាញ។ សកម្មភាពនៅក្នុងការផ្លាស់ប្តូរនៅចំណុចប្រព័ន្ធបច្ចេកវិទ្យាទំនើបត្រូវបានទាមទារបន្ថែមឡើងដោយចង់ឱ្យមានការលូតលាស់អំពីវិស័យឌីជីថល ស្របពេលដែលបច្ចុប្បន្នមានការផ្ទុះឡើងនូវជំងឺកូវីដ១៩កើនជាលំដាប់ផង។ បរិវត្តកម្មឌីជីថល គឺនឹងនាំមកនូវបច្ច័យវិជ្ជមានដ៏សន្ធឹកសន្ធាប់ដល់សេដ្ឋកិច្ចសង្គមកម្ពុជា ពោល គឺជាចន្លល់កំណើនថ្មីដែលមានភាពអត់ធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរជារចនាសម្ពន្ធនាពេលអនាគតផង ហើយក៏ជាចលករក្នុងការជំរុញក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចដែលមានស្រាប់ផងខណៈដែលពេលបច្ចុប្បន្នក្បាលម៉ាស៊ីនកំណើនទាំងនោះចាប់ផ្តើមមានសន្ទុះថមថយ និងរងនូវផលប៉ះពាល់ខ្លាំងបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩។

### ៤.១.១. បញ្ហាប្រឈម

ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោកហើយការកើនឡើងនៃវិបត្តិនេះកំពុងប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍មិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបាន

បំផ្លាញដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដល់ប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរផងដែរ។[៣៤] ដូចគ្នានេះដែរ បណ្ដាប្រទេសសមាជិកអាស៊ានទាំងអស់កំពុងរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីជំងឺកូវីដ១៩។[៣៥] ខណៈការផ្ទុះឡើងនៃជំងឺនេះជាសកលបាននាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ បង្កជាការរាំងស្ទះទៅដល់តម្រូវការព្រមទាំងលំហូរនៃការធ្វើដំណើរពាណិជ្ជកម្ម និងការវិនិយោគ ដែលជាហេតុបាននាំមកនូវការរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងបណ្ដាប្រទេសអាស៊ានក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ។

ផលប៉ះពាល់នៃបរិវត្តកម្មឌីជីថលកើតឡើងដោយសារការបង្កើតទម្លាប់ថ្មីដែលនាំទៅការបំផ្លាញទម្លាប់ចាស់ (Creative Destruction)តាមរយៈវត្តមាននៃបច្ចេកវិទ្យាឌីជីថលទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមបង្កឱ្យមានផលប៉ះពាល់មួយចំនួនដូចខាងក្រោម៖

- ការផ្លាស់ប្ដូររចនាសម្ពន្ធកម្លាំងពលកម្ម និងការងារ
- ការងារបែបប្រពៃណីមួយចំនួនអាចប្រឈមខ្ពស់នឹងការបាត់បង់ខណៈសេដ្ឋកិច្ចឌីជីថលនឹងបង្កើតប្រភេទការងារថ្មីដែលទាមទារឱ្យមានចំណេះដឹង និងជំនាញខ្ពស់ជាងមុនជាពិសេសជំនាញឌីជីថល
- ជាមួយគ្នានេះចរន្តឌីជីថលអាចនាំមកនូវការផ្លាស់ប្ដូររបៀបធ្វើការងារ ការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និងគ្រឿងយន្ត។

#### ៤.១.១.១. សេដ្ឋកិច្ច

ផលប៉ះពាល់លើសេដ្ឋកិច្ចពិភពលោកយ៉ាងធំធេង ហើយពហុមុខរហូតដល់មានការលំបាកក្នុងការវែកញែកផលប៉ះពាល់បន្ទាប់ទៀត។ លើសពីនេះទៅទៀត ត្រូវទទួលរងដូចជាផលិតផលក្នុងស្រុក វិនិយោគទុនការប្រើប្រាស់ការងារពាណិជ្ជកម្មអិតផរណាជាដើមនឹងត្រូវទទួលរងឥទ្ធិពល។ ការផ្ដោតសំខាន់មានពីរចំណុច គឺកំណើន ឬការរីកចម្រើន (ភាគច្រើនតាមរយៈរូបភាពនៃកត្តាកំណត់យូរអង្វែងគឺផលិតផល) និងការងារ។ ការប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច គឺជាបញ្ហាមួយដែលធ្វើឱ្យសេដ្ឋកិច្ចលើបច្ចេកវិទ្យាយល់ថាការចូលរួមរបស់បដិវត្តន៍ឌីជីថលដែលមានកន្លងមក និងផលប៉ះពាល់របស់វាស្ទើរតែលែងមានទៅហើយ។ ការពិនិត្យលើផលប៉ះពាល់ប្រកបដោយសក្ដានុពលនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤ លើកំណើនដោយយោងទៅលើនិន្នាការសេដ្ឋកិច្ចថ្មីៗ និងកត្តាផ្សេងៗទៀតដែលរួមចំណែកដល់កំណើនពិតជាមានសារៈសំខាន់ណាស់។

[៣៤] កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) «វិបត្តិកូវីដ-១៩ ដែលបានគំរាមកំហែងដល់សេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍»។

[៣៥] អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) «ការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ នៅក្នុងរដ្ឋសមាជិកអាស៊ាន»។

### ៤.១.១.២. ផលិតភាព

ទម្រង់ផ្លាស់ប្តូរដែលថ្មីៗបំផុតនៃភាពផ្ទុយគ្នារបស់ផលិតភាព ពោលគឺបរាជ័យដែលគេសន្មតនៃនវានុវត្តន៍បច្ចេកវិទ្យាដើម្បីបង្កើតផលិតភាពកម្រិតខ្ពស់ គឺប្រស្នាសេដ្ឋកិច្ចមួយដ៏ធំក្នុងចំណោមប្រស្នាធំៗនាពេលបច្ចុប្បន្ន ដែលកើតមានមុនការចាប់ផ្តើមមានមហាវិបត្តិសេដ្ឋកិច្ច ហើយដែលគ្មានការពន្យល់ឱ្យបានពេញចិត្តនៅឡើយទេ។

ទំនិញ និងសេវាកម្មថ្មីៗជាច្រើនមានលក្ខណៈ "គ្មានដៃគូប្រជែង" មានការចំណាយផ្សេងៗស្មើសូន្យ ឬបង្កើតទីផ្សារឱ្យមានការប្រកួតប្រជែងខ្ពស់តាមរយៈមធ្យោបាយឌីជីថល ដែលទាំងអស់នេះវានាំឱ្យតម្លៃទាបជាងមុន។ នៅពេលផលិតភាពដែលបានមកពីបដិវត្តន៍ឧស្សាហកម្មលើកទី៣ កំពុងចុះថមថយទៅពិភពលោកមិនទាន់បានជួបប្រទះនូវការផ្ទុះឡើងនូវផលិតភាព និងបង្កើតឡើងដោយរលកនៃបច្ចេកវិទ្យាថ្មីដែលបង្កើតនៅក្នុងបេះដូងនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤នៅឡើយ។

ផលប៉ះពាល់នៃការប្រកួតប្រជែងពីរ ដែលបច្ចេកវិទ្យាអនុវត្តន៍លើវិស័យការងារ ឬនិយោជន៍មាន៖

- ផលវិនាសកម្មនៃការផ្ទុះឡើងនៃបច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្មមកជំនួសមូលធនសម្រាប់កម្លាំងពលកម្មដែលធ្វើឱ្យកម្មករបាត់បង់ការងារ ឬដើម្បីរៀបចំជំនាញរបស់ពួកគេឡើងវិញនៅគ្រប់ទីកន្លែង
- ផលវិនាសកម្មដោយការផ្ទុះឡើងនៃបច្ចេកវិទ្យាកើតឡើងជាមួយ និងផលមូលធនកម្មដែលតម្រូវការទំនិញថ្មីៗ និងសេវាកម្មនានាមានការកើនឡើង ហើយឈានទៅរកការបង្កើតនូវអាជីពថ្មី ឬមុខរបរថ្មីៗជំនួញ ឬពាណិជ្ជកម្មថ្មី និងឧស្សាហកម្មថ្មីៗ។

បើពិនិត្យមើលទៅលើករណីជាច្រើន លំហូរចូលនៃប្រព័ន្ធបច្ចេកវិទ្យាទំនើបទាំងបច្ចេកវិទ្យាដែលមានរូបរាង និងបច្ចេកវិទ្យាជីវសាស្ត្រ (ដែលជាចលនាកំពុងនាំទៅរកការផ្លាស់ប្តូរពលកម្មបច្ចុប្បន្ន) គឺវានឹងជួយបង្កើនប្រសិទ្ធភាព និងការយល់ដឹងរបស់ការងារដែលខ្លួនកំពុងបំពេញដែលមានន័យថាថ្នាក់ដឹកនាំរៀបចំ និងចាត់ចែងការងារ និងចេះអភិវឌ្ឍន៍ប្រព័ន្ធអប់រំដើម្បីឆ្លើយតបបច្ចេកវិទ្យា និងម៉ាស៊ីនដែលមានភាពវៃឆ្លាត។

### ៤.១.១.៣. ផលប៉ះពាល់ទៅលើជំនាញ

នៅពេលអនាគត ដែលយើងអាចមើលឃើញការងារដែលមានគ្រោះថ្នាក់ទាបដោយសារវត្តមានគ្រឿងម៉ាស៊ីន គឺជាការងារដែលត្រូវការជំនាញទាក់ទងនឹងសង្គម និងភាពច្នៃប្រឌិតជាពិសេសពាក់ព័ន្ធនឹងការសម្រេចចិត្តដែលមិនប្រាកដប្រជា និងការអភិវឌ្ឍគំនិតដើម្បីដោះស្រាយបញ្ហានានា។ ការងារប្រភេទខាងលើនេះក៏ប្រហែលអាចប្រឈមនាពេលអនាគតដែរ។ បើយើងគិតទៅការងារដែលត្រូវការភាពវៃឆ្លាត និងច្នៃប្រឌិតខ្ពស់បំផុតដូចជាការងារផ្នែកសរសេរអាចមានហានិភ័យដោយសារម៉ាស៊ីនផងដែរ។ ម៉ាស៊ីនដ៏វៃឆ្លាតបំផុតទាំងនោះអាចសរសេរអត្ថបទដែលទាក់ទាញអ្នកអានបានល្អបំផុត។

បើសិនប្រៀបធៀបជាមួយការងារដែលត្រូវការប្រើប្រាស់កម្លាំង ការងារដែលត្រូវប្រើជំនាញបច្ចេកទេសរបាយការណ៍នោះបានរកឃើញថានៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ គឺជាឆ្នាំដែលសំខាន់ត្រូវប្រឈមទៅនឹងការផ្លាស់ប្តូរ។ ទីផ្សារការងារជារួម គឺនឹងមិនសូវផ្លាស់ប្តូរទេ ប៉ុន្តែនឹងមានការច្របាច់បញ្ចូលគ្នារវាងការងារនៅក្នុងឧស្សាហកម្ម និងជំនាញទៅក្នុងមុខរបរជាច្រើន។ ខណៈដែលតម្លៃពលកម្មនិងសមភាពនៃជីវិត និងការងារគឺត្រូវគេរំពឹងថានឹងរីកចម្រើនបន្តិចបន្តួចសម្រាប់មុខរបរភាគច្រើនសុវត្ថិភាពការងារ គឺត្រូវបានរំពឹងថានឹងកាន់តែធ្លាក់ចុះពាក់កណ្តាលបើតាមការស្រាវជ្រាវ។

#### ៤.១.១.៤. សង្គម

នៅពេលដែលបច្ចេកវិទ្យាធំៗត្រូវបានផ្លាស់ប្តូរប្រជាជនសង្គម និងស្ថាប័នផ្សេងៗក៏នឹងផ្លាស់ប្តូរដែរ។ ឥទ្ធិពលដែលមានគឺជារឿងដែលពួកយើងទាំងអស់គ្នាត្រូវជៀសវាង និងយកចិត្តទុកដាក់ដើម្បីឱ្យសង្គមមានការផ្លាស់ប្តូរបច្ចេកវិទ្យាដោយសមស្រប តាមស្ថានភាពនៅក្នុងសង្គមជាក់នៅក្នុងការពិភាក្សាមុនគឺបានឮបង្ហាញអំពីភាពខុសគ្នានៃឥទ្ធិពលរបស់បដិវត្តន៍ឧស្សាហកម្មលើកទីបួនទៅលើសេដ្ឋកិច្ចជំនួញ ភូមិសាស្ត្រនយោបាយសន្តិសុខអន្តរជាតិ តំបន់ និងទីក្រុងបង្ហាញយ៉ាងច្បាស់ថាបដិវត្តន៍ឧស្សាហកម្មថ្មីៗនឹងមានឥទ្ធិពលជាច្រើនទៅលើសង្គម។

### ៤.១.២. ទិសដៅការងារបន្ទាប់

ការប្រែប្រួលគោលនយោបាយ និងសេដ្ឋកិច្ចសង្គមជាសាកលដូចជាការអនុវត្តគោលនយោបាយគាំពារនិយម ភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចបម្រែបម្រួលនៃសេដ្ឋកិច្ចជាសាកលជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យា ដូចជាការចាប់ផ្តើមអនុវត្តនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការអូសបន្លាយភាពមិនប្រាកដប្រជានៃស្ថានភាពនយោបាយហិរញ្ញវត្ថុសន្តិសុខទាំងក្នុងតំបន់ និងពិភពលោកបានបង្កើតឱកាសឱ្យមានសកម្មភាព។

ដំណោះស្រាយបញ្ហាប្រឈមមានន័យបំផុត បើគេអាចប្រមូលផ្តុំប្រាជ្ញាជារួមនៃគំនិតដើម្បីសម្របតាមកំណត់ និងទាញសក្តានុពលនៃការីកសាយភាយដោយអនុវត្តន៍តាមបរិបទ (គំនិត) ច្នៃប្រឌិតអំពីការគ្រប់គ្រងនៅប្រព័ន្ធឌីជីថល។ ការបម្រើការងារត្រូវមានទិសដៅ និងគោលបំណងច្បាស់លាស់លើការបែងចែកនៃការងារក្នុងការគ្រប់គ្រងគួបផ្សំជាមួយគុណសម្បត្តិផ្សេងៗទៀតដើម្បីធ្វើការផ្លាស់ប្តូរជាមួយសកម្មភាពឆ្ពោះទៅមុខនៃការចង់បានផលរួមក្នុងការអនុវត្តការងារ។ ចំពោះការគ្រប់គ្រងមេដឹកនាំត្រូវយល់ និងមានភាពវៃឆ្លាតតាមបរិបទ។[៣៦]

[៣៦] The term "contextual intelligence" was coined by Nihtin Nohria several years before he became the dean of Harvard Business School".

ការសម្គាល់ទៅលើបរិបទនេះគេចង់បានការកំណត់ជាសមត្ថភាព និងឆន្ទៈនៅក្នុងការប្រមើលមើលនិន្នាការដែលកំពុងតែលេចឡើង និងការតភ្ជាប់ចំណុចតូចៗ។

ដើម្បីអភិវឌ្ឍតាមបរិបទត្រូវសម្រេចចិត្តត្រូវតែយល់អំពីតម្លៃនៃបណ្ដាញចម្រុះសិន។ ការប្រឈមមានតាមកម្រិតថាតើអាចប្រឈមបានដល់កម្រិតណាមួយ? ប្រសិនបើការគ្រប់គ្រងបានតភ្ជាប់ទំនាក់ទំនងគ្នាបានល្អនឹងធ្វើឱ្យអាចត្រៀមខ្លួនដើម្បីចូលរួមជាមួយបញ្ហាដែលកំពុងប្រឈម៖

- តាមរយៈការធ្វើការងាររួមគ្នា និងសហការគ្នាជាមួយមេដឹកនាំអាជីវកម្ម រដ្ឋាភិបាល សង្គមស៊ីវិល ជំនឿផ្នែកសិក្សាស្រាវជ្រាវនៅមហាវិទ្យាល័យ និងយុវជនជំនាន់ក្រោយដែលអាចធ្វើឱ្យបានដើម្បីបានជាទស្សនៈរួមជាមួយនៃអ្វីដែលកំពុងអនុវត្តន៍បន្តកើតឡើង
- សារៈសំខាន់ក្នុងការអភិវឌ្ឍ អនុវត្តន៍គំនិតរួមបញ្ចូលគ្នាព្រមទាំងដំណោះស្រាយដែលនឹងមានលទ្ធផលក្នុងការផ្លាស់ប្ដូរប្រកបដោយនិរន្តរភាព
- ព្រំដែនរវាងវិស័យ និងអាជីពគឺសិប្បនិម្មិតហើយកំពុងក្លាយជាផលអវិជ្ជមានកាន់តែខ្លាំងឡើង។ វាជាការចាំបាច់មួយដើម្បីរំលាយឧបសគ្គទាំងនេះ ដោយការចូលរួមអំណាចនៃបណ្ដាញដើម្បីបង្កើតភាពជាដៃគូដែលមានប្រសិទ្ធភាព
- ក្រុមហ៊ុន និងអង្គការដែលបរាជ័យក្នុងការធ្វើនេះហើយមិនបានអនុវត្តន៍អ្វីដែលខ្លួនបានសន្យាក្នុងការកសាងក្រុមចម្រុះ និងជួបពេលលំបាកក្នុងការសម្របខ្លួនទៅនឹងការរំខាននៃយុគសម័យឌីជីថល
- ថ្នាក់ដឹកនាំផងដែរត្រូវបង្ហាញសមត្ថភាពក្នុងការផ្លាស់ប្ដូរផ្លូវចិត្ត គំនិតក្របខណ្ឌ និងគោលការណ៍រៀបចំក្នុងពិភពលោកមានការផ្លាស់ប្ដូរយ៉ាងលឿននេះការគិតតែមួយជ្រុង និងមានទស្សនៈតែមួយជ្រុងអំពីអនាគតគឺត្រូវជាប់គាំងដែលនេះជាមូលហេតុល្អប្រសើរជាងមុន
- វិធីសាស្ត្ររបស់មេដឹកនាំនានាចំពោះបញ្ហារឿងក្ដីបញ្ហាប្រឈមត្រូវតែមានលក្ខណៈសន្តនិយម[៣៧] (Holistic) អាចបត់បែនបាននឹងអាចប្រែប្រួលបានពោល គឺការរួមបញ្ចូលគ្នាជាបន្តបន្ទាប់នូវផលប្រយោជន៍ និងទស្សនៈចម្រុះជាច្រើន។

ទន្ទឹមនឹងប៉ុន្មានឆ្នាំចុងក្រោយនេះប្រព័ន្ធ ICT នៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សដែលបង្ហាញអំពីសក្ដានុពលនៃវិស័យឌីជីថលក្នុងការប្រែក្លាយជាប្រភពកំណើនថ្មី។ ការប្រើប្រាស់សេវាក៏ដូចជាអ៊ីនធឺណេតតាមទូរស័ព្ទចល័តបាននឹងកំពុងបន្តកើនឡើងជាលំដាប់។ ទោះជាយ៉ាងនេះក្ដីវិសាលភាពគ្របដណ្ដប់ និងការប្រើប្រាស់ភាគច្រើនប្រមូលផ្ដុំនៅតាមទីក្រុង និងទីប្រជុំជនធំៗហើយគុណភាពសេវាកំពុងក្លាយជាបញ្ហាប្រឈម

[៣៧] សន្តនិយម (Holism) គឺសិក្សាទាំងមូលទៅលើសង្គមបរិយាកាសដែលមានទាំងបរិស្ថាន សារពាង្គកាយ ឥរិយាបថ ...។

ដោយសារកំណើននៃការប្រើប្រាស់ជាគំហុកក្នុងបរិការណ៍នៃការរាតត្បាតជំងឺកូវីដ-១៩ និងការប្រកួតប្រជែងយ៉ាងខ្លាំងក្លា។ ការអភិវឌ្ឍការចាប់យកឌីជីថលក៏ដូចជាការធ្វើឌីជីថលូបនីយកម្ម និងការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាស្ថិតនៅដំណាក់កាលចាប់ផ្តើមនៅឡើយ។ ក្នុងបរិបទនេះឧបសគ្គមួយចំនួនទាំងកត្តាជំរុញ និងកត្តាចាប់យកបច្ចេកវិទ្យាក្នុងចំណោមតួអង្គសំខាន់ៗបាននឹងកំពុងរាំងស្ទះដល់ដំណើរឆ្ពោះទៅមុខនៃការត្រៀមខ្លួនឌីជីថលរបស់កម្ពុជា។

## ៤.២. ដំណោះស្រាយ និងការប្រកួតប្រជែង

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅកម្ពុជា គឺមានភាពរីកចម្រើនខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដើម្បីឆ្លើយតបនឹងកំណើនដ៏ខ្លាំងក្លានៃតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការប្រើប្រាស់លើសេវាអ៊ីនធឺណេត ជាពិសេសអ៊ីនធឺណេតតាមទូរស័ព្ទចល័ត ជាក់ស្តែងកម្ពុជាមានវឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅលំដាប់មធ្យមនៅក្នុងកម្រិតតំបន់ និងសាកល។ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណេតនៅកម្ពុជាមានវិសាលភាពគ្របដណ្តប់កាន់តែល្អប្រសើរមានថ្លៃសមរម្យជាពិសេសនៅតាមទីក្រុង និងទីប្រជុំជនធំៗគុណភាពជារួមនៅមានកម្រិតនៅឡើយដែលទាមទារឱ្យមានការពង្រឹងបន្ថែម។ ទន្ទឹមនេះ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅពុំទាន់គ្រប់គ្រាន់ក្នុងការជំរុញបរិវត្តកម្មឌីជីថល និងការចាប់យកកាលានុវត្តភាពថ្មីៗបាននោះឡើយ។ ដូច្នេះសម្រាប់ជាមូលដ្ឋានក្នុងការធ្វើបរិវត្តកម្មឌីជីថលដែលនឹងជ្រាបចូលស្ទើរគ្រប់កោសិកានៃសង្គម និងគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលនឹងផ្តោតការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលលើទិដ្ឋភាព៣ធំៗដែលរួមមានការតភ្ជាប់ឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និងឡូហ្សីស្ទិកក្នុងការដឹកជញ្ជូនគោលដៅចុងក្រោយ។

យុទ្ធសាស្ត្រនយោបាយបានជួយឆ្លុះបញ្ចាំងពីឧស្សាហកម្មទីផ្សារ តាមពិតវិធីសាស្ត្រស្ទើរតែទាំងអស់ដែលបានលើកឡើងមកពន្យល់នៅក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបានគេប្រើប្រាស់រួចទៅហើយដោយក្រុមហ៊ុនរកប្រាក់ចំណេញមុនពេលដែលវិធីសាស្ត្រទាំងនេះត្រូវបានយកមកប្រើក្នុងនយោបាយ។ ទោះបីជាវាមិនអាចទៅរួចក្នុងការប៉ាន់ស្មានថាតើយុទ្ធនាការនយោបាយនឹងវិវឌ្ឍន៍យ៉ាងដូចម្តេចនាពេលអនាគតក៏ដោយវិស័យពាណិជ្ជកម្មនិងផ្នែកដែលកំពុងតែកកើតឡើងមួយចំនួនផ្សេងទៀតនៃការស្រាវជ្រាវ និងការពិសោធន៍ផ្តល់នូវតម្រុយខ្លះៗអំពីអ្វីដែលយុទ្ធនាការនឹងត្រូវធ្វើនៅពេលអនាគត។[៣៩] នៅក្នុងជំពូកនេះយើងនឹងឈ្វេងយល់ពីបច្ចេកវិទ្យាដែលកំពុងរីកចម្រើនជាច្រើនក្នុងការប្រើទិន្នន័យផ្ទាល់ខ្លួន និងបច្ចេកវិទ្យាផ្សេងទៀតដែលកំពុងមានឥទ្ធិពលនៅក្នុងយុទ្ធនាការឃោសនានយោបាយពេលថ្មីៗនេះ។

[៣៩] គេហទំព័រ https://capx.co/the-hyper-personalised-future-of-oliticalcampaigning/ ដកស្រង់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤។

ការប្រើប្រាស់រូបយន្តនយោបាយ និងការឃោសនាតាមកុំព្យូទ័រនៅក្នុងការជះឥទ្ធិពលតាមអនឡាញដូចជាការប្រើប្រាស់ Hashtag ដែលពេញនិយមនៅលើ Twitter ជាដើមត្រូវបានគេចងក្រងទៅជាឯកសារយ៉ាងត្រឹមត្រូវ ហើយការប្រើវិធីសាស្ត្រនេះក៏ជាប្រធានបទដែលសកម្មក្នុងការងារស្រាវជ្រាវផងដែរ។ [៣៩] ដូចដែលអ្នកស្រាវជ្រាវម្នាក់បានព្រមានថាក្នុងរយៈពេលពីរបីឆ្នាំបន្ទាប់ការសន្ទនារូបយន្តអាចស្វែងរកអ្នកប្រើប្រាស់ដែលងាយរងគ្រោះហើយចូលទៅជិតពួកគេនៅលើឆានែលជជែកកំសាន្តឯកជន។ ការរុករកការសន្ទនា ហើយធ្វើការវិភាគទិន្នន័យរបស់អ្នកប្រើដើម្បីកែសម្រួលដល់សារនៃការឃោសនាប្រជាភិថុតឱ្យកាន់តែល្អ និងចង្អុលបង្ហាញមនុស្សឱ្យឆ្ពោះទៅរកទស្សនៈជ្រុលនិយម និងជំទាស់ត្រូវបានគេប្រើក្នុងយុទ្ធនាការឃោសនានយោបាយក្នុងហេតុផលជាច្រើនដូចជាការអនុញ្ញាតឱ្យយុទ្ធនាការឃោសនាឆ្លើយតបទៅនឹងការសាកសួររបស់អ្នកបោះឆ្នោតប្រកបដោយប្រសិទ្ធភាព ជួយអ្នកប្រើប្រាស់រុករកព័ត៌មាននយោបាយស៊ីជម្រៅប្រចាំថ្ងៃលុបបំបាត់ពីកំហុស ដោយថៃដន្យរបស់មនុស្សអាចធ្វើការនៅលើបណ្តាញច្រើន និងអាចផ្តល់ការឆ្លើយតបមានលក្ខណៈបុគ្គលទៅកាន់អ្នកប្រើប្រាស់ដែលកំពុងចូលជាមួយពួកគេ។ [៤០] បើយោងតាមការពន្យល់ពីអ្នកជំនាញផ្នែកទំនាក់ទំនងម្នាក់ដែល "ក្នុងន័យនេះរូបយន្តអាចបង្កើតមូលទិន្នន័យបានភ្លាមៗ អាចផ្តល់ស្ថិតិអំពីចំណូលចិត្តការស្នើសុំ និងចម្ងល់នានារបស់ប្រជាជន"។[៤១] នៅក្នុងករណីផ្សេងទៀតបានកំណត់នូវគោលដៅអ្នកប្រើប្រាស់ជាមួយការស្ទង់មតិ ដើម្បីវាស់ស្ទង់ពីការឆ្លើយតបទៅនឹងបញ្ហាដែលអនុញ្ញាតឱ្យយុទ្ធនាការឃោសនាអាចធ្វើការប្រមូលទិន្នន័យបន្ថែមបាន។

យុទ្ធនាការឃោសនាទាំងនោះទំនងជាទាញផលចំណេញក្នុងការប្រើបច្ចេកវិទ្យាដូចគ្នានេះ និងធ្វើឱ្យវាកាន់តែមានភាពជឿនលឿនក្នុងការកែច្នៃភាសាធម្មជាតិដែល Google, Amazon និងក្រុមហ៊ុន Microsoft ធ្លាប់ប្រើរូបយន្តរបស់ពួកគេឱ្យកាន់តែដូចមនុស្ស។ ហេតុផលនៅពីក្រោយការស្រាវជ្រាវនេះ គឺដើម្បីអង្កេតឱ្យលម្អិតថាតើបច្ចេកវិទ្យាឌីជីថលទាំងនេះបានបង្ហាញពីគំនិត។ ប្រសិនបើវាអាចធ្វើទៅបានយុទ្ធនាការឃោសនាប្រហែលជានឹងប្រើបច្ចេកវិទ្យា "អត្តសញ្ញាណដែលអាចផ្លាស់ប្តូរបាន" ដើម្បីជះឥទ្ធិពលលើមតិយោបល់ និងបង្កើតភាពរំជើបរំជួលនៅក្នុងចំណោមមនុស្សដែលវាគិតថាជាអ្នកគាំទ្របេក្ខជននយោបាយរបស់ពួកគេ។[៤២]

[៣៩] គេហទំព័រ https://www.wired.com/story/new-tool-shows-howbots- ដកស្រង់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤។

[៤០] គេហទំព័រ http://theconversation.com/howartificial-intelligence-conquered-democracy-៧៧៦៧ ដកស្រង់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤។

[៤១] គេហទំព័រ https://chatbotsmagazine.com/bots-arenot-ដកស្រង់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤។

[៤២] អត្ថបទដកស្រង់ Hughes, 'អ្នកស្រាវជ្រាវស្វែងរកអត្តសញ្ញាណឌីជីថលតាមរយៈការវិភាគអន្តរកម្មអ៊ីមែលនៅលើអនឡាញ' គេហទំព័រ https://ourdataourselves.tacticaltech.org/posts/upcoming-tech-km/ ដកស្រង់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤។

ដាក់ស្តែងបន្ថែមលើការគាំទ្រតាមរយៈគោលនយោបាយ និងបទប្បញ្ញត្តិរាជរដ្ឋាភិបាលបាននឹងកំពុងពង្រឹងមូលដ្ឋានគ្រឹះនៃហេដ្ឋារចនាសម្ពន្ធសេដ្ឋកិច្ចឌីជីថលទាំងផ្នែករឹង និងទន់ និងអភិវឌ្ឍធនធានមនុស្ស និងជំនាញឱ្យស្របទៅនឹងតម្រូវការនិងបរិបទថ្មីនៃសេដ្ឋកិច្ច។[៤៣]

របាយការណ៍ថ្មីរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានឱ្យដឹងថាកម្ពុជានឹងអាចសម្រេចបានចក្ខុវិស័យសេដ្ឋកិច្ចឆ្នាំ២០៣០ និង២០៥០ លុះត្រាតែបច្ចេកវិទ្យាថ្មីៗត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរឡើង និងធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន។

UNDP បានឱ្យដឹងនៅក្នុងរបាយការណ៍របស់ខ្លួនស្តីពី "**ការទទួលយកឧស្សាហកម្ម៤.០នៅកម្ពុជា**" ថាសេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងអត្រាខ្ពស់ជាង៧ភាគរយក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ២០១១ ហើយកម្ពុជាបានដាក់ចេញនូវចក្ខុវិស័យរបស់ខ្លួនដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

របាយការណ៍នេះ បានឱ្យដឹងថា "ចក្ខុវិស័យនេះអាចទទួល បានលុះត្រាតែបច្ចេកវិទ្យាថ្មីៗត្រូវបានគេប្រើដើម្បីបង្កើនតម្លៃឧស្សាហកម្ម ធ្វើពិពិធកម្មការនាំចេញ និងពង្រឹងសហគ្រាសធុនតូច និងមធ្យម"។

ទោះយ៉ាងណាផលិតកម្មរបស់កម្ពុជាត្រូវបានផ្តោតលើវិស័យធំៗចំនួនពីរ វាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង អាហារ និងភេសជ្ជៈ។ របាយការណ៍បន្ថែមថាផលិតផលទាំងនេះបានរួមចំណែក៨០ភាគរយនៃតម្លៃផលិតកម្មបន្ថែម និង៧៦ភាគរយនៃការនាំចេញរបស់ប្រទេស។

ឧស្សាហកម្ម៤.០ មានសក្តានុពលក្នុងការបង្កើតប្រភពថ្មីនៃតម្លៃសម្រាប់កម្មករ ក្រុមហ៊ុន សហគ្រាស និងប្រទេសនានាហើយកម្មវិធី និងដំណោះស្រាយឧស្សាហកម្ម៤.០ កាន់តែមានតម្លៃទាប កាន់តែទូលំទូលាយ និងងាយស្រួលប្រើប្រាស់។ ក្រុមហ៊ុនផលិតកម្មអាចជំរុញឧស្សាហកម្ម៤.០ ដើម្បីផ្តល់ជូននូវផលិតផលសេវាកម្មខ្សែសង្វាក់ផ្គត់ផ្គង់ឆ្លាតវៃ និងចែកចាយ។

ប៉ុន្តែកម្រិតនៃការទទួលយកឧស្សាហកម្ម ៤.០ នៅកម្ពុជានៅតែទាបនៅឡើយដោយកត់សម្គាល់ថាបច្ចេកវិទ្យាឌីជីថលនៅក្នុងក្រុមហ៊ុនភាគច្រើន (ជាង ៩០ ភាគរយ) នៅតែស្ថិតក្នុងកម្រិតមូលដ្ឋាននៅឡើយ។

នៅកម្រិតក្រុមហ៊ុន ឧបសគ្គក្នុងការប្រើប្រាស់ឧស្សាហកម្ម ៤.០ នៅក្នុងប្រទេសកម្ពុជារួមមានកង្វះការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថល និងអត្ថប្រយោជន៍របស់ពួកគេការយល់ដឹងខ្ពស់នៃបច្ចេកវិទ្យា ការបង្វែរ ការប្រើបច្ចេកវិទ្យា

[៤៣] គេហទំព័រ https://www.digitalcambodia.com.kh/author/sophea/ ដកស្រង់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤។

ថ្មី ចន្លោះប្រហោងជំនាញ ការទទួលបានការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសនៅមានកម្រិត និងការរាំងស្ទះ ការទទួលបានហិរញ្ញវត្ថុ។[៤៤]

[៤៤] គេហទំព័រ https://cambodiafinancialtimes.com/sme/3824/ ដកស្រង់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវខាងលើ យើងសង្កេតឃើញថារាជរដ្ឋាភិបាលបាន និងខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់សេវាសាធារណៈ ដែលមានការវិវឌ្ឍពីការផ្តល់សេវាសាធារណៈតាមបែបប្រពៃណីទៅជាការផ្តល់សេវាសាធារណៈតាមបែបបច្ចេកវិទ្យាទំនើបដែលទទួលបានការរីកចម្រើន និងទទួលបាននូវលទ្ធផលខ្ពស់ឆាប់រហ័សក្នុងរយៈពេលចុងក្រោយនេះ។ ក្នុងអំឡុងពេលនោះដែរ យើងក៏សង្កេតឃើញថាកំណើននៃការប្រើប្រាស់អ៊ីនធឺណេតក៏មានការកើនឡើងជាលំដាប់រហូតដល់យើងអាចនិយាយថា មនុស្សនាពេលបច្ចុប្បន្នរស់នៅមិនអាចខ្វះអ៊ីនធឺណេតបាន។ លើសពីនេះទៅទៀត ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាគឺជាការបង្កើតនូវយុទ្ធសាស្ត្រដ៏ល្អប្រសើរមួយរបស់រាជរដ្ឋាភិបាលនៅក្នុងការផ្តល់នូវភាពងាយស្រួល ព្រមទាំងមានភាពទំនើបបន្តិចម្តងៗទៅកាន់ប្រជាពលរដ្ឋ។ ចំពោះគោលនយោបាយវិញរាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើកំណែទម្រង់ដែលមានមូលដ្ឋានទូលំទូលាយជាច្រើនក្នុងគោលបំណងពង្រឹងភាពប្រកួតប្រជែងនឹងប្រទេសដទៃ សម្រេចបាននូវការអភិវឌ្ឍ និងនាវានុវត្តសេដ្ឋកិច្ច និងសង្គមឌីជីថល។ ក្នុងការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធឌីជីថលមានសក្តានុពលដ៏ធំធេងសម្រាប់រួមចំណែកដល់សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា ហើយជាមធ្យោបាយសម្រាប់ការធ្វើអាជីវកម្ម ការទូទាត់ប្រាក់ ការបណ្តុះបណ្តាល ការផ្តល់ព័ត៌មាន ការប្រមូល និងផ្តល់ទិន្នន័យដែលស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ជាក់ស្តែងដូចជាការចុះបញ្ជីអាជីវកម្មតាមថ្នាលតែមួយអេឡិចត្រូនិក CamDigikey។ ជាការពិតណាស់រាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្តន៍នូវគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដោះស្រាយកង្វះខាតឫសគល់នៃប្រព័ន្ធអេកូឡូស៊ី ហើយម្យ៉ាងទៀតគឺដើម្បីយល់ដឹងពីវិសាលភាពពេញលេញនៃកាលានុវត្តភាពនៃវិស័យពាណិជ្ជកម្ម និងវិស័យដទៃទៀតនៅកម្ពុជា។ សកម្មភាពទាំងនោះតម្រូវឱ្យមានការចូលរួមចំណែកក្នុងការអនុវត្តពីក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។ ជាក់ស្តែងនាពេលបច្ចុប្បន្នពិភពលោកកំពុងស្ថិតក្នុងបរិបទកូវីដ-១៩ ហើយប្រទេសកម្ពុជាយើងក៏ជាប្រទេសមួយក្នុងចំណោមប្រទេសទាំងអស់ដែលរងនូវផលប៉ះពាល់ និងការរាំងស្ទះនូវដំណើរការប្រព្រឹត្តទៅលើវិស័យទាំងឡាយដែលធ្វើឱ្យប្រទេសជាតិជួបផលលំបាកក្នុងការគ្រប់គ្រង។ ក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានខិតខំអស់ពីកម្លាំងកាយ ចិត្តក្នុងការចាត់នូវវិធានការទប់ស្កាត់ជំងឺនេះ ដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ផ្តល់នូវសេវាសាធារណៈក៏ដូចជាការកាត់បន្ថយនូវការរីករាលដាលនូវជំងឺនេះដ៏កាចសាហាវ។ ដោយមើលឃើញពីបញ្ហា និងទុក្ខលំបាកនេះហើយទើបរាជរដ្ឋាភិបាលបានចេញនូវសម្រេចប្រកាសឱ្យមានការចូលរួមចំណែកនូវការទប់ស្កាត់ជំងឺពីបណ្តាក្រសួង ស្ថាប័នទាំងឡាយបានចាប់យកបច្ចេកវិទ្យាឌីជីថល ដោយប្រជាពលរដ្ឋក្នុងសង្គមបាននឹងកំពុងស្វែងរកដំណោះស្រាយលើផលប៉ះពាល់នៃវិធានការរឹតត្បឹតការធ្វើដំណើរ ការផ្អាកដំណើរការអាជីវកម្ម ចលនានៃការបំពេញការងារតាមផ្ទះក៏ដូច

ជាការរក្សាគម្លាតសុវត្ថិភាពសង្គម ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការអនុវត្តកិច្ចការងាររៀងៗខ្លួនក្នុងគោលបំណងកាត់បន្ថយការជួបជុំផ្ទាល់ដែលជាបញ្ហាប្រឈមនឹងការឆ្លងជំងឺ។ លើសពីនេះទៅទៀតការអនុវត្តការងារ និងការផ្តល់សេវាសាធារណៈនៅតាមក្រសួង ស្ថាប័នតាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថល។

នៅក្នុងបរិបទកូវីដ-១៩ ក៏ធ្វើឱ្យមានការយល់ដឹងកាន់តែច្បាស់ពីវិស័យបច្ចេកវិទ្យា និងចលករក្នុងការពន្លឿនជាមួយនឹងការផ្តល់ភាពងាយស្រួលក្នុងការបំពេញតួនាទី និងភារកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយស្តីពីសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម៤.០។ សរុបមក អ្វីដែលក្រសួង ស្ថាប័នបានសម្រេចនាពេលកន្លងមកនេះគឺបានបង្ហាញពីគោលជំហររបស់រាជរដ្ឋាភិបាល ក្នុងការទទួលយកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាឧបករណ៍ដ៏សំខាន់មួយក្នុងការងារកែទម្រង់ និងបង្កើតប្រសិទ្ធភាពការងាររដ្ឋបាលប្រចាំថ្ងៃ។ ប្រទេសកម្ពុជា កំពុងស្ថិតក្នុងដំណើរឆ្ពោះទៅរកបដិវត្តន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាហេតុនាំឱ្យរាជរដ្ឋាភិបាលបន្តពង្រីកវិសាលភាពនៃប្រព័ន្ធនេះ ឈានទៅគ្របដណ្តប់ដល់គ្រប់ក្រសួង ស្ថាប័នផ្សេងទៀតដើម្បីរៀបចំការផ្តល់អាជ្ញាប័ណ្ណនានា តាមថ្នាលបច្ចេកវិទ្យាព័ត៌មានថែមទៀតដើម្បីជួយឱ្យប្រទេសមានការរីកចម្រើន និងសម្រេចបាននូវចក្ខុវិស័យវែងឆ្ងាយរបស់ខ្លួន និងទទួលបានការរីកចម្រើនជាពិសេសមានភាពជឿនលឿនមិនខុសពីប្រទេសដែលបានអភិវឌ្ឍន៍។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវទាំងទ្រឹស្តី និងទិដ្ឋភាពជាក់ស្តែងអំពីការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យារួចមក ខ្ញុំសង្កេតឃើញថាទោះបីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅកម្ពុជាទទួលបានការប្រព្រឹត្តទៅយ៉ាងរលូនក៏ដោយក៏នៅតែមានការខ្វះចន្លោះ និងបញ្ហាប្រឈមមួយចំនួនបានបង្កឱ្យមានភាពរាំងស្ទះដែលបង្អាក់ក្នុងដំណើរការអនុវត្តការងាររបស់រដ្ឋាភិបាល និងបង្អាក់ធុរជនក្នុងការចុះបញ្ជីអាជីវកម្មថ្មីដោយការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនេះ។ ដើម្បីចូលរួមជំរុញ លើកកម្ពស់ និងពង្រឹងការអនុវត្តការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាឱ្យកាន់តែប្រសើរឡើងមួយកម្រិតទៀតដោយរក្សាស្ថិរភាព ការអភិវឌ្ឍ និងនវានុវត្តន៍ថែមទាំងទាក់ទាញការវិនិយោគដែលប្រកបដោយភាពជឿទុកចិត្តពីសំណាក់វិនិយោគិនបរទេស។

អាស្រ័យហេតុនេះហើយខ្ញុំមានអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ស្នើសុំឱ្យគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធឱ្យជួយពង្រឹង និងបង្កើនល្បឿននៃសេវាអ៊ីនធឺណេតឱ្យមានលក្ខណៈលឿនជាងមុនពីព្រោះដំណើរការ និងការប្រព្រឹត្តទៅនៃការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ គឺពឹងផ្អែកទាំងស្រុងតាមរយៈការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតដែលមានសេវាលឿនទាន់ចិត្តទើបការងារទាំងឡាយមានដំណើរការយ៉ាងរលូន និងឆាប់រហ័ស
- ស្នើសុំឱ្យមានការតភ្ជាប់បណ្តាញអ៊ីនធឺណេតទៅតាមទីជនបទដើម្បីជួយសម្រួលដល់ការទទួលបាននូវសេវាសាធារណៈដល់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាល ឬទីជនបទដែលឆ្ងាយពីទីក្រុង
- ទាមទារឱ្យមានការពង្រឹងនូវប្រព័ន្ធសន្តិសុខឱ្យមានភាពរឹងមាំ ដោយមានការគ្រប់គ្រងសុវត្ថិភាពលើព័ត៌មានវិទ្យា (Cybersecurity) ដើម្បីអនុវត្តន៍នៃការទប់ស្កាត់ ការឆ្លើយតប និងការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមទាំងហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រព័ន្ធប្រតិបត្តិការ និងកម្មវិធីពីការជ្រួតជ្រាបចូល និងការវាយប្រហារគ្រប់រូបភាពជាពិសេសតាមប្រព័ន្ធអ៊ីនធឺណេតនេះ ព្រោះថាមួយរយៈកន្លងមកនេះគេហទំព័រស្ថាប័នរដ្ឋ និងស្ថាប័នធនាគារមួយចំនួនទទួលរងនូវការវាយប្រហារជាច្រើនដែលបង្ហាញពីអសន្តិសុខ និងអស្ថិរភាពនៅក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះ
- ពង្រឹង និងបណ្តុះបណ្តាលធនធានមនុស្សទៅលើអក្ខរកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍវិស័យឌីជីថលនេះ។ ពោល គឺមានការយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា (IT) ឱ្យមានការយល់ដឹងបានច្រើនព្រោះការយល់ដឹង និងមានចំណេះដឹងច្បាស់លាស់ពីការប្រើប្រាស់បច្ចេកវិទ្យាជាកត្តាជំរុញឱ្យមានកំណើននៃការប្រើប្រាស់ ការផ្តល់សេវាសាធារណៈ ដូចជាការចុះបញ្ជីយានយន្ត និងការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលពង្រឹងពីការឆ្លើយតបរបស់

ប្រជាពលរដ្ឋទៅនឹងទីផ្សារការងារនានា ការទទួលបាននូវភាពងាយស្រួលក្នុងការផ្តល់ និងការទទួលបាននូវសេវាសាធារណៈនៅតាមក្រសួង ស្ថាប័នក្នុងពេលបច្ចុប្បន្ន និងអនាគត

- ក្រសួងសាមី ដែលអនុវត្តកិច្ចការងារត្រូវមានអ្នកចេះច្បាស់លាស់សម្រាប់ធ្វើការងារមានលក្ខណៈជំនាញដើម្បីគ្រប់គ្រងទិន្នន័យតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដោយសារការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធអនឡាញគឺពិតជាមានសារៈសំខាន់ក្នុងការអនុវត្តការងារតាមប្រព័ន្ធអេឡិចត្រូនិកទើបទាមទារឱ្យមានជនបង្គោលដែលមានជំនាញក្នុងការផ្តល់សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋ ដូច្នេះហើយស្នើសុំឱ្យក្រសួងសាមីព្រមទាំងស្ថាប័នពាក់ព័ន្ធមេត្តារៀបចំអ្នកគ្រប់គ្រងទិន្នន័យបែបឌីជីថលដែលប្រកបដោយគុណភាព និងជំនាញ។

ក្នុងនាមជាបញ្ញវន្ត ជាអ្នកស្រាវជ្រាវ និងជាពលរដ្ឋក្នុងសង្គមសូមផ្តល់ជាអនុសាសន៍មួយចំនួនខាងលើក្នុងគោលបំណងនូវការផ្តល់ជាគំនិត យោបល់ក្នុងន័យស្ថាបនា និងជាស្មារតីមួយក្នុងការចូលរួមជំរុញការអភិវឌ្ឍប្រទេសនៃការធ្វើទំនើបកម្មក្នុងការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាគំនិតមួយចំនួននៃអនុសាសន៍ខាងលើត្រូវបានក្រសួង ស្ថាប័នមេត្តាទទួលយកគំនិតទាំងនេះទៅកែប្រែ និងបំពេញបន្ថែមនូវចន្លោះខ្វះខាតរបស់ខ្លួនដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ក្នុងការអនុវត្តសេដ្ឋកិច្ចឌីជីថលបន្តទៅមុខទៀត និងដើម្បីសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ពន្ធសេដ្ឋកិច្ច និងសង្គមមួយទាំងមូលឱ្យឈានឆ្ពោះទៅកាន់សង្គមដែលមានការតភ្ជាប់ក្នុងការប្រកួតប្រជែងលក្ខណៈសាកលផងដែរ។

# ឯកសារយោង

## ក. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩។
- ច្បាប់ ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, លេខ នស/រកម/១១១៩/០១៦, ០៤ វិច្ឆិកា ២០១៩។
- ព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, លេខ នស/រកត/០៩១៤/១១៣៦, ០៨ កញ្ញា ២០១៤។
- អនុក្រឹត្យ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មាន, លេខ ៨៤ អនក្រ.បក, ១០ ខែមិថុនា ២០២០។
- ប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម, លេខ៤៣០/២០ ក.ប/ប្រ.ក.ខ/ល, ៣១ ធ្នូ ២០២០។
- ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, លេខ៣៣៣ សហវ ប្រក, ២៧ ខែមីនា ឆ្នាំ២០២០។
- ប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, លេខ៣៣៥ សហវ ប្រ.ក, ២៧ មីនា ២០២០។
- សេចក្តីជូនដំណឹងរបស់ធនាគារជាតិ ស្តីពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, លេខធ៧.០២០.៥៦៩ ស.ជ.ណ, ២៤ កក្កដា ២០២០។
- សេចក្តីណែនាំនៃក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime ២០២០), លេខ០១១ សណន, ០៤ ឧសភា ២០២១។

## ខ. ឯកសារយោងជាគោលនយោបាយ

- គោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨-២០២៣)
- គោលនយោបាយជាតិស្តីពីបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន " សំណើគោលនយោបាយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ", ២០០៩។
- គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន "ឆ្ពោះទៅសន្តិភាព និងសកម្មភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន", ២០២០។

- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា, ២០២១-២០៣៥។
- យោងតាមរបាយការណ៍ស្តីពី វិស័យឌីជីថល សង្គម និងទូរស័ព្ទចល័ត របស់អេភីអេស៊ី, ២០១៥។
- បញ្ញត្តិករទូរគមនាគមន៍កម្ពុជា "ការជាវអ៊ីនធឺណេត"។
- អង្គការសុខភាពពិភពលោក (២០២០) របាយការណ៍ទី៥ ស្តីពីស្ថានភាពជំងឺរាតត្បាតកូវីដ-១៩នៅកម្ពុជា។

## គ. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- សម្តេចព្រះសង្ឃរាជ ជួន ណាត. វចនានុក្រមខ្មែរ ។
- ហៀង សាង. នីតិរដ្ឋបាលទូទៅ.២០២១។
- អ ចំរើន. សិក្ខាប័ននីតិរដ្ឋបាល, ២០១១។
- Toolkit សម្រាប់រៀបចំផែនការបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) សម្រាប់ភ្នាក់ងាររដ្ឋាភិបាល រដ្ឋាភិបាលរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (NiDA).២០០៨។
- OECD, the E-government Imperative, Paris: OECD Publications, ២០០៣។
- Project for Capacity Building on ICT Management for NiDA។

## ឃ. ឯកសារយោងជាគេហទំព័រ

- គេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម http://www.moc.gov.kh/km-kh/
- គេហទំព័រ https://shop.moc.gov.kh/
- គេហទំព័ររបស់ក្រសួងមហាផ្ទៃ https://www.interior.gov.kh/news/detail/2347
- គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh
- គេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh
- គេហទំព័ររបស់ទីស្តីការគណៈរដ្ឋមន្ត្រី https://www.ocm.gov.kh/wp-
- គេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា https://www.cambodiainvestment.gov.kh/KM/
- គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ https://mef.gov.kh/documents/
- គេហទំព័រអំពី The follow-up Study Report on e-Government Service Development Plan https://www.jica.go.jp/project/cambodia/0609376/04/pdf/05_egov_2009_e.pdf
- គេហទំព័រ https://www.kas.de/en/web/kambodscha/single-title/-/content/e-government-what-can-cambodia-learn-from-e-estonia

- គេហទំព័រ https://secudemy.com/egov-digital/
- គេហទំព័រសេវាកម្មចុះបញ្ជីតាមរយៈតំណ https://www.registrationservices.gov.kh/
- គេហទំព័រ Digital "Government-to-Business" service in Cambodia: Overview and Challenges by Maria Yang and Darapich Sovann publishes in January 28 2020
- គេហទំព័រ https://www.kas.de/en/web/kambodscha/single-title/-/content/digital-government -to-business-services-in-cambodia-overview-and-challenges
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/science-and-technology/
- គេហទំព័រ https://www.trc.gov.kh/summary-on-cambodian-ict-masterplan-2020/
- គេហទំព័រ https://www.who.int/docs/defaultsource/wprodocuments/countries/cambodia/covid-19/covid-19-joint-who-moh-sitrep-05.pdf?sfvrsn=845
- គេហទំព័រ Castillo, G. G. (២០២០) ស្ថានភាពជំងឺកូវីដ-១៩នៅកម្ពុជា https://focusweb.org/cambodia -covid-19-situationer/.
- គេហទំព័រ នៃច្បាប់ ស្តីពីការគ្រប់គ្រងប្រទេសនាគ្រាអាសន្នរបស់ប្រទេសកម្ពុជានិងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩៖ https://www.asiapacific.ca/publication/cambodias-state-emergency-law-and-fight-against-covid-19
- គេហទំព័រ https://cd-center.org/wp-content/uploads/2020/04/RGC-Measure-COVID-19-Update17042020
- គេហទំព័រ https://policypulse.org/kh/
- គេហទំព័រ https://www.interior.gov.kh/document/detail/1033
- គេហទំព័រព័ត៌មាន https://www.khmertimeskh.com/50714122/mandatory-quarantine-to-help -prevent-coronavirus-spread/
- គេហទំព័រ https://focusweb.org/cambodia-covid-19-situationer/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ក. ឧបសម្ព័ន្ធជារូបភាព

**ឧបសម្ព័ន្ធទី១៖** កិច្ចប្រជុំរបស់រដ្ឋាភិបាលតាមប្រព័ន្ធអនឡាញ

**ឧបសម្ព័ន្ធទី២៖** នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**ឧបសម្ព័ន្ធទី៣៖** រចនាសម្ពន្ធរដ្ឋាភិបាលឌីជីថលកម្ពុជា

## ខ. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩។

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, លេខ ៨៤ អនក្រ.បក, ១០ ខែមិថុនា ២០២០។

**ឧបសម្ព័ន្ធទី៣៖** ប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម, លេខ៤៣០/២០ ក.ប/ប្រ.ក.ខ/ល, ៣១ ធ្នូ ២០២០។

**ឧបសម្ព័ន្ធទី៤៖** ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, លេខ៣៣៣ សហវ ប្រក, ២៧ មីនា ២០២០។

**ឧបសម្ព័ន្ធទី៥៖** ប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, លេខ ៣៣៥ សហវ ប្រ.ក, ២៧ មីនា ២០២០។

# ឧបសម្ព័ន្ធជារូបភាព

**ឧបសម្ព័ន្ធទី១៖** កិច្ចប្រជុំរបស់រដ្ឋាភិបាលតាមប្រព័ន្ធអនឡាញ



**សកម្មភាព៖** កិច្ចប្រជុំរបស់រដ្ឋាភិបាលទាក់ទងនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃការផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថលដោយកិច្ចប្រជុំនេះធ្វើឡើងតាមរយៈប្រព័ន្ធហ្ស៊ូម (Zoom) ដែលបានអនុវត្តទៅតាមការណែនាំរបស់ក្រសួងសុខាភិបាលដោយអនុវត្តនូវវិធីសាស្រ្ត ៣កុំ ៣ការពារ។

**ឧបសម្ព័ន្ធទី២៖** នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



## **ឧបសម្ព័ន្ធទី៣៖** រចនាសម្ពន្ធរដ្ឋាភិបាលឌីជីថលកម្ពុជា




រចនាសម្ពន្ធនេះ ជាផែនទីបង្ហាញផ្លូវដែលអាចកំណត់ទិសដៅបានត្រឹមត្រូវបំផុតសម្រាប់កម្មវិធីរបស់រដ្ឋាភិបាលឌីជីថលទូទៅនៅក្នុងប្រទេសកម្ពុជានេះ ហើយវាក៏ជាមគ្គុទ្ទេសក៍ដែលមានភាពបត់បែនតាមកាលៈទេសៈផងដែរ។

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្តីពី

## ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះមានគោលបំណង៖

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណី តាមប្រព័ន្ធអេឡិចត្រូនិក។

៣. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្ការនិងបង្រ្កាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។

៤. លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរនិងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

១. ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

២. ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។

៣. រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

៤. ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

៥. ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .. និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា៥ .. ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។

**មាត្រា៦ .. លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយឬកិច្ចការណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

**មាត្រា៧ .. លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែលៈ

ក. អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មាន ឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

ខ. អាចជឿជាក់បាន ស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើងឬត្រូវបានប្រាស្រ័យទាក់ទង។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវយកមកអនុវត្តផងដែរ។

**មាត្រា៨ .- លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**មាត្រា៩ .- ទម្រង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. មានផ្ទុកព័ត៌មានដូចគ្នាឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់។

២. អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ។ និង

៣. អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**មាត្រា១០ .- លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត។

ខ. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ។ និង

គ. ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើឬទទួល។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ សម្រាប់តែធ្វើការបញ្ជូនឬទទួលសារនោះឡើយ។

**មាត្រា១១ .- លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

១. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក។ ឬ

២. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្នើការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្នើការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្ដីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬ ដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអាចៈ

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលៈ

ក. ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ. ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា**

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្វីការពីភាគីម្ខាងទៀត។

**មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

**មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជនណាមួយ។

បញ្ញត្តិដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

## ជំពូកទី៤

## កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

**មាត្រា១៩ .-** កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព

កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។

**មាត្រា២០ .-** ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

ក. ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។

ខ. កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។

ឃ. បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។ និង

ង. បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

២. បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

ក. កំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក។ ឬ

ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

**មាត្រា២១ .-** ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតថាជាកំណត់ត្រាអេឡិចត្រូនិកដែលមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតដូចខាងក្រោម៖

ក. ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់បុគ្គលពាក់ព័ន្ធ។ និង

ខ. ហត្ថលេខាអេឡិចត្រូនិកនោះ ត្រូវបានចុះហត្ថលេខាដោយបុគ្គលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបញ្ញត្តិណាមួយនៅក្នុងជំពូកទី៤ អាចសន្មតបានជាមុនអំពីយថាភូតភាព ឬសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា២២ .- ការលួចប្រើប្រាស់អត្តសញ្ញាណ**

បុគ្គលទាំងឡាយមិនត្រូវប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា២៣ .- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព**

១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុវត្ថិភាព សម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិក។

២. ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៥
## អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា២៤ .- ការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ ក្នុងករណីដែលខ្លួនមិនមែនជាអ្នកធ្វើកំណត់ត្រានោះ និងក្នុងករណីដែល៖

ក. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានធ្វើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។

ខ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។ ឬ

គ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថាព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថា ព័ត៌មាននោះ

អាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា២៥ ខាងក្រោម។

២. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួននោះឡើយ ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះអាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីក៏ដោយ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា។

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា២៥ .- ការទទួលខុសត្រូវផ្នែកព័ត៌មានឬហេតុការណ៍**

១. ក្នុងករណីដែលអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុនិងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវរក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

៣. នៅពេលបានដឹងឬទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ក្រសួងប្រៃសណីយ៍និង

ទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ខ. ផ្អាកឬឈប់ផ្តល់សេវាដល់បុគ្គលនោះ។ ឬ

គ. ផ្អាកឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក។

៤. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តាមកិច្ចសន្យាឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥. បុគ្គលដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិតឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពីអំពើនោះ។

**មាត្រា២៦ .- ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រសួងពាណិជ្ជកម្មផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណរួមមាន៖

ក. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល។

ខ. អាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។

៣. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់វិញ្ញាបនបត្រសេវាអនឡាញ។

៤. ការលើកលែង ការកំណត់ប្រភេទអាជ្ញាបណ្ណ បែបបទ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៧ .- ក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវកំណត់និងរៀបរៀងឡើងដោយក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ដោយសហការជាមួយក្រសួង ស្ថាប័ននិងភាគីពាក់ព័ន្ធ។

**មាត្រា២៨ .- កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះ**

អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## កិច្ចការពារអ្នកប្រើប្រាស់

**មាត្រា២៩ .- ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

ក. ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដកឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញនិងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

៣. បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រនិងធានារ៉ាប់រងឡើយ។

**មាត្រា៣០ .- ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឱ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

**មាត្រា៣១ .- ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ**

១. បុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំឬបង្កការភាន់ច្រឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ឬធ្វើប្រតិបត្តិការ ដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតិយជនឡើយ។

២. បុគ្គលទាំងឡាយមិនត្រូវបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ ក្នុងគោលបំណងទុច្ចរិត តាមមធ្យោបាយអេឡិចត្រូនិក ទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។

**មាត្រា៣២ .- ការការពារទិន្នន័យ**

១. បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២. បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

**មាត្រា៣៣ .- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៤ .- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ. ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើត រក្សាទុក ឬបោះផ្សាយ។

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ. របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ. ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង. លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨

## ភស្តុតាងអេឡិចត្រូនិក

**មាត្រា៣៥ .- ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក**

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយហេតុផលគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

**មាត្រា៣៦ .- សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក**

១. នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រាឬរក្សាទុកនូវទិន្នន័យណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ប្រព័ន្ធអេឡិចត្រូនិកដែលបានប្រើប្រាស់សម្រាប់កត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាព ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ តាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក. ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុ សមស្របណាផ្សេងយកមកជំទាស់សុក្រឹតភាពនៃកំណត់ត្រានោះ។

ខ. ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ឬ

គ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣៧ ._ សុក្រឹតភាពនៃព័ត៌មាន**

១. លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក. នៅពេញលេញនិងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនង ការរក្សាទុកឬការបង្ហាញ។

ខ. ត្រូវបានបញ្ជាក់ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឱ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

គ. មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ. ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង. ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច. នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតបានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតីឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រាមិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ។ ឬ

ឆ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

២. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតានិងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

៣. នៅពេលដែលរបាយការណ៍ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌដូចដែលមានចែងនៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា៣៨ .- ឯកសារដែលបានបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពចេញត្រឹមត្រូវស្របនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិក អាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៩ .- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១. បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវទទួលបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបានបង្ហាញ។

២. ក្នុងករណីមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃការបង្ហាញភស្តុតាងដែលផ្តល់ប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពជាងមាត្រានេះ។

**មាត្រា៤០ .- បទដ្ឋាននៃការកត់ត្រាឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក**

ដើម្បីកំណត់បានថាកំណត់ត្រាអេឡិចត្រូនិកត្រូវទទួលយកឬមិនទទួលយកក្នុងបទប្បញ្ញត្តិផ្សេងទៀត ការបង្ហាញភស្តុតាងអាចត្រូវធ្វើឡើងដោយផ្អែកលើបទដ្ឋាន នីតិវិធី ការប្រើឬការអនុវត្តនៃការកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្ម ចរិតលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា៤១ .- ការចេញលិខិតបញ្ជាក់យថាភូតភាព**

១. ក្នុងករណីដែលបុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់។

២. លិខិតបញ្ជាក់យថាភូតភាពដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវចេញដោយ៖

- ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ។ ឬ
- ខ. អ្នកជំនាញដែលតែងតាំងឬដែលទទួលស្គាល់ដោយតុលាការ។

៣. បុគ្គលដែលមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់យថាភូតភាព ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ខាងលើ មិនត្រូវក្លែងឬចេញលិខិតបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិកដែលមានលក្ខណៈក្លែងបន្លំឬមិនមែនជាការពិតនោះឡើយ។

**មាត្រា៤២ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការី ឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឱ្យមានការកែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

**មាត្រា៤៣ .- ការបំពានលើកូដនីយកម្ម**

បុគ្គលទាំងឡាយមិនត្រូវដាក់កូដក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬការដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិកដែលទាក់ទិននឹងបទល្មើសឡើយ។

**មាត្រា៤៤ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេសត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤៥ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៤៦ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១- បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២- ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៧ .- ការទទួលខុសត្រូវរបស់បុគ្គលផ្ដល់សេវាទូទាត់**

១- បុគ្គលផ្ដល់សេវាទូទាត់មិនត្រូវផ្ដល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្ដូរ។

២- មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្ដល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្ដល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក- ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ- ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ- ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម។

ឃ- ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង- ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣- បុគ្គលផ្ដល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤- ក្នុងករណីដែលបុគ្គលផ្ដល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្ដល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវតម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះ ដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

៥- បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។

**មាត្រា៤៨ .- ការទទួលខុសត្រូវរបស់អតិថិជន**

១- អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្ដល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍/មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបានឬមិនឱ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្មឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០
## សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការដាក់ពិន័យ

### មាត្រា៤៩ .. សមត្ថកិច្ច

ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

ក្នុងករណីដែលបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ អាចធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

### មាត្រា៥០ .. នីតិវិធីនៃការប្តឹងតវ៉ា

១. បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣. បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនៃសេចក្តីសម្រេចនោះ។

**មាត្រា៥១ .- នីតិវិធីនៃការផាកពិន័យ**

នីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការផាកពិន័យ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា៥២ .- ទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាព ឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ការផាកពិន័យ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**មាត្រា៥៣ .- អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា២២។

**មាត្រា៥៤ .- អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានឬហេតុការណ៍**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះអំពើរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៥។

**មាត្រា៥៥ .- អំពើផ្តល់ពត៌មានមិនពិត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា២៥។

**មាត្រា៥៦ .- ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត**

ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលការផាកពិន័យជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា២៦។

ក្នុងករណីធ្លាប់ទទួលរងនូវវិធានការដូចមានចែងក្នុងកថាខណ្ឌទី១ជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលពី៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

**មាត្រា៥៧ .- អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៩។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៥៨ .- អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣០។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបិទមិនឱ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។

**មាត្រា៥៩ .- អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិកនិងកូដព្យាបាទ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣១។

**មាត្រា៦០ .- អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។

**មាត្រា៦១ .- អំពើល្មើសលើការបំពានលើការចេញលិខិតបញ្ជាក់យថាភូតភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយរយពាន់)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៤១។

**មាត្រា៦២ .- អំពើល្មើសលើការបំពានលើគូដនីយកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៤៣។

**មាត្រា៦៣ .- អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។

**មាត្រា៦៤ .- អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

**មាត្រា៦៥ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

១. នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៣ដល់មាត្រា៥៥ កថាខណ្ឌទី២នៃមាត្រា៥៦និងមាត្រា៥៩ដល់មាត្រា៦៤នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ៖

- ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
- ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
- គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
- ឃ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
- ង. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ សារព័ត៌មានអេឡិចត្រូនិក ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

ROYAUME DU CAMBODGE

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៦៦ .-** ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦៧ .-** ការអនុវត្តច្បាប់នេះ

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល៦(ប្រាំមួយ)ខែ ទើបអនុវត្ត។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

ចារល. ១៩១១. ១៦៥៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្ដិ**

# ឧបសម្ព័ន្ធ
# និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១. **ការចូលប្រើប្រាស់/អាក់សេស(Access)** សំដៅដល់ការចូលទៅប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក ដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យ ព័ត៌មានឬឯកសារផ្សេងៗទៀតក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

២. **អ្នកទទួល(Addressee)** សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

៣. **ប្រព័ន្ធស្វ័យប្រវត្តិ(Automated System)** សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

៤. **បណ្ណ/កាតទូទាត់(Card)** សំដៅដល់បណ្ណ/កាតធនាគារ បណ្ណឥណទាន/ឥណពន្ធ ស្មាតកាត (Smart Card) ឬបណ្ណ/កាតទូទាត់ ទោះបីក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃ ហើយមានមុខងារសម្រាប់ទូទាត់។

៥. **កម្មវិធីចម្លងមេរោគ(Contaminant)** សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បី៖

(ក) កែប្រែ បំផ្លាញ កត់ត្រា បញ្ជូនទិន្នន័យឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ

(ខ) ជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក។

៦. **ម្ចាស់បណ្ណ/កាតទូទាត់(Cardholder)** សំដៅដល់បុគ្គលដែលមានឈ្មោះចារឹកនៅលើបណ្ណ/កាត និងជាបុគ្គលដែលទទួលប្រយោជន៍ពីបណ្ណ/កាតទូទាត់នោះ។

៧. **ទំនាក់ទំនង(Communication)** សំដៅដល់អំណះអំណាង សេចក្តីថ្លែងការណ៍ ការទាមទារ សេចក្តីជូនដំណឹង សំណូមពរ សំណើ ឬស្ទីការ ដែលគូភាគីត្រូវធ្វើឬសម្រេចចិត្តធ្វើពាក់ព័ន្ធនឹងការបង្កើតឬការអនុវត្តកិច្ចសន្យា។

៨. **បណ្ណ/កាតទូទាត់ក្លែងក្លាយ(Counterfeit card)** សំដៅដល់បណ្ណ/កាតទូទាត់ទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឬការពិពណ៌នាដែលត្រូវបានប្រឌិតឡើង កែប្រែក្លែងបន្លំ ឬបណ្ណ/កាតទូទាត់ដែលមានសមាសធាតុណាមួយនៃបណ្ណ/កាតទូទាត់នោះមានលក្ខណៈខុសច្បាប់។

៩. **ទិន្នន័យ(Data)** សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។

១០. **អេឡិចត្រូនិក(Electronic)** សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស (wireless) អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

១១. **អាសយដ្ឋានអេឡិចត្រូនិក(Electronic Address)** សំដៅដល់លេខឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើឬទទួលការជូនដំណឹង ឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

១២. **យថាភូតភាព(Authenticity)** សំដៅដល់ភាពត្រឹមត្រូវនិងអាចជឿទុកចិត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក។

១៣. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic Commerce)** សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

១៤. **ឧបករណ៍ទូទាត់អេឡិចត្រូនិក(Electronic Payment Instrument)** សំដៅដល់បណ្ណ/កាត ទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយណាដែលមានទម្រង់ជាអេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់សងប្រាក់។

១៥. **ទំនាក់ទំនងអេឡិចត្រូនិក(Electronic Communication)** សំដៅដល់ព័ត៌មានដែលត្រូវបានទាក់ទង ដំណើរការ កត់ត្រាទុក បង្ហាញឡើង បង្កើតឡើង រក្សាទុក ទទួលបាន ឬបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក។

១៦. **ឧបករណ៍អេឡិចត្រូនិក(Electronic device)** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

១៧. **ភស្តុតាងអេឡិចត្រូនិក(Electronic evidence)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារនានាដែលបានបង្កើតឡើង រក្សាទុក ផ្ញើចេញ ឬទទួលក្នុងទម្រង់ឬទំនាក់ទំនងអេឡិចត្រូនិក សម្រាប់ជាសំអាងទាក់ទងនឹងអង្គហេតុណាមួយក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយព័ត៌មាន ទិន្នន័យ ឬឯកសារនោះមានយថាភូតភាពស្របតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

១៨. **ទម្រង់អេឡិចត្រូនិក(Electronic form)** សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

១៩. **ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(Electronic fund transfer)** សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងតាមរយៈបញ្ជារផ្ទេរប្រាក់អេឡិចត្រូនិក ឬតាមឧបករណ៍អេឡិចត្រូនិកចល័ត ឬតាមឧបករណ៍អេឡិចត្រូនិកដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធឬឥណទានក្នុងគណនី។

២០. **កំណត់ត្រាអេឡិចត្រូនិក(Electronic record)** សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

២១. **បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic-Commerce service provider)** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

២២. **ហត្ថលេខាអេឡិចត្រូនិក(Electronic Signature)** សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។

២៣. **ប្រព័ន្ធអេឡិចត្រូនិក(Electronic system)** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

២៤. **ប្រព័ន្ធព័ត៌មាន(Information system)** សំដៅដល់ប្រព័ន្ធសម្រាប់បង្កើត ផ្ញើ ទទួល រក្សាទុក ឬដំណើរការកំណត់ត្រាអេឡិចត្រូនិក។

២៥. **អន្តរការី(Intermediary)** សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖

១. បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក

២. បុគ្គលផ្តល់សេវាទូរគមនាគមន៍

៣. បុគ្គលផ្តល់សេវាបណ្តាញនានា

៤. បុគ្គលផ្តល់សេវាអ៊ិនធឺណិត

៥. បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក

៦. បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ

៧. បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

៨. បុគ្គលផ្តល់សេវាទីផ្សារអនឡាញនិងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណិត។

២៦. **បុគ្គលចេញបណ្ណ/កាតទូទាត់(Issuer)** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬបុគ្គលណាមួយដែលបានចេញបណ្ណ/កាតទូទាត់ ដែលបានទទួលការអនុញ្ញាត។

២៧. កូដព្យាបាទ(Malicious code) សំដៅដល់កម្មវិធីឬតួនាទីលាក់មុខនៃកម្មវិធីដែលចម្លងមេរោគដល់ទិន្នន័យ ព័ត៌មាន ឬឯកសារ ដោយមានឬគ្មានបន្សល់ទុកស្លាកស្នាមសម្គាល់នៃមេរោគនោះក្នុងឯកសារអេឡិចត្រូនិកដែលបានឆ្លងមេរោគ ហើយមេរោគនោះអាចចម្លងបន្តក្នុងប្រព័ន្ធដោយឯកឯងឬដោយមានអន្តរាគមន៍ពីមនុស្ស។

២៨. អ្នកផ្ញើ(Originator) សំដៅដល់ភាគីឬអ្នកតំណាងដែលបានផ្តើមប្រតិបត្តិការបង្កើត រក្សាទុក ឬបញ្ជូនទិន្នន័យតាមមធ្យោបាយអេឡិចត្រូនិក ដោយមិនរាប់បញ្ចូលអន្តរការី។

២៩. បុគ្គលផ្តល់សេវាទូទាត់(Payment Service Provider) សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាតឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិកឬមធ្យោបាយទូទាត់ ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់ ជាអេឡិចត្រូនិកដល់សាធារណជន។

៣០. ទីតាំងអាជីវកម្ម(Place of business) សំដៅដល់៖

ក. ទីតាំងដែលអ្នកផ្ញើឬអ្នកទទួលបានចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ។

ខ. ប្រសិនបើភាគីណាមួយមិនបានចង្អុលបង្ហាញទីកន្លែងអាជីវកម្មជាក់លាក់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែង ទីតាំងអាជីវកម្មត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹងឬពិនិត្យដោយភាគីនៅពេលណាមួយមុនឬក្នុងពេលចុះកិច្ចសន្យា។

គ. សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេនោះ ទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

មិនត្រូវចាត់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីដោយគ្រាន់តែជា៖

- ទីតាំងដែលសម្ភារៈឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាសយដ្ឋានអេឡិចត្រូនិកឬឈ្មោះដែនកម្មសិទ្ធិ(Domain Name) ដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

៣១. កំណត់ត្រា(Record) សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារដែលត្រូវបានកត់ត្រាចូល រក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបី ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជាត្រដាសស្នាម ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។

៣២. **បុគ្គលផ្តល់សេវា( service provider)** សំដៅដល់

(ក) បុគ្គលដែលផ្តល់សេវាព័ត៌មាននិងសេវាទំនាក់ទំនង រួមមាន ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។

(ខ) បុគ្គលដែលជាម្ចាស់ បុគ្គលកាន់កាប់ បុគ្គលដំណើរការ បុគ្គលគ្រប់គ្រង ឬបុគ្គលត្រួតពិនិត្យបណ្តាញស្វិចសាធារណៈ(Public Switched Network) ឬបុគ្គលដែលផ្តល់សេវាទូរគមនាគមន៍។ ឬ

(គ) បុគ្គលផ្សេងទៀតដែលប្រតិបត្តិឬរក្សាទុកទិន្នន័យបម្រើឱ្យសេវាទំនាក់ទំនងអេឡិចត្រូនិកនោះ ឬអ្នកប្រើប្រាស់សេវា។

៣៣. **បុគ្គលផ្តល់នីតិវិធីសុវត្ថិភាព( Security procedure provider)** សំដៅដល់បុគ្គលបង្កើត ឬផ្តល់នីតិវិធីសុវត្ថិភាព។

៣៤. **នីតិវិធីសុវត្ថិភាព(Security Procedure)** សំដៅដល់នីតិវិធីដែលកំណត់ដោយច្បាប់ ឬកិច្ចសន្យា ឬការសម្រេចដោយភាគីណាមួយ ហើយដែលត្រូវបានប្រើក្នុងគោលបំណង៖

(ក) ផ្ទៀងផ្ទាត់ថាហត្ថលេខា ទំនាក់ទំនង ឬប្រតិបត្តិការក្នុងប្រព័ន្ធអេឡិចត្រូនិក ពិតជារបស់បុគ្គលនោះ។

(ខ) រកឱ្យឃើញកំហុសឆ្គងឬការកែប្រែនៅក្នុងទំនាក់ទំនងឬក្នុងកន្លែងរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ចាប់តាំងពីពេលជាក់ណាមួយ។

នីតិវិធីសុវត្ថិភាពខាងលើអាចតម្រូវឱ្យប្រើរូបមន្តអាល់ហ្គោរីត(algorithms)ឬកូដ ពាក្យឬលេខសម្រាប់ សម្គាល់អត្តសញ្ញាណ កូដនីយកម្ម សំណួរសម្ងាត់ ឬការទទួលស្គាល់នីតិវិធីណាមួយ ឬក៏ឧបករណ៍សុវត្ថិភាពស្រដៀងគ្នាផ្សេងទៀត។

៣៥. **ព័ត៌មានឬកំណត់ត្រាជាលាយលក្ខណ៍អក្សរ(writing/written)** សំដៅដល់ព័ត៌មានឬកំណត់ត្រាផ្សេងៗទៀតដែលត្រូវបានសរសេរ ចារឹក ឬបោះពុម្ពនៅលើក្រដាសឬសម្ភារៈ ផ្សេងៗទៀត។

៣៦. **អ៊ីមែលឬសារអេឡិចត្រូនិក(E-mail or Electronic Message)** សំដៅដល់សារឬព័ត៌មានដែលត្រូវបានបង្កើតឡើង ឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

៣៧. **សន្តតិកម្ម(Will)** សំដៅដល់ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

៣៨. **ស្វីការ**(Acceptance) សំដៅដល់ការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដែលក្នុងនោះមាន÷

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ការពិនិត្យនិងទទួលសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម និង ការពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាន និងឯកសារភ្ជាប់

**មាត្រា ៥.-**

បុគ្គលស្នើសុំ ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ ក្នុងទម្រង់អេឡិចត្រូនិក ដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://www.registrationservices.gov.kh។

បុគ្គលស្នើសុំ អាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងចុះបញ្ជី ដើម្បីធ្វើការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះក្នុងនាមបុគ្គលស្នើសុំ ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ ឬ/និង ឯកសារពាក់ព័ន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ព័ត៌មាននិងឯកសារភ្ជាប់ស្នើសុំចុះបញ្ជីអាជីវកម្ម ដែលបានបំពេញដោយបុគ្គលស្នើសុំ សម្រាប់តម្កល់តាមក្រសួង-ស្ថាប័នមានសមត្ថកិច្ចជាទម្រង់អេឡិចត្រូនិក ត្រូវបញ្ជូនដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងសម្រេចផ្ដល់ការអនុញ្ញាតការចុះបញ្ជីអាជីវកម្ម។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារភ្ជាប់ តាមសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយអនុលោមតាមអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីព័ត៌មាន និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬ/និងមិនគ្រប់គ្រាន់ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវជូនដំណឹងដល់បុគ្គលស្នើសុំ ដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់វិញ្ញាបនបត្រឬលិខិតបញ្ជាក់ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែម។

**មាត្រា ៧.-**

កម្រៃសេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ កម្រៃសេវានេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

## ជំពូកទី៣
## ការផ្តល់ ព្យួរ និងដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈគេហទំព័រចុះបញ្ជី

### ផ្នែកទី១
### ការផ្តល់វិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ៨.-**

ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបាន សម្រាប់ប្រើប្រាស់ជាផ្លូវការ តាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ៩.-**

ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវលើព័ត៌មាននិងឯកសារភ្ជាប់ និងត្រូវផ្តល់ការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជី សម្រាប់ប្រើប្រាស់ជាផ្លូវការ រួមមាន ប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និងលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។



ម៉ា

ក្នុងគោលបំណងលើកទឹកចិត្តនិងជំរុញការចុះបញ្ជីពន្ធដារ អ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវបង់ពន្ធប៉ាតង់ត្រឹមតែ ៥០ (ហាសិប) ភាគរយនៃប្រាក់ពន្ធប៉ាតង់ដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានប៉ុណ្ណោះ សម្រាប់ឆ្នាំដែលធ្វើការចុះបញ្ជីអាជីវកម្ម។ ប្រាក់ពន្ធប៉ាតង់នេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល បុគ្គលស្នើសុំត្រូវផ្តល់ព័ត៌មានអំពីគណនីធនាគារជូនអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបានដកហូតដោយស្វ័យប្រវត្តិ។

**មាត្រា ១០.-**

បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីពន្ធដារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ តាមគេហទំព័រចុះបញ្ជីក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ករណីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនបានពិនិត្យនិងផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសនេះ ក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការទេ សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ត្រូវបានចាត់ទុកថា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ ដោយស្វ័យប្រវត្តិ។

ការទទួលយកសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសរបស់បុគ្គលស្នើសុំ តាមទម្រង់ឌីជីថលនេះ អាចបោះពុម្ពបានដោយបុគ្គលស្នើសុំ សម្រាប់ប្រើប្រាស់ជាផ្លូវការ បន្ទាប់ពីបានបំពេញលក្ខខណ្ឌពេញលេញនិងត្រឹមត្រូវតាមគេហទំព័រចុះបញ្ជី ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១១.-**

ក្នុងរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ និងប្រសិនបើគម្រោងដែលស្នើសុំនេះមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមានទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាននិងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីគម្រោងតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើប្រាស់ជាផ្លូវការ ជូនបុគ្គលស្នើសុំតាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ១២.-**

វិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ ក្នុងទម្រង់ឌីជីថល ត្រូវបានបង្កើតឡើងដោយអាចរកប្រភព និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវបានតាមលេខអត្តសញ្ញាណសហគ្រាស តាមគេហទំព័រចុះបញ្ជី ឬនៅតាមក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា ១៣.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចចេញប្រកាស ឬគោលការណ៍ណែនាំ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ផ្នែកទី២

## ការព្យួរ ឬការដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ១៤.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចព្យួរឬដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ក្នុងករណីបុគ្គលស្នើសុំ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

១- មិនគោរព ឬមិនបន្តគោរពតាមលក្ខខណ្ឌតម្រូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ដូចកំណត់ក្នុងអនុក្រឹត្យនេះ

២- បានផ្តល់ព័ត៌មានមិនពិត ឬប្រើឯកសារក្លែងក្លាយ

៣- ប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីព្យួរ ដកហូតឬលុបចោលនូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់នានា ត្រូវអនុលោមតាមអនុក្រឹត្យនេះ និងតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៤

## ការអះអាងភាពត្រឹមត្រូវនៃព័ត៌មានចុះបញ្ជី ក្រមសីលធម៌វិជ្ជាជីវៈ និងការរក្សាការសម្ងាត់

**មាត្រា ១៥.-**

បុគ្គលស្នើសុំ ត្រូវធានាអះអាង តាមទម្រង់អេឡិចត្រូនិក ថាព័ត៌មានស្នើសុំចុះបញ្ជីអាជីវកម្ម និងឯកសារភ្ជាប់ដែលខ្លួនបានបំពេញ និងបញ្ចូលទៅក្នុងគេហទំព័រចុះបញ្ជី ពិតជាព័ត៌មាននិងឯកសារត្រឹមត្រូវនិងមិនក្លែងបន្លំ។ ក្នុងករណីព័ត៌មាននិងឯកសារទាំងនោះ មិនត្រឹមត្រូវឬមានការក្លែងបន្លំ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១៦.-**

អ្នកតំណាងចុះបញ្ជី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដូចខាងក្រោម÷

១-មានភាពសុចរិត និងភាពស្មោះត្រង់ក្នុងការប្រកបអាជីវកម្ម

២-ផ្តល់សេវាប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់

៣-បំពេញភារកិច្ចដោយគិតដល់ប្រយោជន៍របស់អតិថិជនជាចម្បង

៤-ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជន

៥-ត្រូវជៀសវាងមិនឱ្យមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន ឬមានវិធានការសមស្រប ដើម្បីការពារដល់ផលប្រយោជន៍អតិថិជន និងត្រូវជូនដំណឹងជាមុនដល់អតិថិជន ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍។

អ្នកតំណាងចុះបញ្ជី ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់សម្រាប់ចុះបញ្ជីអាជីវកម្មដែលតម្រូវដោយអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន។

**មាត្រា ១៧.-**

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈដែលកំណត់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត។ មន្ត្រីពាក់ព័ន្ធទាំងនេះ ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់ដែលតម្រូវក្នុងអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គលស្នើសុំ ឬអ្នកតំណាងចុះបញ្ជី។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវមាននីតិវិធី មធ្យោបាយ និងយន្តការផ្ទៃក្នុង ដើម្បីរក្សាការសម្ងាត់នូវរាល់ព័ត៌មាននិងឯកសាររបស់បុគ្គលស្នើសុំ។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចរៀបចំប្រកាសអន្តរក្រសួង ដើម្បីគ្រប់គ្រងព័ត៌មាន និងឯកសារភ្ជាប់ដែលតម្រូវដោយអនុក្រឹត្យនេះ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

## នៃអនុក្រឹត្យលេខ ០៩៤ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០

## សទ្ទានុក្រម

**១.បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**២.អ្នកតំណាងចុះបញ្ជី** សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងទទួលបានការផ្ទេរសិទ្ធិពីបុគ្គលស្នើសុំ ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវព័ត៌មានដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៣.ការចុះបញ្ជីអាជីវកម្ម** សំដៅដល់ការចុះបញ្ជីអាជីវកម្ម តាមគេហទំព័រចុះបញ្ជី តាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីទទួលបាន ក្នុងទម្រង់ឌីជីថលនូវ÷

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**៤.គេហទំព័រចុះបញ្ជី** សំដៅដល់គេហទំព័ររួមមួយ សម្រាប់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងទម្រង់អេឡិចត្រូនិក ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**៥.លេខអត្តសញ្ញាណសហគ្រាស** សំដៅដល់លេខបញ្ជាក់អត្តសញ្ញាណសហគ្រាស ដែលផ្តល់ឱ្យដោយប្រព័ន្ធស្វ័យប្រវត្តិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៦.ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (Cambodia Data Exchange - CamDX) សំដៅដល់ថ្នាលបច្ចេក-វិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានាដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ក្នុងគោលដៅតភ្ជាប់ជាប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល។

**៧.ទម្រង់អេឡិចត្រូនិក** សំដៅដល់ព័ត៌មាន ឬទិន្នន័យ ដែលអាចយកមកដំណើការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងចែករំលែក រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**៨.ឯកសារទម្រង់ឌីជីថល** សំដៅដល់ឯកសារដែលមានទម្រង់ជា Portable Document Format (PDF) ឬរូបភាព សម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ដែលបានស្កេន ឬថតចេញពីឯកសាររូបី ឬឯកសារដែលមានទម្រង់ជា PDF ឬរូបភាព ដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

**៩.លិខិតបញ្ជាក់** សំដៅដល់ការបញ្ជាក់ក្នុងទម្រង់ឌីជីថល ដូចខាងក្រោម÷

- ប័ណ្ណពន្ធប៉ាតង់ ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការទទួលនូវសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.......៤៣០/២០..........ក.ប/ប្រ.ក.ខ.ល

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៤៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ៣៣៥សហវ-ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យដំណើរការការផ្តល់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

គណនេយ្យភាព ព្រមទាំងស្របតាមសំណើរបស់វិស័យឯកជននៅក្នុងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ថ្នាក់កណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នូវសេវាសាធារណៈ ដូចខាងក្រោម៖

- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ https://lacms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ https://tvcms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធជនបរទេស https://fwcms.mlvt.gov.kh

ដោយឡែក ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយរាជធានី ខេត្ត នឹងត្រូវឱ្យដាក់ដំណើរការ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ តទៅ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រធានអង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៧រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- អង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


លេខ ៣៣៣៣...សហវ....ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលតម្លៃសេវាសាធារណៈលើប្រភេទសេវាចំនួនបី នៃកម្រងសេវាសាធារណៈដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម÷

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវាចាស់ | តម្លៃសេវាកែសម្រួលថ្មី |
|---|---|---|---|
| | **I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម** | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០ ៛ | ១ ០១០ ០០០ ៛ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០ ៛ | ១៨០ ០០០ ៛ |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០ ៛ | ២៥ ០០០ ៛ |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ថ្ងៃសុក្រ ៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៣៥ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតជូនដំណឹងលេខ១៣៣ សជណ.អវ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសរួមលេខ០៩ សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤ របស់អតីតក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសុខាភិបាល ស្តីពីការពិនិត្យកាយសម្បទាសម្រាប់ជនកម្ពុជា និងជនបរទេស ដែលមកប្រកបមុខរបរនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០០ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស
- បានឃើញប្រកាសរួមលេខ១៣៩ សកបយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ស្តីពីលក្ខខណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស
- យោងលទ្ធផលកិច្ចប្រជុំរបស់ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសអន្តរក្រសួង និងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។ ក្នុងករណីមានបណ្តឹងតវ៉ា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពិនិត្យលទ្ធភាពដោះស្រាយឱ្យបានឆាប់ ឬដោះស្រាយក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបណ្តឹងតវ៉ាពីសាមីជន។

**ប្រការ៤ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ការកែសម្រួលភារកិច្ចលើការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងតាមដានការអនុវត្ត។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមភារកិច្ចប្រមូលចំណូលរៀងៗខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៩ .-**

កម្រងសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១០ .-**

ប្រកាសអន្តរក្រសួងលេខ៧១៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសអន្តរក្រសួងនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១១ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃប្រកាសអន្តរក្រសួងលេខ.[illegible]. សហវ.ប្រក ចុះថ្ងៃទី[illegible]ខែ.[illegible].ឆ្នាំ២០២០

## កម្រៃសេវាសាធារណៈរបស់រដ្ឋបាលកណ្ដាលក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | I. សេវាសាធារណៈផ្នែកសុវត្ថិភាព និងសុខភាពការងារ (OSH) | | | | |
| | ១ | ការពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន | | | |
| ១ | ១.១ | ការពិនិត្យនៅនាយកដ្ឋានពេទ្យការងារ | ២០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២ | ១.២ | ការចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅក្នុងរាជធានីភ្នំពេញ (តាមការស្នើសុំរបស់សហគ្រាស គ្រឹះស្ថាន) | ២៤ ០០០ | ១០ថ្ងៃ | ១ឆ្នាំ |
| ៣ | ១.៣ | ការចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅតាមបណ្ដាខេត្ត (តាមការស្នើសុំរបស់សហគ្រាស គ្រឹះស្ថាន) | ២៨ ០០០ | ១០ថ្ងៃ | ១ឆ្នាំ |
| | ២ | ការពិនិត្យកាយសម្បទាកម្មករ និយោជិតជនបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន | | | |
| ៤ | ២.១ | ការពិនិត្យនៅនាយកដ្ឋានពេទ្យការងារ | ១០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៥ | ២.២ | ការចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅក្នុងរាជធានីភ្នំពេញ (តាមការស្នើសុំរបស់សហគ្រាស គ្រឹះស្ថាន) | ១១០ ០០០ | ១០ថ្ងៃ | ១ឆ្នាំ |
| ៦ | ២.៣ | ការចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅតាមបណ្ដាខេត្ត (តាមការស្នើសុំរបស់សហគ្រាស គ្រឹះស្ថាន) | ១២០ ០០០ | ១០ថ្ងៃ | ១ឆ្នាំ |
| | ៣ | ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស និងពិនិត្យសុខភាព | | | |
| ៧ | ៣.១ | ការធានាសេវាបញ្ជូនពលករ (សេវាបកប្រែឯកសារជាភាសាអង់គ្លេស) | ៤០ ០០០ | ៥ថ្ងៃ | |
| ៨ | ៣.២ | សេវាគ្រូពេទ្យពិនិត្យ (ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា) | ១០ ០០០ | ៥ថ្ងៃ | |
| ៩ | ៣.៣ | សេវាថតវិទ្យុសាស្ត្រ | ១៨ ០០០ | ៥ថ្ងៃ | |
| | ៤ | សេវាមន្ទីរពិសោធន៍ | | | |
| | ៤.១ | ផ្នែកទី១ : ពិនិត្យឈាម | | | |
| ១០ | | - Hematocrite | ៤ ០០០ | ២ថ្ងៃ | |
| ១១ | | - Hematology test (Hg+Vs) | ១០ ០០០ | ២ថ្ងៃ | |
| ១២ | | - Blood Group | ៤ ០០០ | ២ថ្ងៃ | |
| ១៣ | | - Glucose | ៨ ០០០ | ២ថ្ងៃ | |
| ១៤ | | - Total Cholesterol | ៨ ០០០ | ២ថ្ងៃ | |
| ១៥ | | - HDL-Cholesterol | ៧ ០០០ | ២ថ្ងៃ | |
| ១៦ | | - LDL-Cholesterol | ៩ ០០០ | ២ថ្ងៃ | |
| ១៧ | | - Triglyceride | ៦ ០០០ | ២ថ្ងៃ | |
| ១៨ | | - Calcium | ៥ ០០០ | ២ថ្ងៃ | |
| ១៩ | | - Uric Acid | ៥ ០០០ | ២ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ២០ | | - Albumin | ៥ 000 | ២ថ្ងៃ | |
| ២១ | | - Creatinine | ៦ 000 | ២ថ្ងៃ | |
| ២២ | | - Blood Urea | ៦ 000 | ២ថ្ងៃ | |
| ២៣ | | - Serum Iron | ៧ 000 | ២ថ្ងៃ | |
| ២៤ | | - HIV Antibody (Elisa) | ២៥ 000 | ២ថ្ងៃ | |
| ២៥ | | - HBs Ag (Elisa) | ១៨ 000 | ២ថ្ងៃ | |
| ២៦ | | - HBs Ab | ២០ 000 | ២ថ្ងៃ | |
| ២៧ | | - HCV Ab | ៣៤ 000 | ២ថ្ងៃ | |
| ២៨ | | - HAV IgM | ៤០ 000 | ២ថ្ងៃ | |
| ២៩ | | - HAV IgG | ៤០ 000 | ២ថ្ងៃ | |
| ៣០ | | - GOT | ៦ 000 | ២ថ្ងៃ | |
| ៣១ | | - GPT | ៦ 000 | ២ថ្ងៃ | |
| ៣២ | | - Gamma-GT | ៦ 000 | ២ថ្ងៃ | |
| ៣៣ | | - VDRL (RPR) | ១០ 000 | ២ថ្ងៃ | |
| ៣៤ | | - TPHA | ១០ 000 | ២ថ្ងៃ | |
| ៣៥ | | - Malaria Parasite | ៦ 000 | ២ថ្ងៃ | |
| ៣៦ | | - Widal | ៦ 000 | ២ថ្ងៃ | |
| ៣៧ | | - Blood Conservation ( ៤Months) | ២៦ 000 | ២ថ្ងៃ | |
| | ៤.២ | ផ្នែកទី២ : ពិនិត្យទឹកនោម | | | |
| ៣៨ | | - Albumin, Sugar (+Pregnancy Test) | ៨ 000 | ២ថ្ងៃ | |
| ៣៩ | | - Morphine | ២២ 000 | ២ថ្ងៃ | |
| ៤០ | | - Methamphetamine | ២២ 000 | ២ថ្ងៃ | |
| | ៤.៣ | ផ្នែកទី៣ : ពិនិត្យផ្សេងៗ | | | |
| ៤១ | | - Hearing Acuity | ៣០ 000 | ២ថ្ងៃ | |
| ៤២ | | - ECG | ២០ 000 | ២ថ្ងៃ | |
| ៤៣ | | - Heart Ultra-sound | ៦០ 000 | ២ថ្ងៃ | |
| ៤៤ | ៥ | ការបញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ (ក្នុង ១នាក់) | ២០ 000 | ១ថ្ងៃ | ៦ខែ |
| ៤៥ | ៦ | វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារ តាមសហគ្រាស (ក្នុង ១នាក់) | ៤០០ 000 | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| | ៧ | វគ្គបណ្តុះបណ្តាលសុវត្ថិភាព និងសុខភាពការងារ សម្រាប់និយោជក និងតំណាងកម្មករ និយោជិត (ក្នុង ១នាក់) | | | |
| ៤៦ | ៧.១ | នៅរាជធានីភ្នំពេញ | ៥០ 000 | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ៤៧ | ៧.២ | នៅតាមបណ្តាខេត្ត | ៨០ 000 | ៣ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀង សេវា | បរិយាយ | | តម្លៃឯកតា នៃសេវា (រៀល) | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ៤៨ | ៨ | ការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ/ជនបរទេស | ២០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ៤៩ | ៩ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការវាយតម្លៃហានិភ័យការងារនៅតាមរោងចក្រ សហគ្រាស (តាមការស្នើសុំ) | ២ ០០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៥០ | ១០ | ការផ្តល់លិខិតអនុញ្ញាតប្រកបមុខរបរជាគ្រូពេទ្យសហគ្រាស | ២០០ ០០០ | ៧ថ្ងៃ | ២ឆ្នាំ |
| | II. **សេវាសាធារណៈផ្នែករដ្ឋបាលការងារ** | | | | |
| ៥១ | ១១ | ការចុះបញ្ជិកាសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | ១២០ ០០០ | ១ថ្ងៃ | អចិន្ត្រៃយ៍ |
| | ១២ | សំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថាន សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ១០១នាក់ឡើងទៅ ឬបម្រើឱ្យការនាំចេញ ឬធ្វើអាជីវកម្មកាស៊ីណូ ឬជាតំបន់សេដ្ឋកិច្ចពិសេស ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតចាប់ពីផ្កាយបីឡើង ឬជាទីភ្នាក់ងារជ្រើសរើសឯកជន ឬជាក្រុមហ៊ុនអាកាសចរណ៍ ឬជាក្រុមហ៊ុនធានារ៉ាប់រង ឬជាស្នាក់ការកណ្តាលស្ថាប័នហិរញ្ញវត្ថុ ឬជាស្នាក់ការកណ្តាលក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងអង្គការសង្គមស៊ីវិល | | | |
| ៥២ | ១២.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៣ | ១២.២ | ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៤ | ១២.៣ | ការចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | ៦០០ ០០០ | ៦០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៥ | ១២.៤ | ការផ្តល់លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ | ៤៨០ ០០០ | ៧ថ្ងៃ | ២ខែ |
| ៥៦ | ១២.៥ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការបន្ថែមម៉ោង | ១០០ ០០០ | ៧ថ្ងៃ | ២ខែ |
| ៥៧ | ១២.៦ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍/ថ្ងៃបុណ្យដែលមានប្រាក់ឈ្នួល | ១០០ ០០០ | ៧ថ្ងៃ | ១ខែ |
| ៥៨ | ១២.៧ | ការចុះធ្វើអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ (១ដងក្នុង១ឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរនិងកាបូប និងផលិតផលប្រហាក់ប្រហែល) | ១ ០០០ ០០០ | ១៤ថ្ងៃ | ១ឆ្នាំ |
| ៥៩ | ១២.៨ | ការចុះធ្វើអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ (១ដងក្នុង១ឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរនិងកាបូប និងផលិតផលប្រហាក់ប្រហែល) | ៤០០ ០០០ | ១៤ថ្ងៃ | ១ឆ្នាំ |
| | III. **សេវាសាធារណៈផ្នែកទំនាក់ទំនងការងារ** | | | | |
| ៦០ | ១៣ | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ១០១នាក់ឡើងទៅ ឬបម្រើឱ្យការនាំចេញ ឬធ្វើអាជីវកម្មកាស៊ីណូ ឬជាតំបន់សេដ្ឋកិច្ចពិសេស ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតចាប់ពីផ្កាយបីឡើង ឬជាទីភ្នាក់ងារជ្រើសរើសឯកជន ឬជាក្រុមហ៊ុនអាកាសចរណ៍ ឬជាក្រុមហ៊ុនធានារ៉ាប់រង ឬជាស្នាក់ការកណ្តាលស្ថាប័នហិរញ្ញវត្ថុ ឬជាស្នាក់ការកណ្តាលក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងអង្គការសង្គមស៊ីវិល | ២៥០ ០០០ | [illegible]ថ្ងៃ | [illegible]ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | IV. **សេវាសាធារណៈផ្នែកការងារកុមារ** | | | | |
| | ១៤ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេង និងការផ្តល់លិខិតអនុញ្ញាតការ សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ១០១នាក់ឡើងទៅ ឬបម្រើឱ្យការនាំចេញ ឬធ្វើអាជីវកម្មកាស៊ីណូ ឬជាតំបន់សេដ្ឋកិច្ចពិសេស ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតចាប់ពីផ្កាយបីឡើង ឬជាទីភ្នាក់ងារជ្រើសរើសឯកជន ឬជាក្រុមហ៊ុនអាកាសចរណ៍ ឬជាក្រុមហ៊ុននាវាចរណ៍ ឬជាស្នាក់ការកណ្តាលស្ថាប័នហិរញ្ញវត្ថុ ឬជាស្នាក់ការកណ្តាលក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងអង្គការសង្គមស៊ីវិល | | | |
| ៦១ | ១៤.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦២ | ១៤.២ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៣ | ១៤.៣ | ការផ្តល់លិខិតអនុញ្ញាតការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ៨០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៦៤ | ១៤.៤ | ការផ្តល់លិខិតអនុញ្ញាតការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ៨០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | V. **សេវាសាធារណៈផ្នែកបណ្តុះបណ្តាលកូនជាង** | | | | |
| | ១៥ | សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ១០១នាក់ឡើងទៅ ឬបម្រើឱ្យការនាំចេញ ឬធ្វើអាជីវកម្មកាស៊ីណូ ឬជាតំបន់សេដ្ឋកិច្ចពិសេស ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតចាប់ពីផ្កាយបីឡើង ឬជាទីភ្នាក់ងារជ្រើសរើសឯកជន ឬជាក្រុមហ៊ុនអាកាសចរណ៍ ឬជាក្រុមហ៊ុននាវាចរណ៍ ឬជាស្នាក់ការកណ្តាលស្ថាប័នហិរញ្ញវត្ថុ ឬជាស្នាក់ការកណ្តាលក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងអង្គការសង្គមស៊ីវិល | | | |
| ៦៥ | ១៥.១ | សំណុំបែបបទហ្វឹកហ្វឺនកូនជាង | ៥ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ៦៦ | ១៥.២ | ការផ្តល់បណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | ៥ ០០០ | ១៥ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| ៦៧ | ១៥.៣ | ការផ្តល់វិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | ១៥ ០០០ | ១៥ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| | VI. **សេវាសាធារណៈផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | | | | |
| ៦៨ | ១៦ | ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស និស្សិតបង់ថ្លៃ | ៨ ០០០ | ៦០ថ្ងៃ | អចិន្ត្រៃយ៍ |
| | ១៧ | ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | | |
| ៦៩ | ១៧.១ | កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ (រយៈពេលលើសពី៣ខែ) | ៤ ០០០ ០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ៧០ | ១៧.២ | កម្រិតសញ្ញាបត្រជាន់ខ្ពស់/ វិញ្ញាបនបត្ររង បច្ចេកទេស/ ឯកទេស | ៨ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៧១ | ១៧.៣ | កម្រិតវិញ្ញាបនបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ១២ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៧២ | ១៧.៤ | កម្រិតវិញ្ញាបនបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស និងបណ្ឌិតបច្ចេកវិទ្យា/ឯកទេស | ១៦ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៧៣ | ១៧.៥ | បើកសាខា បន្ថែមជំនាញ ឬដំឡើងកម្រិតបណ្តុះបណ្តាល | ៨ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៧៤ | ១៨ | ការសុំបន្តសុពលភាពបញ្ជិកាបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ឥតគិតថ្លៃ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៧៥ | ១៩ | ធ្វើតេស្តសមត្ថភាព ផ្នែកសេវាកម្ម កម្រិត ១ ឬកម្រិត ២ តាមការស្នើសុំ (ក្នុង ១នាក់) | ៨០ ០០០ | | |
| ៧៦ | ២០ | ធ្វើតេស្តសមត្ថភាព ផ្នែកសេវាកម្ម កម្រិត ៣ ឬកម្រិត ៤ តាមការស្នើសុំ (ក្នុង ១នាក់) | ១០០ ០០០ | | |
| ៧៧ | ២១ | ធ្វើតេស្តសមត្ថភាព ផ្នែកវិស្វកម្ម កម្រិត ១ ឬកម្រិត ២ តាមការស្នើសុំ (ក្នុង ១នាក់) | ១២០ ០០០ | | |
| ៧៨ | ២២ | ធ្វើតេស្តសមត្ថភាព ផ្នែកវិស្វកម្ម កម្រិត ៣ ឬកម្រិត ៤ តាមការស្នើសុំ (ក្នុង ១នាក់) | ១៥០ ០០០ | | |
| ៧៩ | ២៣ | ការ[illegible] និងចុះបញ្ជិកា តាមការស្នើសុំ (ក្នុង ១នាក់) | ២០ ០០០ | [illegible]ថ្ងៃ ក្រោយ ប្រកាស[illegible] | [illegible] |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | VII. **សេវាសាធារណៈផ្នែកមុខរបរ និងហត្ថពលកម្ម** | | | | |
| | ២៤ | សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ១០១នាក់ឡើងទៅ ឬបម្រើឱ្យការនាំចេញ ឬធ្វើអាជីវកម្មកាស៊ីណូ ឬជាតំបន់សេដ្ឋកិច្ចពិសេស ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតចាប់ពីផ្កាយបីឡើង ឬជាទីភ្នាក់ងារជ្រើសរើសឯកជន ឬជាក្រុមហ៊ុនអាកាសចរណ៍ ឬជាក្រុមហ៊ុននាវាចរណ៍ ឬជាស្នាក់ការកណ្តាលស្ថាប័នហិរញ្ញវត្ថុ ឬជាស្នាក់ការកណ្តាលក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងអង្គការសង្គមស៊ីវិល | | | |
| ៨០ | ២៤.១ | ការផ្តល់បណ្ណ/ សៀវភៅការងារកម្មករនិយោជិតខ្មែរ | ២០ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨១ | ២៤.២ | ការផ្តល់ទុតិយតាបណ្ណ/ សៀវភៅការងារកម្មករនិយោជិតខ្មែរ | ២០ ០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨២ | ២៤.៣ | បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" លើសៀវភៅការងារកម្មករនិយោជិតខ្មែរ (ប្តូរសហគ្រាស គ្រឹះស្ថាន ឬមុខងារ/ តួនាទី) | ២ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨៣ | ២៤.៤ | បច្ចុប្បន្នភាពទិដ្ឋាការ "ចេញ" លើសៀវភៅការងារកម្មករនិយោជិតខ្មែរ (ប្តូរសហគ្រាស គ្រឹះស្ថាន ) | ២ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨៤ | ២៤.៥ | ការចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចូល" | ៤ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨៥ | ២៤.៦ | ការចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចេញ" | ៤ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |
| | VIII. **សេវាសាធារណៈផ្នែកកម្មករនិយោជិតជាជនបរទេស** | | | | |
| ៨៦ | ២៥ | ការផ្តល់បណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស | ៥២០ ០០០ | ២០ ថ្ងៃ | ១ឆ្នាំ |
| | | - ចំណូលថវិកាជាតិ | ៤០៥ ០០០ | | |
| | | - តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | ១១៥ ០០០ | | |
| ៨៧ | ២៦ | ការផ្តល់បណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍) | ៣៦០ ០០០ | ២០ ថ្ងៃ | ១ឆ្នាំ |
| | | - ចំណូលថវិកាជាតិ | ២៤៥ ០០០ | | |
| | | - តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | ១១៥ ០០០ | | |
| ៨៨ | ២៧ | ការផ្តល់បណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍត្រីកោណ) | ៤៤០ ០០០ | ២០ថ្ងៃ | ១ឆ្នាំ |
| | | - ចំណូលថវិកាជាតិ | ៣២៥ ០០០ | | |
| | | - តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | ១១៥ ០០០ | | |
| ៨៩ | ២៨ | ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ | ២០០ ០០០ | ២០ ថ្ងៃ | ១ឆ្នាំ |
| | | - ចំណូលថវិកាជាតិ | ៨៥ ០០០ | | |
| | | - តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | ១១៥ ០០០ | | |
| ៩០ | ២៩ | ការចេញលិខិតបញ្ជាក់ (ទុតិយតា) សម្រាប់កម្មករ និយោជិត (ជនបរទេស) | ៨០ ០០០ | ១៥ថ្ងៃ | |
| ៩១ | ៣០ | ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស | ៤០ ០០០ | ១៥ថ្ងៃ | |
| | IX. **សេវាសាធារណៈផ្នែកសេវាកម្មការងារឱ្យធ្វើ** | | | | |
| ៩២ | ៣១ | សំណុំលិខិតអនុញ្ញាតដាក់ឱ្យដំណើរការទីភ្នាក់ងារជ្រើសរើសឯកជន លើការ ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស | ១ ៥០០ ០០០ | ១៥ថ្ងៃ | ៥ឆ្នាំ |
| ៩៣ | ៣២ | ការបន្តសុពលភាពការអនុញ្ញាតឱ្យបើកទីភ្នាក់ងារជ្រើសរើសឯកជន លើការ គ្រប់គ្រង និងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស | ១ ៥០០ ០០០ | ១៥ថ្ងៃ | ៥ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ៩៤ | ៣៣ | ការផ្តល់វិញ្ញាបនបត្រលើការគ្រប់គ្រងនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន | ឥតគិតថ្លៃ | ១៥ថ្ងៃ | ៥ឆ្នាំ |
| ៩៥ | ៣៤ | ការអនុញ្ញាតឱ្យបើកទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក | ១ ០០០ ០០០ | ២០ថ្ងៃ | ៥ឆ្នាំ |
| ៩៦ | ៣៥ | ការពន្យារសុពលភាពការអនុញ្ញាតឱ្យបើកទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក | ៨០០ ០០០ | ២០ថ្ងៃ | ៥ឆ្នាំ |
| ៩៧ | ៣៦ | ការធ្វើទុតិយតាវិញ្ញាបនបត្រនានា | ៨០ ០០០ | ២០ថ្ងៃ | ៥ឆ្នាំ |

ឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងលេខ.[illegible]... សហវ.ប្រក ចុះថ្ងៃទី[illegible].ខែ.[illegible]..ឆ្នាំ២០២០

## តម្លៃសេវាសាធារណៈរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

| លេខរៀងសេវា | បរិយាយ | | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ១ | សេវាសាធារណៈផ្នែកអធិការកិច្ចការងារ លើសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថាន សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០១នាក់ ដល់ ០៧នាក់ | | | |
| ១ | ១.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | ៦០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ១.២ | ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | ១.៣ | ការផ្តល់លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ | ២៤០ ០០០ | ៧ថ្ងៃ | ២ខែ |
| ៤ | ១.៤ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការបន្ថែមម៉ោង | ១០០ ០០០ | ៧ថ្ងៃ | ២ខែ |
| ៥ | ១.៥ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍/ ថ្ងៃបុណ្យដែលមានប្រាក់ឈ្នួល | ១០០ ០០០ | ៧ថ្ងៃ | ១ខែ |
| | ២ | សេវាសាធារណៈផ្នែកអធិការកិច្ចការងារ លើសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថាន សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ ដល់ ១០០នាក់ ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតក្រោមផ្កាយបី ឬជាសាខាស្ថាប័នហិរញ្ញវត្ថុ ឬជាសាខាក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងសាខាអង្គការសង្គមស៊ីវិល | | | |
| ៦ | ២.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | ៦០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៧ | ២.២ | ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨ | ២.៣ | ការចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | ៦០០ ០០០ | ៦០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៩ | ២.៤ | ការផ្តល់លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ | ២៤០ ០០០ | ៧ថ្ងៃ | ២ខែ |
| ១០ | ២.៥ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការបន្ថែមម៉ោង | ១០០ ០០០ | ៧ថ្ងៃ | ២ខែ |
| ១១ | ២.៦ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស គ្រឹះស្ថានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍/ ថ្ងៃបុណ្យដែលមានប្រាក់ឈ្នួល | ១០០ ០០០ | ៧ថ្ងៃ | ១ខែ |
| ១២ | ២.៧ | ការចុះធ្វើអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ (១ដងក្នុង១ឆ្នាំសម្រាប់សហគ្រាសគ្រឹះស្ថាន) | ២០០ ០០០ | ១៤ថ្ងៃ | ១ឆ្នាំ |
| ១៣ | ៣ | សេវាសាធារណៈផ្នែកវិវាទការងារ លើការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ ដល់ ១០០នាក់ ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតក្រោមផ្កាយបី ឬជាសាខាស្ថាប័នហិរញ្ញវត្ថុ ឬជាសាខាក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងសាខាអង្គការសង្គមស៊ីវិល | ៨០ ០០០ | ៧ថ្ងៃ | ២ឆ្នាំ |
| | ៤ | សេវាសាធារណៈផ្នែកការងារកុមារ លើការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេង និងការផ្តល់ទិដ្ឋាការ សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០១នាក់ ដល់ ០៧នាក់ | | | |
| ១៤ | ៤.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥ | ៤.២ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦ | ៤.៣ | ការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៧ | ៤.៤ | ការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ៥ | សេវាសាធារណៈផ្នែកការងារកុមារ លើការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេង និងការផ្តល់ទិដ្ឋាការ សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ ដល់ ១០០នាក់ ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតក្រោមផ្កាយបី ឬជាសាខាស្ថាប័នហិរញ្ញវត្ថុ ឬជាសាខាក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងសាខាអង្គការសង្គមស៊ីវិល | | | |
| ១៨ | ៥.១ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៩ | ៥.២ | ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ៨០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ២០ | ៥.៣ | ការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១២ឆ្នាំ ដល់ ១៥ឆ្នាំ | ៦០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២១ | ៥.៤ | ការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងអាយុចាប់ពី ១៥ឆ្នាំ ដល់តិចជាង ១៨ឆ្នាំ | ៦០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | ៦ | សេវាសាធារណៈផ្នែកហ្វឹកហ្វឺនកូនជាង សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ ដល់ ១០០នាក់ ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតក្រោមផ្កាយបី ឬជាសាខាស្ថាប័នហិរញ្ញវត្ថុ ឬជាសាខាក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងសាខាអង្គការសង្គមស៊ីវិល | | | |
| ២២ | ៦.១ | សំណុំបែបបទហ្វឹកហ្វឺនកូនជាង | ៥ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ២៣ | ៦.២ | ការផ្តល់បណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | ៥ ០០០ | ១៥ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| ២៤ | ៦.៣ | ការផ្តល់វិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | ១៥ ០០០ | ១៥ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| ២៥ | ៧ | ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ (រយៈពេលចាប់ពី ៣ខែចុះ) | ២ ០០០ ០០០ | ៣០ថ្ងៃ | ៥ឆ្នាំ |
| ២៦ | ៨ | ការបន្តសុពលភាពបញ្ជិកាបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ (រយៈពេលចាប់ពី ៣ខែចុះ) | ឥតគិតថ្លៃ | ៣០ថ្ងៃ | ៥ឆ្នាំ |
| | ៩ | សេវាសាធារណៈផ្នែកមុខរបរ និងហត្ថពលកម្ម សម្រាប់សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ ដល់ ១០០នាក់ ឬជារមណីយដ្ឋាន និងសណ្ឋាគារកម្រិតក្រោមផ្កាយបី ឬជាសាខាស្ថាប័នហិរញ្ញវត្ថុ ឬជាសាខាក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ និងសាខាអង្គការសង្គមស៊ីវិល | | | |
| ២៧ | ៩.១ | ការផ្តល់បណ្ណ/សៀវភៅការងារកម្មករនិយោជិតខ្មែរ | ២០ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ២៨ | ៩.២ | ការផ្តល់ទុតិយតាបណ្ណ/សៀវភៅការងារកម្មករនិយោជិតខ្មែរ | ២០ ០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ២៩ | ៩.៣ | បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" លើសៀវភៅការងារកម្មករនិយោជិតខ្មែរ (ប្តូរសហគ្រាស គ្រឹះស្ថាន ឬមុខងារ/តួនាទី) | ២ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣០ | ៩.៤ | បច្ចុប្បន្នភាពទិដ្ឋាការ "ចេញ" លើសៀវភៅការងារកម្មករនិយោជិតខ្មែរ (ប្តូរសហគ្រាស គ្រឹះស្ថាន ) | ២ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣១ | ៩.៥ | ការចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចូល " | ៤ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣២ | ៩.៦ | ការចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចេញ " | ៤ ០០០ | ២០ថ្ងៃ | អចិន្ត្រៃយ៍ |